# ទស្សនាវដ្តី កសិកម្ម

# THE AGRICULTURE MAGAZINE



ឆ្នាំទី ១៣ ត្រីមាសទី ៣ (កក្កដា-កញ្ញា) ឆ្នាំ ២០១៤ លេខ ៥១

អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh





ការផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# មាតិកា ទំព័រ


- លិខិតសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........០១
- ព្រះរាជសុន្ទរកថាព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ..........០២
- សុន្ទរកថា**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុង ឱកាសទិវាមច្ឆជាតិ នៅអាងទឹកក្តុល ភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង..........០៦
- របាយការណ៍ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ " នៅអាងទឹកក្តុល ភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង..........១០
- របាយការណ៍ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធីបុណ្យ " រុក្ខទិវា " នៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ..........១៥
- ប្រជាពលរដ្ឋទទួលបានផលប្រយោជន៍ពិតប្រាកដពីកំណែទម្រង់ឡូត៍នេសាទពីរាជរដ្ឋាភិបាល..........២០
- បច្ចេកទេសដាំដំណាំមានប៉េលិន(តពីលេខ៥០)..........២៧
- បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ (តពីលេខ ៥០)..........៣៤
- បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ (តពីលេខ ៥០)..........៤៤
- លិខិតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ផ្ញើជូន ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........៥២
- ច្បាប់ស្តីពីសហគមន៍កសិកម្ម (តពីលេខ ៥០) ..........៥៣
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........៦១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## ផ្ញើជូន
## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រី
## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

*ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ជាទីរាប់អាន !*

ខ្ញុំ និង ភរិយា បានទទួលរួចហើយ នូវលិខិតលេខ ៣១៤៧ កសក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ដែលក្នុងនាម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី បានផ្តល់ជូន ខ្ញុំ និង ភរិយា នូវអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ ចំនួន ១៥០ កន្លែង សម្រាប់ឆ្នាំសិក្សាថ្មី ២០១៤-២០១៥ ខាងមុខនេះ។

សកម្មភាពសប្បុរសធម៌ដ៏ថ្លៃថ្លានេះ បានបង្ហាញនូវការយកចិត្តទុកដាក់ខ្ពស់ ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព និង ប្រសិទ្ធភាព ពិសេស ការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រ ដែលគ្មានលទ្ធភាពបង់ថ្លៃសិក្សាឲ្យកូនចៅបន្តការសិក្សា នៅកម្រិតឧត្តមសិក្សា។

ឆ្លៀតក្នុងឱកាសដ៏រីករាយនេះ ខ្ញុំ និង ភរិយា សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និង សូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ កើតមានដល់ ឯកឧត្តម ក៏ដូចជា គណៈគ្រប់គ្រង បុគ្គលិក និង សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និង សាលាជាតិកសិកម្មកំពង់ចាម ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម និង សហការី ទទួលការរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ និង ភរិយា។

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែកក្កដាឆ្នាំ២០១៤

**ហ៊ុន សែន**

# ព្រះរាជសុន្ទរកថា
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ

(ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤)



*ព្រះរាជសុន្ទរកថា**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ*

- សូមក្រាបថ្វាយបង្គំព្រះមេគណ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សម្តេច ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងប្រិយមិត្តបរទេសជាទីមេត្រី
- ជនរួមជាតិ លោកតា លោកយាយ មាមីង បងប្អូន និងក្មួយៗទាំងអស់ ជាទីនឹករលឹក និងគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីសោមនស្សរីករាយ ជាអនេកប្បការ ដោយបានមកកាន់ខេត្តតាកែវ ដែលជាខេត្តចំណាស់មួយរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមប្រារព្ធពិធីបុណ្យរុក្ខទិវាដ៏វិសេសវិសាលនេះ និង បានមកថ្វាយបង្គំ ព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជម្រាបសួរសុខទុក្ខជនរួមជាតិ លោកតា លោកយាយ មាមីង បងប្អូនក្មួយៗទាំងអស់ដែលបាននិមន្តនិងអញ្ជើញចូលរួមយ៉ាងកុះករក្នុងពិធីដ៏មានអត្ថន័យឧត្តុងឧត្តមនាពេលនេះ។ ឆ្លៀតក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅចំពោះព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមអរគុណចំពោះសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត រដ្ឋទូត លោក លោកស្រី បងប្អូនជនរួមជាតិទាំងអស់ដែលបានធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅដល់ខ្ញុំព្រះករុណាខ្ញុំ។

ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំសូមកោតសរសើរចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងខេត្តតាកែវ ជាពិសេសរដ្ឋបាលព្រៃឈើដែលជាអង្គភាពជំនាញបានសហការគ្នាដោយស្មារតីយកចិត្តទុកដាក់អស់ពីកម្លាំងកាយ និងកម្លាំងចិត្តដើម្បីរៀបចំ ប្រារព្ធពិធីបុណ្យរុក្ខទិវាដ៏មានសារសំខាន់នេះ នៅលើទឹកដីភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ ដើម្បីបង្កើនធនធានព្រៃឈើឡើងវិញ សំដៅប្រែក្លាយតំបន់នេះឱ្យមានទេសភាពល្អស្អាត ប្រកបដោយគម្រប ពណ៌បៃតងកាន់




*ទិដ្ឋភាពប្រជាពលរដ្ឋអញ្ជើញចូលរួមក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ*



**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី**
*ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងដាំកូនឈើជានិមិត្តរូបក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ*

តែស្រស់ត្រកាល និងទាក់ទាញភ្ញៀវទេសចរណ៍ឲ្យមកកំសាន្តកាន់តែច្រើនឡើងថែមទៀតដែលជាចំណែកមួយយ៉ាងល្អប្រសើរ ចូលរួមលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះផងដែរ ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំព្រះករុណាខ្ញុំ សូមពាំនាំមកនូវព្រះរាជទានសេចក្តីនឹករលឹក និងព្រះរាជបណ្តាំផ្ញើសួរសុខទុក្ខ និងសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតអំពី **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាពសេចក្តីថ្លៃថ្នូរនិងសុភមង្គល ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតមកប្រគេនព្រះថេរា-នុត្ថេរៈគ្រប់ព្រះអង្គ និងជូនសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកតា លោកយាយ មាមីង បងប្អូននិងក្មួយៗជាជនរួមជាតិទាំងអស់ដែលបាននិមន្ត និងអញ្ជើញមកចូលរួមក្នុងពិធីបុណ្យរុក្ខទិវាដ៏មហោឡារិកនេះ និងសូមជូនពរបវរមហាប្រសើរចំពោះបងប្អូនជនរួមជាតិទាំងអស់សូមបានប្រកបទៅដោយសេចក្តីសុខសេចក្តីចម្រើន និងទទួលនូវសុភមង្គលគ្រប់ប្រការដើម្បីកសាងជីវភាពរស់នៅឲ្យបានរុងរឿងតរៀងទៅ។

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណចំពោះឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តតាកែវ ដែលបានថ្លែងនូវសុន្ទរកថាស្វាគមន៍មានអត្ថន័យដ៏ជ្រាលជ្រៅ និងខ្លឹមសារច្បាស់លាស់បង្ហាញនូវវឌ្ឍនភាពលើគ្រប់វិស័យ និងការអនុវត្ត នូវរាល់ភារកិច្ចរបស់អាជ្ញាធរ ថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់នៅក្នុងខេត្តតាកែវដែលជាសក្ខីភាពបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា ជីវភាពរបស់បងប្អូនប្រជាពលរដ្ឋកាន់តែប្រសើរឡើងថែមទៀតដែលឆ្លុះបញ្ចាំងឲ្យឃើញនូវការដឹកនាំប្រកបដោយស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់សមស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីរីករាយ និងមានចំណាប់អារម្មណ៍ចំពោះរបាយការណ៍ដ៏មានអត្ថន័យរបស់ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទដែលបានលើកឡើងឆ្លុះបញ្ចាំង ឲ្យឃើញយ៉ាងច្បាស់នូវសមិទ្ធផលជាច្រើនដែលសម្រេចបានក្នុងវិស័យកសិកម្មតាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារី-វប្បកម្ម។ និយាយដោយឡែកអំពីកំណែទម្រង់វិស័យព្រៃឈើ ដើម្បីឈានទៅរកការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ហើយដែលក្នុងរបាយការណ៍ក៏បានគូសបញ្ជាក់ផងដែរ អំពីការគ្រប់គ្រងវិស័យព្រៃឈើដែលកើតឡើងពីការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ខ្ពស់ បំពេញភារកិច្ចតាមគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវ ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ជាពិសេសក្រសួង



**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី**
*ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងទតពិព័រណ៍ផលិតផលកសិកម្មក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ*



***ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថនរោត្តម សីហមុនី***
*ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងផ្ដល់ជូន ព្រះរាជអំណោយដល់ដូនជី*

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពុះពាររួមចំណែកអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្មធ្វើឲ្យមានការរីកចម្រើនទទួលបានលទ្ធផលជាផ្លែផ្កាល្អប្រសើរដើម្បីចូលរួមចំណែក កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ ដែលពឹងអាស្រ័យ លើការប្រកបមុខរបរកសិកម្ម។

- ព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់

- សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី និងបងប្អូនជនរួមជាតិជាទីមេត្រី

ដូចព្រះករុណាគ្រប់ព្រះអង្គនិងបងប្អូនជនរួមជាតិទាំងអស់បានជ្រាបហើយថា បច្ចុប្បន្ននេះវិស័យកសិកម្មយើងក៏ទទួលរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរពីបម្រែបម្រួលអាកាសធាតុ និងការកើនឡើងនៃកំដៅភពផែនដីដែលបង្កឱ្យមានជារៀងរាល់ឆ្នាំនូវគ្រោះរាំងស្ងួត ទឹកជំនន់ និងការរីករាលដាលនៃជំងឺឆ្លងសត្វនិងសត្វល្អិតចង្រៃលើដំណាំជាដើម។ យ៉ាងណាមិញ យើងក៏ទទួលស្គាល់ថា ព្រៃឈើមានទំនាក់ទំនងជាសារវ័ន្តជាមួយជីវិតនៅលើភពផែនដី។ ព្រៃឈើបានផ្ដល់នូវពហុប្រយោជន៍មិនអាចប៉ាន់ប្រមាណបាន ដល់មនុស្សជាតិ ហើយព្រៃឈើមិនត្រឹមតែមានតម្លៃខាងសេដ្ឋកិច្ច និងសង្គមជាតិប៉ុណ្ណោះទេ ថែមទាំងបានជួយថែរក្សា លំនឹងបរិស្ថានធម្មជាតិធ្វើឲ្យធាតុអាកាសមានភាពកាន់តែប្រសើរឡើង រក្សានិយ័តភាពប្រភពទឹក ការពារទីជម្រាល និងការពារជីវចម្រុះ ពោលគឺព្រៃឈើមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយកសិកម្ម។ សរុបមកព្រៃឈើគឺជាប្រភពផ្ដល់ការរស់រានមានជីវិតដល់សត្តនិករទាំងឡាយនៅលើភពផែនដីយើងនេះ។ ដូចនេះព្រៃឈើគឺសម្រាប់យើងទាំងអស់គ្នា យើងទាំងអស់គ្នាត្រូវចូលរួមការពារព្រៃឈើ។

ក្នុងន័យនេះខ្ញុំព្រះករុណាខ្ញុំ សូមបងប្អូនប្រជាពលរដ្ឋយើងទូទាំងប្រទេសមេត្តារួមគ្នាបន្តថែរក្សាការពារព្រៃឈើ និងដាំកូនឈើល្អៗគ្រប់ប្រភេទឱ្យកាន់តែសកម្មខ្លាំងក្លាថែមទៀតនៅលើដីទំនេរតាមទីអារាម ភូមិដ្ឋាន និងនៅទីកន្លែងផ្សេង ទៀតឱ្យបានច្រើនជាអតិបរមារួមទាំងការដាំដុះដំណាំផ្សេងៗ ការចិញ្ចឹមសត្វ និងវារីវប្បកម្មដើម្បីអភិវឌ្ឍន៍មាតុភូមិយើង និងធ្វើឲ្យបរិយាកាសកាន់តែល្អប្រសើរឡើង។ ជាមួយគ្នានេះយើងទាំងអស់គ្នាត្រូវដាំឈើដើម្បីកែលម្អដី បង្កើតធនធានឈើសម្រាប់ប្រើប្រាស់ថែរក្សា និងបង្កើនគម្របព្រៃឈើព្រមទាំងជួយសម្អាតភាពកខ្វក់ក្នុងបរិយាកាស។ ទន្ទឹមនឹងនេះ ចំពោះបងប្អូនទាំងឡាយដែលមានជីវភាពរស់នៅពឹងអាស្រ័យលើផល-អនុផលព្រៃឈើ ត្រូវងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតឱ្យអស់សក្ដានុពល ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនឱ្យកាន់តែល្អប្រសើរថែមទៀត ពិសេសបងប្អូននៅក្នុងសហគមន៍ព្រៃឈើ។

ផ្សារភ្ជាប់ទៅនឹងខ្លឹមសារខាងលើនេះ បងប្អូនជនរួមជាតិក៏បានជ្រាបរួចមកហើយថា ពិធីបុណ្យរុក្ខទិវាជាប្រពៃណីវប្បធម៌ដ៏ឧត្ដុង្គឧត្ដមរបស់ប្រជាជាតិយើងតាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ។ ទិវាដ៏ល្អប្រពៃនេះត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ដើម្បីលើកកម្ពស់ការដាំដើមឈើនៅព្រះរាជាណាចក្រកម្ពុជាយើង ហើយការដាំឈើនេះ ក៏នឹងផ្ដល់នូវបុណ្យកុសល ដល់មនុស្សជាតិផងដែរ បានន័យថាការដាំដើមឈើពិតជាបានផ្ដល់ឱកាសឱ្យយើងទាំងអស់គ្នាបានចូលរួមចំណែកការពារថែរក្សាកេរ្ដិ៍ដំណែលដ៏ល្អផូរផង់របស់ព្រះរាជាណាចក្រកម្ពុជាយើង។

នៅក្នុងបរិយាកាសរីករាយនេះ ខ្ញុំព្រះករុណា ខ្ញុំសូមអំពាវនាវចំពោះព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ក្រសួង ស្ថាប័ននានា អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ គ្រប់គ្រឹះស្ថានសិក្សា ទីវត្តអារាមទាំងអស់ និងបងប្អូនជនរួម ជាតិទូទាំងប្រទេសសូមមេត្តារួមគ្នាបន្តដាំដើមឈើ ថែរក្សា

និងការពារព្រៃឈើរបស់យើងសម្រាប់ផ្តល់នូវក្តីសង្ឃឹមដល់មនុស្សជាតិគ្រប់ជំនាន់តរៀងទៅ។ និយាយរួមយើងទាំងអស់គ្នាត្រូវ៖

- ជំរុញការរួមចំណែកនៃវិស័យព្រៃឈើ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គម

- ជំរុញការរួមចំណែកនៃវិស័យព្រៃឈើចំពោះការកាត់បន្ថយភាពក្រីក្រដោយពង្រឹងគំនិតផ្តួចផ្តើមដល់ប្រជាសហគមន៍មូលដ្ឋានឱ្យចូលរួមក្នុងផែនការអភិវឌ្ឍព្រៃឈើ ក្រោមកិច្ចសហការពីគ្រប់ដៃគូទាំងអស់ ដោយអនុវត្តតាមយុទ្ធសាស្រ្តនិងនីតិវិធីជាមាគ៌ាសម្រាប់តម្រង់ទិសដៅ

- បង្កើនការយល់ដឹង ជាសាធារណៈអំពីសារសំខាន់ និងភាពចាំបាច់នៃការដាំដើមឈើឡើងវិញ និងការប្រើប្រាស់ចម្ការឈើរបស់សហគមន៍ ដើម្បីបំពេញតម្រូវការឈើអុសនិងធ្យូងក្នុងស្រុកប្រកបដោយចីរភាព។

ជាមួយគ្នានេះ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមថារដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនឹងខិតខំបណ្តុះកូនឈើមានតម្លៃឱ្យបានច្រើនប្រភេទថែមទៀតនៅគ្រប់ខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីចែកជូនជាប្រយោជន៍ដល់ប្រជាពលរដ្ឋយើង។ ខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវផងដែរចំពោះសហគមន៍អ្នកផ្តល់ជំនួយជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍរបស់កម្ពុជាទាំងអស់ សូមបន្តជួយឧបត្ថម្ភគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ដល់សកម្មភាពកែទម្រង់ វិស័យព្រៃឈើដ៏ត្រឹមត្រូវ និងល្អប្រពៃរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីការពារព្រៃឈើរបស់យើងសម្រាប់ជាមរតកដល់កូនចៅជំនាន់ក្រោយៗទៀត។ ជាងនេះទៅទៀតសូមមេត្តាបន្តផ្តល់ការគាំទ្រឱ្យបានខ្លាំងក្លាបន្ថែមទៀតដល់ការអនុវត្តផែនការយុទ្ធសាស្រ្តឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុឆ្នាំ២០១៣-២០១៨ ដើម្បីកាត់បន្ថយជាអតិបរមានូវឥទ្ធិពលអវិជ្ជមាននានា ដែលអាចកើតមានឡើង ដោយធានាបាននូវកំណើនរីកលូតលាស់ក្នុងវិស័យកសិកម្មប្រកបដោយចីរភាព ដើម្បីធ្វើជាកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ពិសេសប្រជាកសិករក៏ដូចជាសហគមន៍ និងក្រុមជនងាយរងគ្រោះនៅមូលដ្ឋានជន



*ទិដ្ឋភាពរួមក្នុងពិធីបុណ្យរុក្ខទិវាស្ថិតនៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ*

បទ ព្រមទាំងបង្កើនការកៀរគរ ក៏ដូចជាការប្រើប្រាស់ធនធានជំនួយពីបរទេសឱ្យបានច្រើនជាងមុន សំដៅជំរុញកំណើនសេដ្ឋកិច្ចកសិកម្ម តាមរយៈការអភិវឌ្ឍវិស័យកសិកម្មដែលជាវិស័យមួយមានអាទិភាពនាគ្រប់កាលៈទេសៈរបស់រាជរដ្ឋាភិបាល។ ខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសឱ្យពិធីបុណ្យរុក្ខទិវានេះស្ថិតនៅជាអចិន្ត្រៃយ៍របស់មនុស្សជាតិព្រោះថាយើងទាំងអស់គ្នាចូលរួមដាំដើមឈើ ហើយដើមឈើនឹងជួយទ្រទ្រង់ជីវិតយើង និងភពផែនដីយើងឱ្យរួចផុតពីគ្រោះថ្នាក់មហន្តរាយធម្មជាតិនានាជាពិសេសការប្រែប្រួលអាកាសធាតុដែលជាបញ្ហាសកលសម្រាប់យើងទាំងអស់គ្នា។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរព្រះមេគណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រិយមិត្តបរទេស លោកតា លោកយាយ មាមីង បងប្អូន និងក្មួយៗជាជនរួមជាតិទាំងអស់ សូមបានប្រកបនូវព្រះពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរព្រះគុណ និង សូមអរគុណ!***

# សុន្ទរកថាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុង ឱកាសទិវាមច្ឆជាតិ នៅអាងទឹកក្តុល ភូមិត្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង





*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាមច្ឆជាតិ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

**- សូមគោរពក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ**

**- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត រដ្ឋទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា**

**- ឯកឧត្តមលោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ**

**- លោកតា លោកយាយ បង ប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីនឹករលឹក**

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ និងភរិយាសូមសម្តែងនូវសេចក្តីសោមនស្ស រីករាយជាអនេកកប្បការដោយបានមកចូលរួមក្នុងទិវាមច្ឆជាតិជាលើកទី១២ ដ៏មហោឡារិក និងមានឱកាសបានមកថ្វាយបង្គំទូលសួរសុខទុក្ខ ព្រះតេជគុណ ព្រះថេរានុៈគ្រប់ព្រះអង្គ និងជម្រាបសួរសុខទុក្ខលោកតា លោកយាយ មាមីង បងប្អូនជនរួមជាតិទាំងអស់នៅខេត្តកំពង់ឆ្នាំង ដែលបាននិមន្ត និងអញ្ជើញមកចូលរួមយ៉ាងច្រើនកុះករក្នុងទិវាដ៏មានអត្ថន័យនេះជាមួយគ្នានេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវឯកអគ្គរាជទូត រដ្ឋទូតប្រិយមិត្តបរទេសអស់លោក លោកស្រី មន្ត្រីរាជការបងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ ក្មួយៗសិក្សានុសិស្សទាំងអស់ ដែលបានធ្វើបដិសណ្ឋាកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុតដល់ខ្ញុំព្រះករុណាខ្ញុំ និងភរិយាក្នុងពិធីប្រារព្ធ ទិវាមច្ឆជាតិដ៏មានអត្ថន័យដ៏អស្ចារ្យជារៀងរាល់ឆ្នាំនេះ។

ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងការកោតសរសើរចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសថ្នាក់ដឹកនាំ មន្ត្រីរាជការរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់ដែលបានយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត និងប្រាជ្ញាស្មារតីដើម្បីរៀបចំ ទិវាមច្ឆជាតិ ដ៏មានអត្ថន័យនេះ ជាប្រពៃណី និងជារៀងរាល់ឆ្នាំ។ ដោយឡែកឆ្នាំនេះទៀតសោត ក្រោមកិច្ចសហការគ្នាយ៉ាងជិតស្និតជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងអាជ្ញាធរដែនដីខេត្តកំពង់ឆ្នាំងដែលបានខិតខំរៀបចំពិធីនេះឱ្យកាន់តែមានអត្ថន័យទូលំទូលាយគួរឱ្យចាប់អារម្មណ៍ ក្នុងន័យបំផុសមហាជនឱ្យមានស្មារតីចូលរួមការពារអភិរក្ស អភិវឌ្ឍធនធានជលផល ឱ្យបានយល់ជ្រួលជ្រាបដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋ មន្ត្រីរាជការ ស្ថាប័នរដ្ឋ និងឯកជន ជាពិសេសកូនចៅជំនាន់ក្រោយ សំដៅធានាដល់ការគ្រប់គ្រង និងការប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តរភាព។

**- ព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី បង្អួនជន**

## រួមជាតិជាទីស្នេហា

ខ្ញុំព្រះករុណាខ្ញុំ ក៏សូមបញ្ជាក់ផងដែរថា ក្នុងដំណាក់ដៃលេដ្ឋកិច្ចប្រទេសកម្ពុជាយើងកំពុងអភិវឌ្ឍឈានឡើងជាបន្តបន្ទាប់ ពីប្រទេសក្រីក្រ មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ត្រី និងវារីសត្វផ្សេងៗទៀត នៅតែជាអាហារយ៉ាងសំខាន់របស់ប្រជាពលរដ្ឋខ្មែរ បន្ទាប់ពីស្រូវអង្ករផងដែរ ពោលគឺត្រីជាម្ហូបអាហារដែលពាក់ព័ន្ធដល់ជីវភាពប្រចាំថ្ងៃជាប្រពៃណីរបស់ប្រជាពលរដ្ឋយើងទាំងអស់គ្នាដែលមិនអាចខ្វះបានឡើយ ជាពិសេស អ្នកក្រីក្រនៅតាមតំបន់ជនបទដាច់ស្រយាល។

បច្ចុប្បន្ននេះ អ្នកវិទ្យាសាស្ត្រផ្នែកជលផលនៅលើពិភពលោកបានស្រាវជ្រាវរកឃើញថា ប្រទេសកម្ពុជាយើងជាប្រទេសចូលចិត្តរិភោគត្រី ដែលជាមធ្យមសម្រាប់ប្រជាពលរដ្ឋម្នាក់ៗបរិភោគត្រីប្រមាណ៦៣គីឡូក្រាមក្នុងមួយឆ្នាំ ដោយត្រីបានផ្ដល់ជាប្រភពប្រូតេអ៊ីនប្រមាណ៨០%នៃប្រូតេអ៊ីនសាច់ដែលប្រជាពលរដ្ឋខ្មែរទូទៅទទួលទាន។ កត្តានេះគឺបណ្ដាលមកពីព្រះរាជាណាចក្រកម្ពុជាយើងសម្បូរទៅដោយត្រីទឹកសាបដោយសារមានបឹងទន្លេសាប និងប្រព័ន្ធទន្លេ បឹងបួរ ស្ទឹងជាច្រើន និងទំនាបវាលស្រែដែលអាចផ្ដល់បរិមាណត្រីដ៏ច្រើនដល់ប្រជាជនយើង។

ដូចនេះ វិស័យជលផលកម្ពុជា ក៏បានចូលរួមចំណែកដ៏សំខាន់នៅក្នុងផលទុនជាតិផងដែរ ហើយក៏ជាបណ្ដាញនៃសុវត្ថិភាពសង្គមដែលមនុស្សប្រមាណ៦លាននាក់ មានមុខរបរពាក់ព័ន្ធនឹងវិស័យជលផល ជាអ្នកនេសាទពេញម៉ោង អ្នកកែច្នៃផលនេសាទ អ្នកធ្វើទូកកាណូត អ្នកធ្វើឧបករណ៍នេសាទ ឬលក់ដូរផលនេសាទ និងអ្នកលក់ដូររបស់របរបំរើការងារនេសាទ។

- អង្គពិធីទាំងមូលជាទីមេត្រី

ដូចឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងជនរួមជាតិទាំងអស់បានជ្រាបហើយថា កំណើនប្រជាពលរដ្ឋក៏ដូចជាកំណើនប្រជានេសាទដែលរស់នៅជុំវិញបឹងទន្លេសាប ក៏មានការកើនឡើងយ៉ាងឆាប់រហ័សដែរ រួមផ្សំនិងលទ្ធភាពនៃការណែនាំផ្ទាល់តាមរយៈបណ្ដាញផ្សព្វផ្សាយព័ត៌មានស្ដីពីការប្រើប្រាស់បច្ចេកទេសទំនើប អំពីវិស័យជលផលនៅមានកម្រិត និងការយល់ដឹងអំពីសារៈសំខាន់នៃធនធានធម្មជាតិ បរិស្ថាន





*ប្រជាពលរដ្ឋអញ្ជើញចូលរួមក្នុងឱកាសទិវាមច្ឆជាតិ ប្រារព្ធធ្វើនៅ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

និងអំពីបទប្បញ្ញ នៃការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពនៅក្នុងចំណោមសាធារណជនទូទៅក៏នៅមានកម្រិតដែរ។ ដូចនេះកត្តាទាំងនេះបានជះឥទ្ធិពល និងដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរបន្ថែមទៀត ធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ដល់ធនធានជលផល និងធនធានធម្មជាតិផ្សេងទៀត ដែលស្ថិតនៅតែជាឧបសគ្គចម្បងនៅក្នុងការធ្វើឱ្យបានសម្រេចតាមផែនការប្រើប្រាស់ និងអភិវឌ្ឍធនធានជលផល និងធនធានធម្មជាតិដទៃទៀតប្រកបដោយចីរភាព

លើសពីនេះទៀត ដោយសារតែការប្រែប្រួលអាកាសធាតុជាសកល ដែលបណ្ដាលឱ្យធនធានធម្មជាតិមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ គួរឱ្យកត់សម្គាល់ក្នុងរយៈពេលថ្មីៗកន្លងមកនេះ។ ជាក់ស្ដែងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះយើងឃើញមានភ្លៀងធ្លាក់ច្រើនខុសធម្មតា ខ្យល់ព្យុះផ្គររន្ទះ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាច្រើនករណីដែលបានបំផ្លិចបំផ្លាញផលដំណាំ និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋអស់យ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលយើងទាំងអស់គ្នាមិនសូវដែលបានជួបប្រទះពីពេលមុនមក។





*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញលែងត្រីក្នុងឱកាស ទិវាមច្ឆជាតិនៅអាងទឹកក្តុល ភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

ហេតុហើយ ទើបរាជរដ្ឋាភិបាលយើងបានរៀបចំកម្មវិធីកំណែទម្រង់គោលនយោបាយវិស័យជលផលដ៏ស៊ីជម្រៅមួយដោយកាត់រំសាយឡូត៍នេសាទទាំងអស់ ហើយបានប្រគល់សិទ្ធិអំណាចទៅឱ្យសហគមន៍ជនបទគ្រប់គ្រង និងប្រើប្រាស់ធនធានដោយផ្ទាល់នោះ បានធ្វើឱ្យប្រជាកសិករអាចមានលទ្ធភាពចូលរួមបានយ៉ាងសកម្មនៅក្នុងការសម្រេចចិត្ត និងរៀបចំផែនការ និងកម្មវិធីអភិវឌ្ឍនានារបស់ មូលដ្ឋានសាមី ហើយរួមចំណែកទទួលខុសត្រូវ និងម្ចាស់ការគ្រប់គ្រងធនធានធម្មជាតិដោយខ្លួនឯង។

**- ព្រះតេជព្រះគុណ ព្រះមេគណ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិជាទីស្នេហា!**

ជាក់ស្តែង ថ្វីត្បិតតែយើងបានធ្វើកំណែទម្រង់លុបឡូត៍នេសាទអស់ហើយក្តី ក៏សព្វថ្ងៃនេះយើងពិនិត្យឃើញថា មានការធ្វើនេសាទយ៉ាងខ្លាំងក្លា ដែលជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរ បំផុតចំពោះប្រភេទត្រី ដែលមានសារៈសំខាន់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើង ដោយសារកំណែនយ៉ាងឆាប់រហ័សនចំនួនប្រជាជនទាំងនាជុំបឹងទន្លេសាបក៏ដូចជានៅតាមដងទន្លេមេគង្គ។ ក្រៅពីនេះក៏នៅមានសកម្មភាពអនាធិបតេយ្យផ្សេងៗទៀត ដែលបង្កឱ្យមានការបាត់បង់ និងធ្វើឱ្យរិករិលដល់ជម្រកត្រី ការលើកទំនប់ជីកប្រឡាយរំលោភយកដីធ្វើកម្មសិទ្ធិ ការតាំងទីលំនៅថ្មី ការបម្លែងដីព្រៃលិចទឹកទីជាដីកសិកម្ម ការដុតព្រៃលិចទឹកធម្មជាតិ ការធ្វើនេសាទខុសច្បាប់។ល។ ក៏ជាការដាក់សម្ពាធបន្ថែមយ៉ាងធ្ងន់ធ្ងរដល់វិស័យនេះដែរ។

ហេតុដូចហើយ ទើបយើងទាំងអស់គ្នាចាត់ទុកថាការប្រារព្ធទិវាមច្ឆជាតិ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៤នេះពិតជាមានអត្ថន័យយ៉ាងជ្រាលជ្រៅ ពោលគឺជាថ្ងៃប្រកាសបិទនេសាទ ទូទាំងប្រទេស លើកលែងតែការនេសាទជាលក្ខណៈគ្រួសារ ដើម្បីទុកឱ្យត្រីទាំងឡាយបានពងកូនបន្តពូជទុកសម្រាប់ឆ្នាំក្រោយៗទៀតការបិទនេសាទនេះ គឺយើងហាមឃាត់តែឧបករណ៍ចំនួន០៦មុខ គឺ អួន ម៉ាញ់ ថៃ៉ វា នាម និងឈ្នក់ប៉ុណ្ណោះ។ ចំណែកឯឧបករណ៍មងពាក់ អាចប្រើប្រាស់បាន១០០ម៉ែត្រ ក្រៅពីនោះ មិនមានហាមឃាត់ទេ ដូចជាសន្ទូចរនង លប លាយទ្រូជាដើម។

ជារួម ខ្ញុំព្រះករុណាខ្ញុំ សូមវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលទាំងឡាយដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏ដូចជារដ្ឋបាលជលផលសម្រេចបានថ្មីៗទៀតនារយៈពេលមួយឆ្នាំកន្លងមកនេះ។ ដូចដែលឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាយការណ៍អម្បាញ់មិុញនេះស្រាប់ ហើយខ្ញុំសូមកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីជលផលគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម ដោយសហការជាមួយអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និងសហគមន៍មូលដ្ឋានក្នុងការទប់ស្កាត់ បទល្មើសនេសាទ ក៏ដូចជា ការអភិវឌ្ឍន៍អនុវិស័យជលផលផ្សេងៗទៀត ហើយខ្ញុំសំណូមពរ សូមបន្តនូវប្រពៃណី នៃកិច្ចសហប្រតិបត្តិការ ឱ្យបានជិតស្និទ្ធថែមទៀត ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូរអភិវឌ្ឍជាតិ និងអន្តរជាតិនានា ក៏ដូចជាបងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដើម្បីសម្រេចបានកិច្ចការពារធនធានជលផល

ប្រកបដោយនិរន្តរភាព។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណចំពោះបណ្តាប្រទេសជាមិត្ត អង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសវិស័យជលផលដ៏មានសារៈសំខាន់នេះ ដើម្បីបុព្វហេតុនៃការអភិវឌ្ឍន៍និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា និងនាំប្រទេសកម្ពុជា ឱ្យឈានឡើងដល់ឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនាពេលនេះ។

ក្នុងឱកាស ទិវាមច្ឆជាតិ លើកទី១២ នៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ខ្ញុំព្រះករុណាខ្ញុំ សូមបញ្ជាក់បន្ថែមនូវអនុសាសន៍មួយចំនួនដូចតទៅៈ

ទី១- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជារដ្ឋបាលជលផល ត្រូវរៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សជលផល និងសាងសង់ស្នាក់ការយាមការពារឱ្យច្បាស់លាស់ ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមទាំងធ្វើសកម្មភាពគ្រប់គ្រងកន្លែងអភិរក្សជលផលប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវផ្តល់ថវិកាសម្រាប់ការបោះបង្គោលកន្លែងអភិរក្ស និងការសាងសង់ស្នាក់ការ យាមកាមឱ្យបានទាន់ពេលវេលា។

ទី២- រដ្ឋបាលជលផលត្រូវជំរុញការភ្ញាស់កូនត្រីនិងកូនបង្កង និងប្រភេទវារីសត្វផ្សេងៗទៀតដែលជិតផុតពូជឱ្យបានច្រើនថែមទៀត ដើម្បីបម្រើតម្រូវការរបស់វារីវប្បករ ក៏ដូចជាបម្រើដល់កាតលែងកូនត្រី និងកូនបង្កងទៅក្នុងធម្មជាតិវិញ ព្រោះប្រទេសយើងមានតំបន់លិចទឹកដ៏ទូលំទូលាយដែលអំណោយផលដល់ការលែងកូនបង្កងក្នុងធម្មជាតិ។

ទី៣- រដ្ឋបាលជលផលត្រូវបន្តជំរុញការងារបង្រ្កាបបទល្មើស ឱ្យមានប្រសិទ្ធភាពថែមទៀត ដោយសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក៏ដូចជាស្ថាប័នពាក់ព័ន្ធបន្តកិច្ចការការពារ អភិរក្សធនធានជលផលឱ្យបានល្អប្រសើរក្នុងស្មារតីទទួលខុសត្រូវ សាមគ្គីភាព និងរាយការណ៍ឱ្យបានទាន់ពេលវេលា។ អាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវម្ចាស់ការទទួលខុសត្រូវបង្ក្រាបបទល្មើសជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសយកចិត្តទុកដាក់ទប់ស្កាត់រាល់ឧបករណ៍នេសាទដែលបង្កិតបំផ្លាញ ដល់ធនធានធម្មជាតិធ្ងន់ធ្ងរ និងរុករៀន



*សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញលែងត្រីក្នុងឱកាសទិវាមច្ឆជាតិនៅអាងទឹកក្តុល ភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

បំផ្លាញកាប់ព្រៃលិចទឹក។

ទី៤- រដ្ឋបាលជលផល ត្រូវពង្រីកសកម្មភាពលែងកូនបង្កងទៅក្នុងទំនាបលិចទឹកឱ្យបានច្រើនលានក្បាលថែមទៀត ដើម្បីឱ្យប្រទេសយើងសម្បូរបង្កងនៅគ្រប់ទីកន្លែងព្រមទាំងជួយបំផុស ការអភិវឌ្ឍវារីវប្បកម្ម ដោយត្រូវជំរុញការបង្កាត់ត្រីនៅតាមអាងបង្កាត់ - ភ្ញាស់នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវលើកទឹកចិត្តដល់វិស័យឯកជនទាំងក្នុង និងក្រៅប្រទេសឱ្យវិនិយោគលើការងារចិញ្ចឹមត្រីនិងបង្កង ការកែច្នៃផលិតផលជលផល ជាពិសេសចិញ្ចឹមប្រភេទត្រីក្នុងស្រុកដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់។

ទី៥-ខ្ញុំសូមអំពាវនាវដល់អង្គការជាតិ និងអន្តរជាតិមេត្តាជួយឧបត្ថម្ភ ដល់ការអភិវឌ្ឍវិស័យជលផលដើម្បីជួយកូនចៅជំនាន់ក្រោយ របស់យើងទាំងអស់គ្នាក្នុងន័យ ទាំងអស់គ្នាដើម្បីត្រី ត្រីដើម្បីទាំងអស់គ្នា។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរចំពោះព្រះតេជព្រះគុណ ព្រះមេគណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ លោកតា លោកយាយ មាមីង លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់អស់សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

# របាយការណ៍
## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ" នៅអាងទឹកក្ដុល ភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០១៤



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ" នៅអាងទឹកក្ដុល ភូមិក្រាំងកន្ទ្រោល ឃុំពាមស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

- សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ព្រះមេគណនិង ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

**សូមគោរព** :

- សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រីជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ក្មួយៗសិស្សានុសិស្សនិងបងប្អូនជនរួមជាតិទាំងអស់ ជាទីមេត្រី !

ជាបឋម តាងនាមឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិតនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវគារវកិច្ច និង កតញ្ញូតាធម៌ដ៏ជ្រាលជ្រៅចំពោះវត្តមាន ដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅក្នុងពិធី " ទិវាមច្ឆជាតិ១កក្កដា " ដែលកំពុងប្រារព្ធឡើងនៅអាងទឹកក្ដុល ភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង នាពេលនេះ ។ ទន្ទឹមនេះដែរ ខ្ញុំក៏សូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅផងដែរចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ សមាជិកនៃព្រឹទ្ធសភា រដ្ឋសភា និង រាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី តំណាងអង្គការជាតិ អន្តរជាតិ មន្ត្រីរាជការ សិស្សានុសិស្ស និង បងប្អូនជនរួមជាតិ ដែលបានឆ្លៀតឱកាសអញ្ជើញមកចូលរួមនៅក្នុងពិធីដ៏មានអត្ថន័យនេះ។ នេះគឺជាលើកទី១២ហើយ ដែលទិវាមច្ឆជាតិនេះត្រូវបានរៀបចំឡើង ហើយ **សម្ដេចតេជោ និង សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** តែងតែបានអញ្ជើញចូលរួមដោយផ្ទាល់ ក្នុងគោលបំណងផ្សារភ្ជាប់មនោសញ្ចេតនាជាមួយបងប្អូនប្រជាពលរដ្ឋជាទីស្រឡាញ់របស់សម្ដេចផង និង បំផុសចលនាប្រជាពលរដ្ឋគ្រប់ៗរូបឱ្យចូលរួមយ៉ាងសកម្មក្នុងការថែរក្សាពូជត្រី ក៏ដូចជាវារីជាតិផ្សេងៗទៀតឱ្យមាននៅក្នុងដែនទឹកធម្មជាតិផងព្រមទាំងបង្កើនផលត្រីនៅតាមតំបន់ដែលមិនជាប់ដែននេសាទ ជាពិសេស នៅតាមតំបន់វាលទំនាប និង វាលស្រែក្នុងទូទាំងប្រទេស ដើម្បីធានាឱ្យមានផលត្រីនៅតាមទីតំបន់ជនបទឆ្ងាយដាច់ស្រយាល ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រកបដោយអត្ថន័យនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអនុញ្ញាតពិតពុទ្ធ-ដីកា និង ជម្រាបជូនអង្គពិធីទាំងមូលមេត្តាជ្រាបថាៈ អាងទឹកក្ដុលនេះមានទីតាំងស្ថិតនៅក្នុងឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដែលមានចម្ងាយ៧០គីឡូម៉ែត្រពីរាជធានីភ្នំពេញ ។ អាងទឹកនេះ មានទំនប់ ទ្វាររំដោះទឹក ប្រព័ន្ធស្រោចស្រព និងប្រឡាយជាច្រើនខ្សែ ដែលបានសាងសង់ឡើងក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ តំបន់នេះស្ថិតនៅក្នុងភាពប្រទាញប្រទង់ ដោយសារសង្គ្រាមស៊ីវិលអូសបន្លាយអស់រយៈពេលជិត២០ឆ្នាំ ដែលបានធ្វើឱ្យអាងទឹកនេះទទួល

វងនូវការខូចខាត និងខ្វះការថែទាំ ។ ស្ថិតក្នុងស្ថានភាពនេះ អាងទឹកក្ដុលត្រូវបានស្ដារ និង សាងសង់ឡើងវិញ ក្នុងក្របខ័ណ្ឌនៃគម្រោងប្រព័ន្ធពហុបំណងអភិវឌ្ឍន៍ធនធានទឹកនៅស្ទឹងក្រាំងពន្លៃដែលបានផ្ដល់ហិរញ្ញប្ប-ទានដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA) ក្នុងឆ្នាំ២០០៩-២០១២ ។ បច្ចុប្បន្ននេះ អាងទឹកក្ដុលមានទំហំផ្ទៃទឹកប្រមាណ ១២០ហិកតា មានធារទឹកប្រមាណ៦លានម៉ែត្រត្រីគុណនិងមានជម្រៅជាមធ្យម៥ម៉ែត្រ ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រែវស្សាជាង១.៤០០ហិកតានិង ដីស្រែប្រាំងជិត ៥០០ហិកតា សម្រាប់ឃុំបួន នៅក្នុងស្រុកសាមគ្គីមានជ័យ រួមមាន៖ ឃុំពាម ឃុំត្បែងខ្ពស់ ឃុំស្វាយជុក និងឃុំស្វាយ ដែលមាន៤៤ភូមិ និងមានប្រជាពលរដ្ឋរស់នៅចំនួន៣៩.៣២៥នាក់ ស្មើនឹង៨.៣៦៧គ្រួសារ ។

- សម្ដេចតេជោជាទីគោរពដ៏ខ្ពង់ខ្ពស់
- អង្គពិធីទាំងមូលជាទីមេត្រី !

ក្នុងការអនុវត្តកំណែទម្រង់ស៊ីជម្រៅលើវិស័យជលផល រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទចំនួន១៥៨ឡូត៍ ដែលមានផ្ទៃសរុប៩៥៣ពាន់ហិកតា ក្នុងនោះបានកាត់ជូនប្រជាពលរដ្ឋចំនួន៨៥៦.២៣៧ហិកតា ស្មើនឹងប្រមាណ៩០% និងរក្សាទុកធ្វើជាកន្លែងអភិរក្សជលផលចំនួន៩៧.៥០០ហ.ត គឺស្មើនឹងប្រមាណ១០%។ ស្ថិតនៅក្នុងដំណាក់កាលកំណែទម្រង់ស៊ីជម្រៅនៃវិស័យជលផលនេះ គួបផ្សំជាមួយនឹងអនុសាសន៍ដ៏ថ្លៃថ្លាជាបន្តបន្ទាប់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំអនុវត្តការងារយ៉ាងសកម្មដូចភ្លៀងរលឹម ដោយរួមសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ និងសហគមន៍មូលដ្ឋាន ដោយប្រើប្រាស់មធ្យោបាយសរុប វិធានការសរុប និងកម្លាំងសរុប លើគោលដៅសំខាន់ៗមួយចំនួនរួមមាន (ទី១) ការលុបបំបាត់បទល្មើសបំផ្លិចបំផ្លាញជលផល ជាពិសេស ការប្រើឧបករណ៍ស្នែមុង និងឧបករណ៍ឆក់ដែលមានឥទ្ធិពលយ៉ាងខ្លាំងលើជីវិតវារីជាតិគ្រប់ប្រភេទ (ទី២) ការលើកកម្ពស់វារីវប្បកម្ម តាមរយៈការបំផុសចលនាលែងកូនត្រី កូនបង្កងក្នុងដែនទឹកធម្មជាតិ (ទី៣) ការអភិរក្សជម្រកត្រីមេពូជ និង(ទី៤) ការការពារ និង ដាំដុះព្រៃលិចទឹក និង ព្រៃកោងកាងឡើងវិញ ។



*ប្រជាពលរដ្ឋអញ្ជើញចូលរួមក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ" នៅអាងទឹកក្ដុល ភូមិក្រាំងកន្ទ្រោល ឃុំពាមស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

ជាសក្ខីភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រសួង និង មន្ត្រីជំនាញរបស់រដ្ឋបាលជលផល រួមជាមួយស្ថាប័នពាក់ព័ន្ធ និង បងប្អូនប្រជាជនយើងទទួលបាននូវសមិទ្ធផលជាក់ស្ដែងក្នុងវិស័យជលផលដូចតទៅ៖

**១. ការអភិវឌ្ឍសហគមន៍នេសាទ:** រហូតមកដល់ឆ្នាំ២០១៤នេះ សហគមន៍នេសាទចំនួន៥១៦សហគមន៍ត្រូវបានបង្កើតឡើង រួមមាន សហគមន៍នេសាទទឹកសាបចំនួន ៤៧៧ និងសហគមន៍នេសាទសមុទ្រចំនួន៣៩សហគមន៍ ក្នុងនោះ សហគមន៍នេសាទចំនួន៣៦០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទរួចហើយ ។ ជាមួយគ្នានេះដែរ យើងក៏បានរៀបចំសហគមន៍នេសាទដែលគ្មានបទល្មើសបានចំនួន២៨សហគមន៍ផងដែរ ធនាគារក្ដាមចំនួន៣៤កន្លែងត្រូវបានបង្កើតឡើង ដែលធ្វើឱ្យផលក្ដាមសេះមានបរិមាណកើនឡើង៤ដង បើប្រៀបធៀបមុនពេលបង្កើតធនាគារនេះ ។

**២. ការអភិរក្សធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម:** បន្ទាប់ពីការកែទម្រង់ស៊ីជម្រៅវិស័យជលផលក្នុងការរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេស រហូតមកដល់ពេលនេះ យើងបានបង្កើតកន្លែងអភិរក្សទូទាំងប្រទេសបានចំនួន១៤៨កន្លែង ដោយគិតទាំងកន្លែងអភិរក្សជលផលថ្មីចំនួន៥០កន្លែងដែលទើបនឹងបង្កើតឡើងផង ។ ក្រៅពីនោះ ការអភិរក្សវារីជាតិផ្សេងៗទៀត ដូចជា៖ ការអភិរក្សផ្កាថ្ម និង ស្មៅសមុទ្រ នៅតាមតំបន់ឆ្នេរ អនុវត្តបានចំនួនជិតបួនពាន់ហិកតា ការដាំព្រៃលិចទឹក និងព្រៃកោងកាង



*កងកម្លាំងមានសមត្ថកិច្ចមូលដ្ឋានអញ្ជើញចូលរួមក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ"*

អនុវត្តបានចំនួន១០០ហិកតា រួមទាំងការការពារផ្សោតទឹកសាប កន្ធាយក្បាលកង្កែប អណ្តើកហ្លួង អណ្តើកសមុទ្រ ក្រពើ សេះសមុទ្រ ព្រមទាំងបានលែងកូនត្រី និង កូនបង្កងប្រមាណ ៥លានក្បាលទៅក្នុងបឹងធម្មជាតិផងដែរ ។ ដោយឡែក ការចិញ្ចឹមត្រីអនុវត្តបានជាង៩០ពាន់តោន បើធៀបនឹងឆ្នាំកន្លងទៅគឺកើនឡើងជាង១៦ពាន់តោន ។ ទន្ទឹមនឹងការងារខាងលើ យើងបានបង្កើតកន្លែងភ្ញាស់ត្រីចំនួន៣០៥កន្លែង ដែលក្នុងនោះ មានកន្លែងភ្ញាស់ត្រីរបស់ប្រជាពលរដ្ឋចំនួន២៩២កន្លែង ដោយបានទទួលការណែនាំបច្ចេកទេសពីមន្ត្រីជំនាញនៃរដ្ឋបាលជលផល ។ យើងបានផលិតកូនត្រីពូជសរុបចំនួនប្រមាណ ១៥០លាន ក្បាល កើនលើសឆ្នាំកន្លងទៅ១០ លានក្បាល ក្នុងនោះក៏មានកូនបង្កងប្រមាណ១លានក្បាលផងដែរ ។ គួរគត់សម្គាល់ថា តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាបន្តបន្ទាប់ពីរដ្ឋបាលជលផល ប្រជាពលរដ្ឋជាង៦១ពាន់គ្រួសារបានចូលរួមយ៉ាងសកម្មក្នុងការចិញ្ចឹមត្រីតាមគ្រប់រូបភាព រួមទាំងការចិញ្ចឹមត្រីក្នុងស្រែផង ហើយកសិករចំនួន១៥៤នាក់បានក្លាយទៅជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយនៅតាមមូលដ្ឋាន ។

ក្នុងឆ្នាំ២០១៣កន្លងមក ផលត្រីសរុបមានចំនួនប្រមាណ ៧២៨ពាន់តោន កើនលើសឆ្នាំមុនចំនួន៤៦ពាន់តោន ក្នុងនោះ ផលនេសាទទឹកសាបមានជាង៥២៨ពាន់តោន ផលនេសាទសមុទ្រមានជាង១១០ ពាន់តោន និងផលវារីវប្បកម្មមានប្រមាណ៩០ពាន់តោន ។

**៣. ការបង្កើតស្រះជម្រកត្រីសហគមន៍:** ដោយអនុវត្តតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចតេជោ កាលពីឆ្នាំ២០០៩ នៅខេត្តកែប រហូតដល់ចុងឆ្នាំ២០១៣នេះ មន្ត្រីរដ្ឋបាលជលផលគ្រប់ខេត្ត បានរៀបចំបង្កើតស្រះជម្រកត្រីសហគមន៍បានចំនួន៧៧៨កន្លែង ដែលក្នុងនោះ ខេត្តកំពង់ស្ពឺមានស្រះជម្រកត្រីច្រើនជាងគេគឺរហូតដល់១៧៣កន្លែង ។ សកម្មភាពនេះក៏បានធ្វើឱ្យផលត្រីតាមវាលស្រែកើនឡើងប្រមាណពី៤ទៅ៦ដង ។

**៤. ការបង្ក្រាបបទល្មើសជលផល:** នៅក្នុងឆ្នាំ២០១៣នេះ មន្ត្រីរដ្ឋបាលជលផលគ្រប់ថ្នាក់បានសហការជាមួយគណៈបញ្ជាការឯកភាពខេត្ត ស្រុក ឃុំ និង សមត្ថកិច្ចពាក់ព័ន្ធបំពេញការងារយ៉ាងសកម្មក្នុងការការពារកន្លែងអភិរក្សជលផល ដោយមិនឱ្យមានការលួចចូលធ្វើនេសាទ ដោយអាណាធិបតេយ្យឡើយ ទោះបីជា មធ្យោបាយ ធនធានមនុស្ស និងថវិកានៅមានកម្រិតក៏ដោយ ។ ជាលទ្ធផលជាក់ស្តែង យើងបានធ្វើការបង្ក្រាបបទល្មើសបានចំនួន៣.៨០២ករណី ធៀបនឹងឆ្នាំមុនថយចុះចំនួន១.៥០៥ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន៣.៤៨១ករណី ពិន័យអន្តរការណ៍ចំនួន២២៥ករណី បញ្ជូនទៅតុលាការចំនួន៩៦ករណី ។

**៥. ការអភិវឌ្ឍបច្ចេកវិទ្យាកែច្នៃ និង គុណភាព:** នេះជាការងារថ្មីមួយទៀតដែលរដ្ឋបាលជលផលកំពុងផ្សព្វផ្សាយដល់គ្រប់កន្លែងផលិត និង កែច្នៃត្រី ឱ្យគោរពតាមស្តង់ដារអនាម័យឱ្យបានត្រឹមត្រូវ ក្នុងន័យធានាសុវត្ថិភាពសុខភាពសាធារណៈ និងស្តង់ដារទីផ្សារនាំចេញ ដោយរួមទាំងសកម្មភាព ភូមិ១ផលិតផលជលផល១ ។ រដ្ឋបាលជលផលបានរៀបចំសមាគមអ្នកកែច្នៃត្រីបានចំនួន១៦សមាគម និងបានរៀបចំសេចក្តីព្រាងស្តង់ដារត្រីងៀត ប្រហុក និងបង្គាបង្កករហ័សដាក់ជូនវិទ្យាស្ថានជាតិស្តង់ដារ ពិនិត្យរួចហើយ។

ក្រៅពីនោះក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍផ្នែកជលផល និងក្រោមកិច្ចខិតខំប្រឹងប្រែងអស់រយៈកាលជាង១០ឆ្នាំកន្លងមកនេះ ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ វិស័យជលផលមានការប្រែប្រួលរីកចម្រើន និងទទួលបានលទ្ធផលគួរជាទីមោទនៈ ជាអាទិ៍ការកសាងអគារវិទ្យាស្ថានមជ្ឈមណ្ឌលស្រាវជ្រាវទាំងទឹកសាប ទឹកប្រៃ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល(២០១០-២០១៩) ការបោះពុម្ពផ្សាយសៀវភៅបច្ចេកទេស ប៉ាណូ ប៉ូស្ទ័រជាច្រើនម៉ឺនច្បាប់ និងការងារផ្សេងៗទៀតជាច្រើន ។ ទន្ទឹមនឹងនេះ មន្ត្រីជំនាញរដ្ឋបាលជលផលធ្លាប់បានផ្តល់នូវបទពិសោធន៍

អំពីផ្នែកវារីវប្បកម្មជាលក្ខណៈគ្រួសារដល់ប្រទេសមួយចំនួន ដូចជា ប្រទេសភូមា ឡាវ ម៉ាដាហ្គាស្ការ និងប្រទេសបេណាំង ព្រមទាំងបានទទួលនូវមន្ត្រីជំនាញនៃបណ្ដាប្រទេសទាំងនោះ ឲ្យមកបំពេញទស្សនកិច្ចសិក្សាលើផ្នែកនេះផងដែរ ។ រីឯបទពិសោធន៍ស្ដីពីការរៀបចំសហគមន៍នេសាទក៏ត្រូវបានទទួលនូវការវាយតម្លៃជាវិជ្ជមាន និងជាគំរូសម្រាប់បណ្ដាប្រទេសនៅក្នុងតំបន់អាស៊ានផងដែរ។

ទោះបីជាបានទទួលនូវសមិទ្ធផលជាផ្លែផ្កាដូចបានរៀបរាប់ខាងលើក៏ដោយ ក៏យើងនៅមានការងារជាច្រើនទៀតដែលត្រូវបំពេញជាបន្ទាន់ ដូចជា ការទប់ស្កាត់ការទន្ទ្រានយកដីក្នុងដែននេសាទធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ ការបង្ក្រាបបទល្មើសនេសាទ ដែលការងារនេះត្រូវខិតខំពុះពារជម្នះឱ្យខាងតែបាន។ ជារួមសមិទ្ធផលទាំងឡាយដែលសម្រេចបានប្រកបដោយមោទនភាពនេះ ពិតជាមិនអាចកាត់ផ្ដាច់បានពីក្បួនតម្រាប្រកបដោយតេជានុភាពដែលមានចែងយ៉ាងច្បាស់ក្នុងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីការលើកកម្ពស់ការអភិវឌ្ឍវារីវប្បកម្មទាំងទឹកសាប និងសមុទ្រឱ្យបានទូលំទូលាយរួមទាំងការកែច្នៃ និង ការធ្វើពាណិជ្ជកម្មសំដៅធានាសេចក្ដីត្រូវការរបស់ប្រជាជន និងទីផ្សារនាំចេញដោយធានាចីរភាពជាអមតៈនៃធនធានជលផលទាំងក្នុងដែនទឹកសាប និង សមុទ្រ។

- សម្ដេចតេជោជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- អង្គពិធីទាំងមូលជាទីមេត្រី !

ខ្ញុំព្រះករុណាខ្ញុំ សូមអនុញ្ញាតពិតពុទ្ធដីកា និង សូមគោរពជម្រាបជូនសម្ដេចតេជោ សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត និង អង្គពិធីទាំងមូលមេត្តាជ្រាបថា នៅក្នុងឱកាសទិវាមច្ឆជាតិ១ កក្កដា ២០១៤ ដ៏មហោឡារិកនេះ យើងនឹងរៀបចំពិធីលែងកូនត្រីចម្រុះចំនួន ១លានក្បាល កូនបង្កង១សែនក្បាល និង មេត្រីពូជមួយចំនួន ដូចជា ត្រីគល់រាំង ត្រីអណ្ដែង ត្រីក្រាញ់ និងត្រីផ្ទក់។ល។ ដើម្បីធ្វើឱ្យអាងទឹកនេះ សម្បូរទៅដោយត្រី និងបង្កងឡើងវិញ សម្រាប់បម្រើសេចក្ដីត្រូវការហូបចុករបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ។ ម្យ៉ាងទៀត ចាប់ពីឆ្នាំនេះតទៅ រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគម្រោងនឹងលែងកូនបង្កងនៅតាមទីកន្លែងនានានៅក្នុងដែនទឹកធម្មជាតិនៅក្នុងប្រទេសយើង ឱ្យកាន់តែច្រើនថែមទៀត ។









ការជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ "នៅអាងទឹកក្ដុល ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងជួយឧបត្ថម្ភគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន បណ្តាប្រទេសជា មិត្ត អង្គការជាតិ និងអន្តរជាតិនានា ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ក្នុងការជួយជ្រោមជ្រែងអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាពសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។ ខ្ញុំព្រះករុណាខ្ញុំ មានក្តីសង្ឃឹមយ៉ាងមុតមាំថា ការថែរក្សា ការការពារ ការអភិរក្ស និងការទប់ស្កាត់បទល្មើសជលផល គឺជាកាតព្វកិច្ចរួមប្រកបដោយភាពទទួលខុសត្រូវខ្ពស់របស់តួអង្គពាក់ព័ន្ធទាំងអស់ ដែលរួមមាន ទាំងអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និង ប្រជាពលរដ្ឋនៅក្នុងសហគមន៍មូលដ្ឋានផងដែរ ។

ជាទីបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំព្រះករុណាខ្ញុំសូមបន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក គុណបុណ្យព្រះរតនត្រៃ និង បារមីម្ចាស់ទឹកម្ចាស់ដី សូមលោកតាមជួយបីបាច់ថែរក្សា សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមបានប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខមហាប្រសើរ ប្រាជ្ញាឈ្លាសវៃជានិច្ចនិរន្តរ៍ឈ្នះអស់មារសត្រូវគ្រប់ទិសទី និងទទួលបាននូវជោគជ័យធំៗថែមទៀតដើម្បី ដឹកនាំប្រទេសជាតិមាតុភូមិឆ្ពោះទៅរកសេចក្តីសុខ សន្តិភាព សម្បូររុងរឿង និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូបជារៀងដរាបតទៅ ។ ខ្ញុំព្រះករុណាខ្ញុំ យើងខ្ញុំទាំងអស់គ្នា សូមប្តេជ្ញាអនុវត្តតាមការដឹកនាំដ៏ថ្លៃថ្លារបស់ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាជាពិសេស ក្នុងការអភិវឌ្ឍវិស័យកសិកម្ម តាមគោលនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៥នេះ ឱ្យទទួលបានលទ្ធផលជាផ្លែផ្កា ក្នុងបុព្វហេតុផលប្រយោជន៍របស់ប្រជាជន កំណើនសេដ្ឋកិច្ចជាតិ និង មាតុភូមិកម្ពុជាដ៏រុងរឿង ។ សូមប្រគេនពរព្រះតេជព្រះគុណគ្រប់ព្រះអង្គ សូមគោរពជូនពរបវរប្រសើរដល់គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ បងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ និង ក្មួយៗសិស្សានុសិស្សទាំងអស់ សូមទទួលនូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។





*ទិដ្ឋភាពរួមក្នុងឱកាសប្រារព្ធពិធី "ទិវាមច្ឆជាតិ" នៅអាងទឹកក្តុលស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង*

នាឱកាសដ៏នក្ខត្តឫក្សនេះ ខ្ញុំព្រះករុណាខ្ញុំ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាអាជ្ញាធរដែនដី មន្ត្រីរាជការ អ្នកមុខអ្នកការ និងប្រជាពលរដ្ឋនៅក្នុងខេត្តកំពង់ឆ្នាំងទាំងមូល មានមោទនភាព និងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមអនុញ្ញាតគោរពអញ្ជើញសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាផ្តល់នូវមតិសំណេះសំណាល និងអនុសាសន៍គន្លឹះ ដើម្បីជាប្រទីបសម្រាប់យើងខ្ញុំទាំងអស់គ្នាបន្តអនុវត្តការកែទម្រង់ស៊ីជម្រៅលើវិស័យជលផលឱ្យបានទទួលជោគជ័យជាផ្លែផ្កាតរៀងទៅ។

***សូមគោរពអញ្ជើញសម្តេចតេជោនាយករដ្ឋមន្ត្រី***

***សូមអរព្រះគុណ និងសូមអរគុណ!***

# របាយការណ៍

## ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធីបុណ្យ " រុក្ខទិវា " នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ

ថ្ងៃទី ៧ ខែកក្កដា ឆ្នាំ២០១៤



*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធីបុណ្យ " រុក្ខទិវា " នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ*

- សូមក្រាបថ្វាយបង្គំ ព្រះតេជព្រះគុណ ព្រះមេគណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ

- សូមក្រាបថ្វាយបង្គំ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

- សូមគោរពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ជាទីគោរព

- សូមគោរពសម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ ក្មួយៗ សិស្សានុសិស្ស និងជនរួមជាតិជាទីមេត្រី

នៅក្នុងទិវាដ៏មហានក្ខត្តឫក្សនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិតនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តតាកែវ និងប្រជាពលរដ្ឋដ៏ច្រើនកុះករនៅទីនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នាមានមហាកិត្តិយសដ៏ឧត្ដុង្គឧត្ដម និងមានសេចក្ដីសោមនស្ស រំភើបរីករាយជាអនេកប្បការ ចំពោះវត្តមានរបស់ព្រះតេជព្រះគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមព្រះរាជានុញ្ញាតសម្ដែងនូវអភិវន្ទនាការ និង មហាបដិសណ្ឋារកិច្ចដ៏កក់ក្ដៅបំផុតចំពោះព្រះរាជវត្តមានដ៏ថ្លៃថ្លារបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ ដែលព្រះអង្គទ្រង់យាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៅក្នុងពិធីបុណ្យ" រុក្ខទិវា" នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ នៅក្នុងឱកាសដ៏មហាប្រសើរនេះ ហើយនេះគឺជាព្រះរាជបេសកកម្មលើកទី១០របស់ព្រះអង្គ បន្ទាប់ពីទ្រង់បានយាងចូលរួមក្នុងពិធីបុណ្យ" រុក្ខទិវា" ដែលបានប្រព្រឹត្តទៅនៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ កាលពីឆ្នាំ២០១៣កន្លងទៅនេះ ។ ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងវត្តមានរបស់សម្ដេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោក



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងឱកាសប្រារព្ធពិធីបុណ្យ " រុក្ខទិវា " នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ*




*ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសប្រារព្ធពិធីបុណ្យ " រុក្ខទិវា " នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ*

ជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ ដែលបានយាង និង អញ្ជើញមកចូលរួមនៅក្នុងពិធីបុណ្យរុក្ខទិវាដ៏វិសេសវិសាលនេះ ។

នៅក្នុងឱកាសដ៏មហាប្រសើរនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមព្រះរាជានុញ្ញាតទូលថ្វាយ ប្រគេន និងជម្រាបជូនថា ចាប់តាំងពីឆ្នាំ១៩៩២ រហូតមកដល់ឆ្នាំ២០១៣ ពិធីបុណ្យរុក្ខទិវា ត្រូវបានរៀបចំឡើងចំនួន ២៣លើករួចមកហើយ នៅលើផ្ទៃដីដាំដុះចំនួន៣៧៨ហិកតា ។ សម្រាប់ឆ្នាំ២០១៤នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានកិច្ចសហការជាមួយអាជ្ញាធរខេត្តតាកែវ បានសម្រេចកំណត់យកទីតាំងប្រារព្ធពិធីបុណ្យរុក្ខទិវាលើកទី២៤នេះ នៅក្នុងភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ ក្នុងតំបន់ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ភ្នំតាម៉ៅ ដែលតំបន់នេះធ្លាប់បានប្រារព្ធពិធីបុណ្យរុក្ខទិវាម្ដងរួចមកហើយកាលពីឆ្នាំ១៩៩៣ លើផ្ទៃដីទំហំ២០ហិកតា ដែលស្ថិតក្នុងបរិវេណតំបន់នេះដែរ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់អតីតព្រះមហាវីរក្សត្រ ព្រះករុណាព្រះបាទសម្ដេចព្រះ**នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គទ្រង់តែងតែយកព្រះទ័យទុកដាក់ខ្ពស់លើការអភិរក្ស និង ស្ដារព្រៃឈើឡើងវិញ ។ នៅក្នុងឱកាសដ៏ប្រពៃនេះទៀត កូនឈើដែលត្រូវយកមកដាំនៅក្នុងពិធីនេះគឺជាប្រភេទឈើក្រញូង អង្កាញ់ សុក្រម កណ្ដឹងដំរីនៅលើផ្ទៃដីទំហំ២០ហិកតា ក្នុងគោលបំណងស្ដារ និងដាំដុះឡើងវិញនូវប្រភេទឈើ ដែលមានអាយុកាលវែង ដើម្បីធ្វើឲ្យបរិស្ថានធម្មជាតិមានភាពល្អប្រសើរឡើងវិញ ដោយរក្សាបាននូវនិយតភាពប្រភពទឹក និងជាទីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ ជាពិសេស គឺដើម្បីចូលរួមកាត់បន្ថយការឡើងកម្ដៅនៃផែនដី និងការប្រែប្រួលអាកាសធាតុ ។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមព្រះរាជាអនុញ្ញាតទូលថ្វាយ និងជម្រាបជូនអង្គពិធីទាំងមូលសូមទ្រង់ព្រះមេត្តាជ្រាប និងមេត្តាជ្រាបអំពីប្រវត្តិនៃទីតាំងប្រារព្ធពិធីបុណ្យរុក្ខទិវាថ្ងៃនេះ ដូចមានតទៅ៖ តំបន់ភ្នំតាម៉ៅ ស្ថិតនៅភាគនិរតីនៃរាជធានីភ្នំពេញ មានផ្ទៃដីទំហំ ២.២៨៥ហិកតា ដែលគ្របដណ្ដប់ទៅដោយព្រៃខ្មែងដែលមានប្រភេទឈើដូចជា ធ្នឹក សុក្រំ និងត្បែងជាដើម ។ កាលដើមឡើយ ព្រៃឈើនៅក្នុងតំបន់នេះគឺជាព្រៃបម្រុងទុកតំបន់២៣៩ ឈ្មោះថាព្រៃជាំ ដែលសម្បូណ៌ទៅដោយព្រៃក្រាស់ៗ មានដើមឈើធំៗ សម្រាប់ជាទីជម្រកដ៏សុខសាន្តនៃពពួកម្រឹគីម្រឹគា សត្វខ្លា ដំរីជាដើម ។ តែជាអកុសល ដោយសារសង្គ្រាមរ៉ាំរ៉ៃជាងពីរទសវត្ស បានធ្វើឱ្យតំបន់ព្រៃក្រាស់នេះក្លាយទៅជាទីវាលរហោដ្ឋាន ។ នៅឆ្នាំ១៩៩២ តំបន់នេះត្រូវបានដាក់ឱ្យប្រើប្រាស់ជាតំបន់ការពារដំណុះព្រៃ ដាំដុះកូនឈើ និងស្ដារព្រៃឡើងវិញ ក្រោមការគ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានរុក្ខាប្រមាញ់ ។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានប្រកាសប្រែក្លាយតំបន់ភ្នំតាម៉ៅនេះ ទៅជាឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ និងបានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ ២០០០ ។ ការបង្កើតឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ មានគោលបំណងបួនជាសំខាន់ គឺ៖(១)ការអភិរក្ស និងវិបុលកម្មសត្វព្រៃដែលងាយរងគ្រោះថ្នាក់ (២)ការសង្គ្រោះសត្វព្រៃ និងស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ (៣)ការអប់រំផ្សព្វផ្សាយ និងសេវាទេសចរណ៍ និង(៤)ការសិក្សាជ្រាវជ្រាវអំពីវិទ្យាសាស្ត្រ



*ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងឱកាសប្រារព្ធពិធីបុណ្យ "វុក្ខទិវា" នៅភូមិកណ្តឹងធំ ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ*

ព្រៃឈើ និងសត្វព្រៃ ។ អស់រយៈកាលជាង១៨ឆ្នាំកន្លងមកនេះ ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅត្រូវបានធ្វើការអភិវឌ្ឍនៅលើផ្ទៃដីចំនួន៨៥ហិកតានៃផ្ទៃដីសរុបដោយបានបែងចែកជាបីតំបន់សំខាន់ៗតាមលក្ខណៈជីវសាស្ត្រនៃក្រុមសត្វព្រៃនីមួយៗ។បច្ចុប្បន្ននេះ ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅបាន និងកំពុងអភិរក្ស ស្តារព្រៃឈើ និងថែរក្សាសត្វព្រៃបានចំនួន១.១៣៤ក្បាល ក្នុងនោះមាន បក្សីចំនួន៤៦ប្រភេទ ថនិកសត្វចំនួន៣៨ប្រភេទ និងល្មូនចំនួន១០ប្រភេទ ហើយសត្វព្រៃមួយចំនួនទៀត ត្រូវបានយកមកព្យាបាលនៅក្នុងមជ្ឈមណ្ឌលនេះ និងត្រូវដោះលែងទៅកាន់ព្រៃធម្មជាតិវិញ បន្ទាប់ពីមានសុខភាពរឹងមាំហើយ ។ ទន្ទឹមនេះ ទ្រុងសត្វតូចធំចំនួន២៤៩ទ្រុងត្រូវបានសាងសង់ឡើង តាមតម្រូវការចាំបាច់ សម្រាប់សេវាថែទាំ សង្គ្រោះ និងព្យា-បាលសត្វព្រៃ។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្រាលគ្រួសក្រហម ដែលមានប្រវែងជាង១១គីឡូម៉ែត្រ និងសួនច្បារតាមបណ្តោយផ្លូវប្រវែងជិត២ពាន់ម៉ែត្រត្រូវបានស្ថាបនាឡើង សម្រាប់បម្រើសេវាគ្រប់គ្រងឧទ្យានសួនសត្វ និងសេវាទេសចរណ៍ ព្រមទាំងបានសាងសង់អគារជាច្រើនដូចជា អគាររដ្ឋបាល អគារអប់រំ អគារសារមន្ទីរ មន្ទីរពេទ្យសត្វព្រៃ ឃ្លាំងសម្ភារ ផ្ទះបាយ និងបណ្តាញផ្គត់ផ្គង់ទឹកពីទន្លេបាទី និងនៅក្នុងសួនសត្វ ។

- ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

- អង្គពិធីទាំងមូលជាទីគោរព

ក្នុងនីតិកាលទី៥នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បាន និងកំពុងបន្តកំណែទម្រង់លើវិស័យព្រៃឈើ និងកំណែទម្រង់ការគ្រប់គ្រងវិស័យដីធ្លី ដែលជាមូលដ្ឋានគ្រឹះដ៏មានអាទិភាពក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងទី៣នៃរាជរដ្ឋាភិបាល ។ ដើម្បីសម្រេចឱ្យបានតាមទិសដៅនៃគោលនយោបាយ និងយុទ្ធសាស្ត្រដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញអនុវត្តកម្មវិធីព្រៃឈើជាតិ ជាពិសេស កម្មវិធីកំណត់ព្រំប្រទល់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ កម្មវិធីអភិរក្សធនធានព្រៃឈើ និងជីវ-ចម្រុះ កម្មវិធីពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ច និង កម្មវិធីសហគមន៍ព្រៃឈើជាដើម ។ ជាសក្ខីភាព នៅក្នុងឆ្នាំ២០១៣នេះ រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានសម្រេចនូវស្នាដៃ និងសមិទ្ធផលធំៗជាច្រើន រួមមាន៖ ការបោះបង្គោលព្រំប្រទល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍បាន៨១៧បង្គោល ដែលមានប្រវែង៩៧គីឡូម៉ែត្រ ។ ការដាំដុះព្រៃឈើជាចម្ការក្នុងក្របខ័ណ្ឌនៃការអភិរក្សធនធានព្រៃឈើ និងជីវចម្រុះសរុបមានផ្ទៃដីជិត១៨ពាន់ហិកតា ដែលក្នុងនោះ រដ្ឋបាលព្រៃឈើដាំបាន៣៥០ហិកតា និងក្រុមហ៊ុនវិនិយោគឯកជនដាំបានចំនួនជាង១៧.៥០០ហិកតា ។ ទន្ទឹមនោះ រដ្ឋបាលព្រៃឈើបានបណ្តុះកូនឈើនៅគ្រប់ទីកន្លែងនៅក្នុងទូទាំងប្រទេសបានជាង៦លានដើម សម្រាប់ដាំតាមទីសាធារណៈ និងបានចែកកូនឈើគ្រប់ប្រភេទជូនដល់ប្រជាពលរដ្ឋសម្រាប់ដាំជាលក្ខណៈគ្រួសារ ព្រមទាំងបានបង្កើតសួនអាពាហ៍ពិពាហ៍ចំនួន១២កន្លែង ដែលមានផ្ទៃដីទំហំ៩៧ហិកតា ។ ដោយឡែក ផ្នែកឯកជនខ្នាតតូច និងអង្គការក្រៅរដ្ឋាភិបាលក៏បានបណ្តុះកូនឈើបានជាង១លានដើមដែរ ។ រយៈកាលកន្លងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញសេចក្តីប្រកាសបង្កើតសហគមន៍ព្រៃឈើបានចំនួន៥៤កន្លែង ដែលមានផ្ទៃដីសរុបជាង៥៨ពាន់ហិកតា នៅក្នុង



*ទិដ្ឋភាពរួមក្នុងឱកាសប្រារព្ធពិធីបុណ្យ "រុក្ខទិវា" នៅភូមិកណ្ដាលធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ*

ខេត្តចំនួន១០ ព្រមទាំងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍បានចំនួន៤៦កន្លែងលើផ្ទៃដីសរុបទំហំជាង៦២ពាន់ហិកតា ។ រហូតមកដល់ពេលនេះ សហគមន៍ព្រៃឈើសរុបនៅទូទាំងប្រទេសមានចំនួន៤៧៩កន្លែង ដែលមានផ្ទៃដីជាង៤០៩ពាន់ហិកតាស្ថិតនៅក្នុងខេត្តចំនួន២១ ដោយមានអ្នកចូលរួមចំនួន១១៤.៣៣១គ្រួសារ ស្មើនឹង ៣៣១.៣៨៨នាក់ ក្នុងនោះស្ត្រីមានចំនួន១៦០.១៨៧នាក់ផង ។ ការផ្គត់ផ្គង់ឈើមូល ឈើអារគ្រប់ប្រភេទក៏ដូចជាកូនឈើ និងអុសចម្រុះសម្រាប់ប្រើប្រាស់ក្នុងស្រុក គឺបានមកពីផលនៃការឈូសឆាយសម្អាតដីក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច និងសង្គមកិច្ច ។ ការប្រមូលចំណូលពីវិស័យព្រៃឈើសរុបបានចំនួនជាង៦៣ពាន់លានរៀល គឺស្មើនឹង២៩៥% នៃផែនការឆ្នាំ ។

ក្រៅពីការងារខាងលើ ក្នុងឆ្នាំ២០១៣នេះដែរ ដោយអនុវត្តតាមបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ស **ម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សមត្ថកិច្ចជំនាញរដ្ឋបាលព្រៃឈើបានសហការជាមួយកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រះរាជអាជ្ញាអមសាលាដំបូង និងអាជ្ញាធរដែនដីរាជធានី-ខេត្ត បើកយុទ្ធនាការបង្ក្រាបបទល្មើសព្រៃឈើគ្រប់ប្រភេទនៅទូទាំងប្រទេសបានចំនួន១.៥២៣ករណី ។ បានចុះស្រង់ស្ថិតិដីព្រៃឈើ ដែលមានការរំលោភបំពានបានចំនួនជាង១.៧០០ហិកតា និងបានចេញដីកាបដិសេធដកហូតយកដីព្រៃឈើមកវិញបានចំនួនជាង១.៨០០ហិកតា។

ដោយឡែក ក្នុងការបន្តអភិវឌ្ឍវិស័យកសិកម្ម កសិឧស្សាហកម្ម កៅស៊ូ ការចិញ្ចឹមសត្វ ព្រៃឈើ វារីវប្បកម្ម និងជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានកំណត់ចេញនូវគោលនយោបាយតម្រង់ទិសឆ្ពោះទៅរកការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន តាមរយៈការរៀបចំនូវយុទ្ធសាស្ត្រកម្មវិធី និងផែនការសកម្មភាពនានា ដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០០៩-២០១៣ យុទ្ធសាស្ត្រកសិកម្ម និងទឹក យុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំកៅស៊ូ កម្មវិធីព្រៃឈើជាតិ និងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១០-២០១៩ ។

- ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

- អង្គពិធីទាំងមូលជាទីគោរព

ជាថ្មីម្ដងទៀត តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរមូលដ្ឋាន និងបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលមានវត្តមាននៅទីនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្លែងនូវអំណរព្រះគុណដ៏ជ្រាលជ្រៅបំផុតចំពោះព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលព្រះអង្គទ្រង់បានយាងមកចូលរួម ក្នុងពិធីបុណ្យរុក្ខទិវា ជាប្រវត្តិសាស្ត្រនៅក្នុងទឹកដីនៃស្រុកបាទី ខេត្តតាកែវ ដ៏មហោឡារិកនេះ។ ព្រះរាជវត្តមានដ៏ឧត្ដុង្គឧត្ដមរបស់ព្រះករុណាព្រះមហាក្សត្រជាទីគោរពសក្ការៈនាពេលនេះ គឺជាមហាកិត្តិយសដ៏ធំធេង និងផ្ដល់នូវភាពសប្បាយរីករាយ និងកក់ក្ដៅ សម្រាប់ប្រជារាស្ត្រ នៅក្នុងខេត្តតាកែវទាំងមូល ដែលជាសក្ខីភាព បង្ហាញឱ្យឃើញ អំពីការយកទឹកព្រះទ័យទុកដាក់ខ្ពស់បំផុតរបស់ព្រះករុណាជាអម្ចាស់ ចំពោះសម្បត្តិព្រៃឈើជាតិ និងប្រជារាស្ត្រជាទីស្រឡាញ់របស់ព្រះអង្គ តាមគន្លងព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះវររាជបិតា និងព្រះវររាជមាតារបស់ព្រះអង្គ ។ ទន្ទឹមនឹងនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមថ្លែងនូវអំណរគុណ ដ៏ជ្រាលជ្រៅចំពោះវត្តមាន របស់ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី ឯកឧត្ដម លោកជំទាវ សមាជិក









*ទិដ្ឋភាពរួមក្នុងឱកាសប្រារព្ធពិធីបុណ្យ " វុក្ខទិវា "*
*នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ*

សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងវត្តមានរបស់ សម្ដេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ដែលបានរួមវិភាគទានយ៉ាងសស្រាក់សស្រាំក្នុងការជួយស្ដារ និង អភិវឌ្ឍន៍វិស័យព្រៃឈើ និងសត្វព្រៃនៅកម្ពុជា និង សូមអំពាវនាវជួយបន្តលើវិស័យនេះថែមទៀត ដើម្បីឲ្យកម្ពុជាទទួលបាននូវភាពរីកចម្រើនដូចអារ្យប្រទេសនានាលើសកលលោក ។

ជាទីបញ្ចប់ ក្នុងទិវាដ៏មហានក្ខត្តឫក្សនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នាសូមលំឱនកាយវាចាចិត្ត គោរពបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យគុណកែវទាំងបី និងវត្ថុស័ក្ដិសិទ្ធិក្នុងលោក ពិសេសទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និង ព្រះរាជបល្ល័ង្ក ព្រះបារមីអតីតព្រះមហាវីរក្សត្រ ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ សូមលោកតាមជួយប្រោះព្រំបីបាច់ថែរក្សា **ព្រះករុណាព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល សូមព្រះអង្គទាំងទ្វេមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីទ្រង់គង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់ ត្រជុំសុខដុមរមនា សម្រាប់ប្រជារាស្ត្រជាកូន ជាចៅរបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។ សូមប្រគេនពរ ចំពោះព្រះតេជព្រះគុណ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមគោរពជូនពរជ័យសិរីមង្គលជូនចំពោះឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំង សម្ដេច ព្រះអង្គម្ចាស់ ទ្រង់ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរព្រះគុណ និងអរគុណ!***




## I- សេចក្ដីផ្ដើម

ប្រព័ន្ធឡូត៍នេសាទត្រូវបានដាក់ឱ្យប្រើប្រាស់ជាដំបូងក្នុងប្រទេសកម្ពុជានៅចុងសតវត្សរ៍ទី១៩ (ឆ្នាំ១៨៦៨) ដែលជាប្រព័ន្ធមួយរបស់របបអភិបាលកិច្ចបារាំង។ នៅក្នុងឆ្នាំ១៩០៨ អាណាព្យាបាលបារាំងបានកំណត់រដូវបើក នេសាទ ការបង្កើតឡូត៍នេសាទបម្រុងទុក ការហាមឃាត់មិនឱ្យប្រើប្រាស់ឧបករណ៍ កំណត់កន្លែងនេសាទរបស់អ្នកភូមិក្នុងមូលដ្ឋាន។ ក្រោយបានទទួលឯករាជ្យនៅក្នុងឆ្នាំ១៩៥៤ ក្របខ័ណ្ឌច្បាប់សម្រាប់វិស័យនេសាទត្រូវបានបង្កើតឡើងតាមរយៈការដាក់ឱ្យប្រើប្រាស់ច្បាប់ជលផលនៅក្នុងឆ្នាំ១៩៥៦។

នៅក្នុងដំណាក់កាលឆ្នាំដំបូង ក្រោយការទទួលបានឯករាជ្យ ទំនាស់អំពីប្រព័ន្ធឡូត៍នេសាទក៏បានកើតឡើង។ រាជរដ្ឋាភិបាលសម័យនោះបានបញ្ជាឱ្យបញ្ឈប់ដំណើរការអាជីវកម្មឡូត៍នេសាទមួយចំនួននៅក្នុងជម្លោះជាមួយមន្ត្រីមូលដ្ឋាន និងអ្នកនេសាទ។ នៅឆ្នាំ១៩៧៣ រដ្ឋក៏បានហាមឃាត់ការធ្វើអាជីវកម្មឡូត៍នេសាទ ហើយនៅឆ្នាំ១៩៧៥ ភាគច្រើននៃសកម្មភាពនេសាទក៏ត្រូវបានបោះបង់ចោល។ នៅក្នុងឆ្នាំ១៩៧៩ រដ្ឋាភិបាលបានបែងចែកឡូត៍នេសាទទៅឱ្យប្រជាពលរដ្ឋចងក្រងជាក្រុមសាមគ្គីនេសាទ ហើយរដ្ឋជាអ្នកឧបត្ថម្ភឧបករណ៍និងសម្ភារៈនេសាទ។ នៅឆ្នាំ១៩៨៧ រដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យប្រើប្រាស់ច្បាប់ស្ដីពីការគ្រប់គ្រងវិស័យជលផល។ តរៀងមកនៅឆ្នាំ១៩៨៧ រហូតដល់ឆ្នាំ២០០០ ក៏មានការគ្រប់គ្រងអាជីវកម្មឡូត៍នេសាទ ដោយធ្វើការដេញថ្លៃឡូត៍នេសាទជាសាធារណៈ ហើយក្រោយមកក៏មានឡូត៍នេសាទមួយចំនួនត្រូវបានរាជរដ្ឋាភិបាលដាក់ឲ្យធ្វើការកែលម្អ និងអភិវឌ្ឍដោយសារឡូត៍នេសាទទាំងនោះមានលក្ខណៈខ្សោយផលិតភាព។ ការគ្រប់គ្រងឡូត៍នេសាទ គឺសំដៅតែទៅលើការធ្វើអាជីវកម្មជាចម្បង ប៉ុន្តែដោយសារប្រជាពលរដ្ឋមានចំនួនកាន់តែច្រើនឡើងបានតម្រូវឱ្យរាជរដ្ឋាភិបាល ប្តូរយុទ្ធវិធីគ្រប់គ្រងនេះទៅជាយុទ្ធសាស្ត្រចម្រុះដោយរួមបញ្ចូលទាំងការធ្វើអាជីវកម្មប្រកបដោយនិរន្តរភាព ការអភិរក្ស និងការអភិវឌ្ឍដើម្បីធានាបាននូវតុល្យភាពរវាងផលចាប់និងផលស្តុក។

ចុងក្រោយនេះនៅដើមឆ្នាំ២០១២ ការកែទម្រង់ដ៏ស៊ីជម្រៅលើវិស័យជលផល តាមរយៈការរំសាយឡូត៍នេសាទទាំងស្រុងនៅទូទាំងប្រទេស គឺជាការគិតគូរប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ម៉ឺងម៉ាត់បំផុតរបស់តេជោសែនដោយបានផ្ដល់កន្លែងនេសាទជាលក្ខណៈគ្រួសារបន្ថែមទៀតជូនដល់ប្រជានេសាទសម្រាប់ការធ្វើនេសាទជាលក្ខណៈគ្រួសារ និងរក្សាផ្នែកខ្លះទុកជាកន្លែងអភិរក្សពូជត្រី ដើម្បីធានាបានផលស្តុកធនធានជលផល។ ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រេចយកថ្ងៃទី០១ ខែកក្កដា ជាទិវាមច្ឆជាតិដើម្បីបំផុសចលនាប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ជាន់ថ្នាក់ឱ្យចូលរួមយ៉ាងសកម្មប្រកបដោយឆន្ទៈមោះមុតក្នុងការថែរក្សាពូជត្រីក៏ដូចជាវារិ ជាតិផ្សេងៗទៀតឱ្យមានក្នុងដែនទឹកធម្មជាតិផង បង្កើនផលត្រីនៅតាមតំបន់ដែលមិនជាប់ដែននេសាទផង ជាពិសេសតាមតំបន់សមស្របនៃវាលទំនាប និងវាលស្រែក្នុងទូទាំងប្រទេស ដើម្បីធានាឱ្យមានផលត្រីហូបចុកនៅតាមទីតំបន់ជនបទឆ្ងាយដាច់ស្រយាល។

ក្រោមមាគ៌ាដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា យើងបានកត់សម្គាល់ប្រកបដោយមោទនភាពចំពោះសមិទ្ធផលធំៗលើគ្រប់វិស័យក្នុងនោះក៏មានវិស័យកសិកម្មផងដែរ ដែលរាជរដ្ឋាភិបាលនីតិកាលទី៤ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងម៉ឺងម៉ាត់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សម្រេចបានក្នុងដំណើរការកសាង និងអភិវឌ្ឍលើគ្រប់វិស័យ ទន្ទឹមនឹងដំណើរការរាល់កំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅត្រូវបានជំរុញអនុវត្តប្រកបដោយផ្លែផ្កា

## II- ការកែទម្រង់វិស័យជលផលនិងការអភិវឌ្ឍសហគមន៍នេសាទ

### ក. ការកែទម្រង់វិស័យជលផល



ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងភាពប៉ិនប្រសប់របស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** វិស័យជលផលទទួលបាននូវការធ្វើកំណែទម្រង់ស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ គឺមានន័យថា បានប្រគល់ឡូត៍នេសាទទាំងអស់ ក្នុងក្របខ័ណ្ឌទូទាំងប្រទេសជូនប្រជាជន និងសហគមន៍នេសាទមូលដ្ឋានគ្រប់គ្រងវិញ បន្ទាប់ពីរបបអាណានិគមនិយមបារាំងបានបង្កើតឡើងជាង១សតវត្សកន្លងមក។ តាមរយៈសម្បទាននេះ ផលប្រយោជន៍បានធ្លាក់ដល់ដៃអ្នកដែលមានជីវភាពក្រីក្រពិតប្រាកដ ហើយអ្វីដែលពិសេសមិនអាចកាត់ថ្លៃបាននោះ គឺពួកគាត់មានភាពជា ម្ចាស់ក្នុងការប្រើប្រាស់និងគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព មានការទទួលខុសត្រូវ និងសហការល្អជាមួយសហគមន៍មូលដ្ឋានដូចគ្នា អាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ និងអង្គភាពជលផល។ ទោះបីយើងទទួលបាននូវភាពជោគជ័យប្រកបដោយមោទនៈដូចនេះក៏ដោយ ក៏យើងនៅតែបន្តការងារដូចភ្លៀងរលឹម ដោយប្រើប្រាស់កម្លាំងសរុប វិធានការសរុបគឺ ទី១: ការលុបបំបាត់បទល្មើសបំផ្លិចបំផ្លាញខ្លាំងក្លា ជាពិសេសការប្រើឧបករណ៍ស្វៃមុង និងឧបករណ៍ឆក់ដែលមានឥទ្ធិពលយ៉ាងខ្លាំងលើបរិមាណផលត្រី។ ហេតុនេះហើយ ទើបយើងបានបង្កើនសកម្មភាពបង្ក្រាបបទល្មើសទាំងនេះនៅគ្រប់ទីកន្លែងទូទាំងប្រទេស។ ទី២: ការបំផុសចលនាលែងកូនត្រី លែងកូនបង្កងក្នុងដែនទឹក ធម្មជាតិ ទី៣: ការអភិរក្សស្រះជម្រកត្រីមេពូជនិងទី៤: ការការពារនិងដាំឡើងវិញនូវព្រៃលិចទឹកនិងព្រៃកោងកាង។

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលបានលុបឡូត៍នេសាទចំនួន១៥៨ឡូត៍ ដែលមានផ្ទៃក្រឡាសរុប ៩៥៣.៧៤០ ហិកតា ក្នុងនោះបានកាត់ជូនប្រជាពលរដ្ឋចំនួន៨៥៦.២៣៧ហិកតា ស្មើនឹង៨៩,៧៧% និងរក្សាទុកធ្វើជាកន្លែងអភិរក្សជលផលចំនួន៩៧.៥០៣ហិកតា ស្មើនឹង១០,២៣%។

### ខ. ការអភិវឌ្ឍសហគមន៍នេសាទ

រហូតមកដល់ឆ្នាំ២០១៣នេះ យើងបង្កើតសហគមន៍នេសាទបានចំនួន៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបមាន ចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រមានចំនួន៣៩។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៣៦០ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយ។ ម៉្យាងទៀត យើងក៏បានរៀបចំសហគមន៍នេសាទគ្មានបទល្មើសបានចំនួន២៨សហគមន៍ ផងដែរ ដែលនេះគឺជាទិសដៅទៅអនាគត ដើម្បីលុបបំបាត់បទល្មើសនេសាទ។ ដោយឡែក ការបង្កើតធនាគារក្ដាមមានចំនួន៣៤ កន្លែង ស្មើនឹង៩៥បៃ ហើយបានលែងមេក្ដាមពងចំនួន១.៩៩៩គក្រ ប្រមាណ១៥៣ពាន់ក្បាល។ បើគិតពីឆ្នាំ២០០៨មកដល់បច្ចុប្បន្ន គឺបានលែងមេក្ដាមចំនួន៣៥.៧៦២ គក្រ ប្រមាណ១៦០៣ពាន់ក្បាលដែលបានផ្ដល់កូនក្ដាមចំនួនប្រមាណជាង៤០០៣ពាន់លានក្បាលចូលទៅក្នុងសមុទ្រវិញ។ សកម្មភាព នេះតាមការស្រាវជ្រាវរបស់វិទ្យាស្ថានឃើញថាបានធ្វើឲ្យផលក្ដាមសេះមានកំណើនប្រមាណ៤ដងបើប្រៀបធៀបមុនពេល បង្កើតធនាគារក្ដាម។






ក្រាហ្វិក: ចំនួនសហគមន៍នេសាទពីឆ្នាំ២០០០ដល់ឆ្នាំ២០១៤

### គ.ការអភិរក្សធនធានជលផល

ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផល ដោយរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេសមានកន្លែងអភិរក្សជលផលចំនួន៥០កន្លែង ដែលមានទំហំសរុបប្រមាណ៩៧.៥០៣ហិកតា រហូតមកដល់ពេលនេះមានកន្លែងអភិរក្សទូទាំងប្រទេសចំនួន១៤៨ កន្លែង ដែលមានទំហំសរុបជាង ២១៥ពាន់ហិកតា ស្ថិតនៅក្រោមការគ្រប់គ្រងយ៉ាងត្រឹមត្រូវ។ សកម្មភាពអភិរក្សជលផលផ្សេងៗទៀតមានដូចតទៅ៖ អភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន៣.៨៣១ហិកតានៅតាមតំបន់ឆ្នេរដាំព្រៃលិចទឹក និងព្រៃកោងកាងបានចំនួន១០០ហិកតា ការពារផ្សោតទឹកសាប កន្ធាយក្បាលកង្កែប អណ្តើកហ្លួង អណ្តើកសមុទ្រ ក្រពើ សេះសមុទ្រ ។ល។ បានលែងកូនត្រីនិងកូនបង្គងប្រមាណ៥លានក្បាល ទៅក្នុងបឹងធម្មជាតិ។

| ឈ្មោះទីតាំងកន្លែងអភិរក្ស | ចំនួនទីកន្លែង | ទំហំ (ហត) |
|---|---|---|
| បឹងទន្លេសាប(ថ្មី) | ២៣ | ៩៣ ២៤៦.០០ |
| បឹងទន្លេសាប (ចាស់) | ៨ | ២២៥០០.០០ |
| មេគង្គក្រោម | ២៧ | ៤២៥៧.០០ |
| មេគង្គលើ | ៤៦ | ៤៣៥៥.៥០ |
| តំបន់ឆ្នេរ | ៤៤ | ៩១៥២៣.៨៧ |
| សរុប | ១៤៨ | ២១៥ ៨៨២.៣៧ |

តារាង: ទីតាំងកន្លែងអភិរក្សសរុបទូទាំងប្រទេស

### ឃ. ការបង្ក្រាបបទល្មើសជលផល

ក្នុងឆ្នាំ២០១៣នេះ មន្ត្រីរដ្ឋបាលជលផលគ្រប់ថ្នាក់បានសហការជាមួយគណៈបញ្ជាការឯកភាពខេត្ត ស្រុក ឃុំ និងសមត្ថកិច្ចពាក់ព័ន្ធបំពេញការងារយ៉ាងសកម្ម ទោះបីខ្វះកម្លាំង មធ្យោបាយធ្វើដំណើរ និងថវិការក៏ដោយជាពិសេសយកចិត្តទុក ដាក់ការពារកន្លែងអភិរក្សជលផល មិនឲ្យមានការលួចចូលធ្វើនេសាទអាណាធិបតេយ្យឡើយ។ ឯលទ្ធផលជាក់ស្តែងគឺបង្ក្រាបបទល្មើសបានចំនួន៣.៨០២ ករណី ប្រៀបធៀបឆ្នាំមុនថយចុះចំនួន១.៥០៥ករណីក្នុងនោះបានបំផ្លាញចោលវត្ថុតាង ចំនួន៣.៤៨១ករណី ពិន័យអន្តរ-ការណ៍ចំនួន ២២៥ករណី បញ្ជូនទៅតុលាការចំនួន៩៦ករណី ដាក់ពន្ធនាគារ ចំនួន៥១នាក់ ប្រាក់ពិន័យ និងលក់វត្ថុតាងចំនួនជា១៥៧លានរៀល។

### ង. ការបង្កើតស្រះជម្រកត្រីសហគមន៍

អនុវត្តតាមអនុសាសន៍ពេជ្ររបស់សម្តេចតេជោ កាលពីឆ្នាំ២០០៩នៅខេត្តកែប មន្ត្រីរដ្ឋបាលជលផលគ្រប់ខេត្ត បាន




ក្រាហ្វិក: លទ្ធផលបង្ក្រាបបទល្មើសជលផល (២០០៣-២០១៣)




ក្រាហ្វិក: ចំនួនស្រះសហគមន៍ជម្រកត្រី




ក្រាហ្វិក: បរិមាណផលវារីវប្បកម្មប្រចាំឆ្នាំ (តោន)

រៀបចំ បង្កើត ស្រះជម្រកត្រីសហគមន៍ បាន៧៧៨កន្លែង គិតរហូតដល់ចុងឆ្នាំ ២០១៣ នេះហើយដែលនៅខេត្តកំពង់ស្ពឺ មានចំនួនច្រើនជាងគេ រហូតដល់ ១៧៣កន្លែង។ សកម្មភាពនេះ ក៏បានធ្វើឱ្យផលត្រី តាមវាលស្រែ កើនឡើងប្រមាណពី៤ទៅ៦ដងផងដែរ។

### ច. ការអភិវឌ្ឍនវារីវប្បកម្ម

ការចិញ្ចឹមត្រី អនុវត្តបានចំនួនប្រមាណ៩០ពាន់តោន បើប្រៀបធៀបឆ្នាំកន្លងទៅកើន១៦ពាន់តោន។ កន្លែងភ្ញាស់ត្រី សរុបមានចំនួន៣០៥ កន្លែង ដែលក្នុងនោះមាន ២៩២ កន្លែង ជារបស់ប្រជាពលរដ្ឋ តាមរយៈការផ្តល់បច្ចេក-ទេសពីមន្ត្រី រដ្ឋបាលជលផល។ ផលិតកូនត្រី ពូជសរុបចំនួនប្រមាណ ១៥០ លាន ក្បាលកើនលើសឆ្នាំកន្លងទៅ ១០លានក្បាល ដែលក្នុងនោះមាន កូនបង្កង ប្រមាណ១លានក្បាល។ គួរគត់សម្គាល់ថា ប្រជាពលរដ្ឋ ប្រមាណ ៦១.០០០គ្រួសារ បានចូលរួមក្នុងសកម្មភាពចិញ្ចឹមត្រីតាមគ្រប់រូបភាពមានទាំងការចិញ្ចឹមត្រីក្នុងស្រែផងដែរ ដោយបានទទួលការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមត្រី ជាបន្តបន្ទាប់ ក្នុងនោះមានកសិករ១៥៤នាក់ ជាគ្រូបង្គោល និងជាគ្រូផ្សព្វផ្សាយនៅមូលដ្ឋាន។

### ឆ. ការអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃ និងគុណភាព

ជាការងារថ្មីដែលរដ្ឋបាលជលផលកំពុងពន្យល់និងផ្សព្វផ្សាយ ដើម្បីឱ្យគ្រប់កន្លែងផលិតនិងកែច្នៃត្រី គោរពទៅតាមស្តង់ដារអនាម័យឱ្យបានត្រឹមត្រូវ ក្នុងន័យធានាសុវត្ថិភាពសុខភាពសាធារណៈនិងទីផ្សារនាំចេញ ដោយរួមទាំងសកម្មភាពភូមិ១ផលិតផលជលផល១ដែលស្របទៅតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ សព្វថ្ងៃនេះដើម្បីធានាសុវត្ថិភាពម្ហូបអាហារនិងសុខភាពសាធារណៈ រដ្ឋបាលជលផលបានរៀបចំសមាគមអ្នកកែច្នៃត្រីបានចំនួន១៦សមាគម និងព្រាងស្តង់ដារត្រីងៀត ប្រហុក និងបង្គាបង្កករហ័សដាក់ជូនវិទ្យាស្ថានជាតិស្តង់ដារពិនិត្យហើយ ។




### ជ. ស្ថិតិផលនេសាទ និងផលវារីវប្បកម្ម

ផលត្រីសរុបក្នុងឆ្នាំ២០១៣ មានចំនួនប្រមាណ៧២៨ពាន់តោនកើនលើសឆ្នាំមុនចំនួន៤៦ពាន់តោន ក្នុងនោះមានៈ ផលនេសាទទឹកសាបជាង៥២៨ពាន់តោន ផលនេសាទសមុទ្រប្រមាណ១១០ពាន់តោន និងផលវារីវប្បកម្មប្រមាណ៩០ពាន់តោន។

### ឈ- ការងារគាំទ្រផ្សេងទៀត:

លទ្ធផលគួរជាទីពេញចិត្ត ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានាជាច្រើនក្នុងវិស័យជលផល និងកិច្ចខិតខំជាង១០ឆ្នាំមកនេះ ការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យជលផលមានការប្រែប្រួលរីកចម្រើនគួរឱ្យកត់សម្គាល់ ជាអាទិ៍ ក្រៅពីការកសាងហេដ្ឋារចនាសម្ព័ន្ធដូចជាវិទ្យាស្ថាន មជ្ឈមណ្ឌលស្រាវជ្រាវទាំងទឹកសាប ទឹកប្រៃ យើងបានខិតខំបង្កើតស្រះជម្រកត្រីសហគមន៍ចំនួន៧៧៨កន្លែង បង្កើត និងអភិ-វឌ្ឍសហគមន៍នេសាទចំនួន៥១៦សហគមន៍ បង្កើតធនាគារ ក្ដាមចំនួន៣២កន្លែងនៅតំបន់ឆ្នេរ ការចាត់វិធានការអភិរក្សធនធានជលផលរួមមានទាំងផ្កាថ្ម ស្មៅសមុទ្រ ព្រៃលិចទឹកនិងព្រៃកោងកាង ការរៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យជលផល (២០១០-២០១៩) ការបោះពុម្ពផ្សាយសៀវភៅ បច្ចេកទេស ប៉ាណូ ប៉ូស្ទ័របានជាច្រើនម៉ឺនច្បាប់។ល។ គួរគត់សម្គាល់ថាមន្ត្រីជំនាញរដ្ឋបាលជលផលធ្លាប់បានផ្ដល់ជាបទ ពិសោធន៍ផ្នែកវារីវប្បកម្មជាលក្ខណៈគ្រួសារទៅដល់ប្រទេសមួយចំនួនដូចជា ភូមា ឡាវ ម៉ាដាហ្គាស្ការ និងបេណាំង ព្រមទាំងបានទទួលនូវមន្ត្រីជំនាញនៃបណ្ដាប្រទេសទាំងនោះឱ្យមកបំពេញទស្សកិច្ចលើផ្នែកនេះផងដែរ។ រីឯបទពិសោធន៍ក្នុងការរៀបចំសហគមន៍នេសាទក៏ទទួលបាននូវការវាយតម្លៃជាវិជ្ជមាននិងជាបទពិសោធន៍គំរូសម្រាប់បណ្ដាប្រទេសអាស៊ានផងដែរ។



ប៉ុន្តែទោះជាធ្វើការងារបានយ៉ាងច្រើនក៏ដោយ ក៏នៅមានការងារជាច្រើនទៀតដែលត្រូវបំពេញជាបន្ទាន់ ដូចជាការទប់ ស្កាត់ទន្ទ្រានយកដីក្នុងដែននេសាទធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ ជាពិសេសការបង្ក្រាបបទល្មើសនេសាទ ដែលតែងតែកើតមានឡើងជាបន្តបន្ទាប់ ដែលទាមទារឱ្យមានការខិតខំប្រឹងប្រែងកាន់តែសកម្មដោយប្រើកម្លាំងសរុប មធ្យោបាយសរុបបន្ថែមទៀត។ជារួមសកម្មភាពក៏ដូចជាសមិទ្ធផលទាំងឡាយដែលសម្រេចបានជាផ្លែផ្កាដូចបានរៀបរាប់ ខាងលើនេះគឺពិតជាមិនអាចកាត់ផ្ដាច់បានពីទ្រឹស្ដីគន្លឹះ ដ៏ត្រចះត្រចង់ដែលមានចែងយ៉ាងច្បាស់ក្នុងយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណរបស់ រាជរដ្ឋាភិបាលនោះឡើយ។

## III. អនុសាសន៍គន្លឹះរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

នៅក្នុងឱកាស ទិវាមច្ឆជាតិ លើកទី១២ នៅស្រុកសាមគ្គីមានជ័យ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអំពាវជាថ្មីចំពោះប្រជាពលរដ្ឋនៅទូទាំងប្រទេសជាមួយនឹងអនុសាសន៍ចំនួន៧ចំណុច ដែលសម្ដេចធ្លាប់បានកាលពីឆ្នាំ២០១២ នៅខេត្តកំពង់ចាមអនុសាសន៍ជាការសំណូមពរនោះរួមមានៈ ទី១. សុំកុំប្រើឧបករណ៍ខុសច្បាប់ ជាពិសេសការប្រើឧបករណ៍ឆក់ត្រី។ ទី២. កុំចាប់ត្រីក្នុងរដូវហាមឃាត់គឺក្នុងរដូវត្រីពង។ ទី៣. សូមកុំកាប់ព្រៃលិចទឹក ដែលជាជម្រកត្រីពងកូន។ ទី៤. ជួយផ្ដល់ព័ត៌មានអំពីជនខិលខូច និងមន្ត្រីខិលខូច ដែលចូលទៅនេសាទ ឬពាក់ព័ន្ធក្នុងតំបន់អភិរក្ស។ ទី៥. កុំយកបឹង ព្រែក ប្រើប្រាស់ខុសគោលដៅនេសាទ ដូចជាយកទៅដាំឈូក និងចាក់ដីលុបជាដើម។ ទី៦. កុំឱ្យមានទំនាស់រវាងប្រជាពលរដ្ឋអ្នកនេសាទ និងអ្នកធ្វើស្រែប្រាំង ឬទំនាស់ដែនទឹកជាមួយប្រជាពលរដ្ឋដែលកធ្វើនេសាទនៅតំបន់របស់ខ្លួន គឺត្រូវចែកគ្នារស់ទាំងអស់គ្នា។ ទី៧.សូមចូលរួមឱ្យសកម្មក្នុងទិវាមច្ឆជាតិ១កក្កដា ជារៀងរាល់ឆ្នាំ ដែលជាទិវាជំរុញវារីវប្បកម្មឱ្យកាន់តែទូលំទូលាយ និងចូលរួមការពារត្រី និងជីវចម្រុះដែលជិតផុតពូជ។



សម្ដេចបានថ្លែងដោយសុទិដ្ឋិនិយម និងដោយមោទនភាពថា “ច្បាស់ណាស់ថា ប្រជាពលរដ្ឋបានទទួលផលប្រយោជន៍ពិតប្រាកដពីកំណែទម្រង់ឡូត៍នេសាទរបស់រាជរដ្ឋាភិបាល” ។ ដូច្នេះហើយ បានជាសម្ដេចផ្ទាល់ក្នុងនាមរាជរដ្ឋាភិបាលក្នុងនាមគណបក្សប្រជាជនកម្ពុជា ដែលជាបក្សកាន់អំណាច បានចាប់ផ្ដើមធ្វើកំណែទម្រង់ស៊ីជម្រៅ ផ្ដាច់ព្រ័ត្យដោយមិនរាថយចាប់ពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០១២ កន្លងទៅ ដោយលុបបំបាត់ចោលឡូត៍នេសាទទាំងអស់ មិនឱ្យពួកថៅកែគ្រប់គ្រងទៀតហើយឡូត៍នេសាទទាំងនោះ។





## IV.សេចក្ដីសន្និដ្ឋាន

សម្ដេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ទិវាមច្ឆជាតិ មិនធ្វើតែថ្ងៃទី១កក្កដា នោះទេ គឺត្រូវធ្វើនៅពេលវេលាជាច្រើន និងទីកន្លែងជាច្រើនទៀត ដើម្បីធ្វើឱ្យទន្លេ ស្ទឹង បឹងបួរ របស់កម្ពុជាសម្បូរទៅដោយត្រី។ សម្ដេចបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរួមទាំងឡាយក្នុងការអភិរក្សធនធានមច្ឆជាតិ និងផ្នែកវារីវប្បកម្មដោយហេតុថា បច្ចុប្បន្នប្រជាពលរដ្ឋកម្ពុជាកាន់តែមានចំនួនកើនឡើង។ ផ្ទុយទៅវិញ ផ្ទៃទឹកដែលជាជម្រកត្រីកាន់តែរួម និងរាក់ទៅៗ គួបផ្សំនឹងបញ្ហាបទល្មើសនេសាទការប្រើឧបករណ៍ខុសច្បាប់ទៀតនោះ បានធ្វើឱ្យផលត្រីថយចុះ មិនអាចបម្រើឱ្យរបបហូបចុករបស់ប្រជាពលរដ្ឋកម្ពុជាដែលមានទម្លាប់បរិភោគត្រីច្រើននោះ ដូច្នេះការចិញ្ចឹមត្រី និងវារីសត្វផ្សេងៗទៀតនោះ គឺជាកិច្ចការដែលចាំបាច់ត្រូវយកចិត្តទុក

ដាក់ធ្វើជាប្រចាំគ្រប់ពេលវេលា ដោយមិនមែនធ្វើតែក្នុងទិវាមច្ឆជាតិមួយថ្ងៃនោះទេ។

**សម្ដេចតេជោ** បានលើកឡើងថា ការថយចុះនៃផលត្រីពីមួយឆ្នាំទៅមួយឆ្នាំគឺកើតឡើងដោយកត្តាសត្យានុម័តផង និងកត្តាអន្ដនោម័តផង។ កត្តាសត្យានុម័ត គឺចំនួនប្រជាពលរដ្ឋមានចំនួនកើនឡើង ចំណែកបឹង ត្រពាំងទន្លេរបស់យើងកាន់តែរីងរាក់ទៅដោយសារតែបាតុភូមធម្មជាតិ ការហូរច្រោះដី និងការគោករាក់។ ក្នុងការថ្លែងនោះសម្ដេច ក៏បានស្នើឱ្យរដ្ឋបាលជលផល ត្រូវមានវិធានការក្នុងការស្ដារតំបន់មួយចំនួន ដែលត្រូវគោករាក់នៅក្នុងតំបន់អភិរក្សដែលកន្លងមកបានបង្កឱ្យត្រីងាប់រហូតដល់៩០តោន។ សម្ដេចបន្តពន្យល់ថា ចំពោះកត្តាអន្ដនោម័ត គឺបានបង្កឡើងដោយសារតែមនុស្សមួយចំនួនបានប្រើប្រាស់ឧបករណ៍ខុសច្បាប់ ធ្វើឱ្យផលត្រីត្រូវវិនាសហិនហោច។ ដូចជាការប្រើប្រាស់ខ្សែភ្លើងឆក់ និងការគប់គ្រាប់បែ និងឧបករណ៍ហាមឃាត់មួយចំនួនទៀតរាប់ទាំងការនេសាទនៅរដូវត្រីពងផង។





ក្រោយការកែទម្រង់ស៊ីជម្រៅវិស័យជលផលដំណាក់កាលទី២ រាជរដ្ឋាភិបាលបានសម្រេចលុបឡូត៍នេសាទទាំងអស់ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ និងធ្វើជាកន្លែងអភិរក្សជលផល។ ក្នុងស្ថានភាពនេះត្រូវបន្តអនុវត្តអនុសាសន៍ទាំង៧ចំណុចដែលបានដាក់ចេញកន្លងមក។ ទន្ទឹមនឹងនេះ ត្រូវបន្តរៀបចំបោះបង្គោលព្រំប្រទល់កន្លែងអភិរក្ស និងកន្លែងនេសាទគ្រួសារឱ្យបានច្បាស់លាស់ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិព្រមទាំងត្រូវពង្រឹងការបង្ក្រាបបទល្មើស និងការពារកន្លែងអភិរក្សជលផលឱ្យបានដាច់ខាត។ កាតព្វកិច្ចមួយទៀត ដែលមិនត្រូវមើលរំលង និងត្រូវអនុវត្តជាអចិន្ត្រៃយ៍ នោះ គឺការចូលរួមខានមិនបានពីអាជ្ញាធរថ្នាក់ក្រោមជាតិ គណៈបញ្ជាការឯកភាពខេត្ត ក្រុង ស្រុក និងកងកម្លាំងប្រដាប់អាវុធ រួមទាំងសហគមន៍នៅមូលដ្ឋាន ដើម្បីជួយទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលនិងថែរក្សាធនធានជលផល ទាំងទឹកសាប និងសមុទ្រឱ្យបានគង់វង្ស។



# បច្ចេកទេសដាំណាំមៀនប៉ៃលិន



សហការរៀបចំដោយៈ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម និងការិយាល័យផ្សព្វផ្សាយកសិកម្ម នៃមន្ទីរកសិកម្មខេត្តប៉ៃលិន

**បន្តពីលេខ ៥០**

ក្រោយពីរើសដើមពូជបានហើយ ត្រូវជ្រើសរើសមែកសាក នេះគឺជាកិច្ចការសំខាន់ដែលកន្លងមកកសិករខ្មែរយើងហាក់មិនសូវនឹកដល់ប៉ុន្មានទេ ទម្លាប់ដែលគាត់និយមធ្វើ គឺឱ្យតែគាត់សង្កេតឃើញមែកណាល្អមសាក ក៏សាកទាំងអស់ដោយមិនមានការជ្រើសមែកឡើយ ដែលទម្លាប់នេះអាចចាត់ទុកថា មិនត្រឹមត្រូវទេ ព្រោះថាដើមឈើមួយដើមៗ មែកមានការរីកលូតលាស់មិនដូចគ្នាទេ មែកខ្លះ រឹងមាំល្អ តែមែកខ្លះក្រេះក្រិន ទន់ជ្រាយ មែកខ្លះក៏ចាស់ហួសពេក បើមែកចាស់ហួសពេក មិនងាយចេញឫស ហើយឫសមិនសូវរឹងមាំ តែបើសិនជាមែកខ្ចីពេកក៏មិនចេញឫសដែរ ហើយពណ៌របស់មែកគួរមានពណ៌ត្នោត ជាមែកអើត មានជំហរត្រង់ ឬផ្អៀងបន្តិចក៏ប្រើបានទាំងអស់ ដើម្បីឱ្យឫសសំបូរកើនឡើងបានជុំវិញមែក បើសិនជាមែកសំយុងក៏ប្រើបាន តែការដុះចេញឫសនឹងដុះចេញតែខាងក្រោមម្ខាង មែកដែលត្រូវសាកប្រវែងប្រមាណ ៧៥ ដល់ ១០០ សង់ទីម៉ែត្រ មុខកាត់ ប្រមាណ ១,៥ ដល់ ២ សង់ទីមែត្រ។ ក្រៅពីនេះត្រូវតែជាមែកលូតលាស់ល្អ រឹងមាំ មិនមានមេរោគ និងសត្វល្អិតយាយី ។

**វិធីសាស្ត្រសាកមែក:** វិធីសាកមែកមៀន មានវីធីសាស្រ្ត និងដំណាក់កាលដូចតទៅ ៖

- ពេលរើសមែកបានតាមតម្រូវការហើយ ទើបគេក្រៀវមែកជាគន្លាក់ការក្រៀវមែកនោះត្រូវឱ្យមុខក្រៀវផ្អែកលើ មានស្នាមមុខត្រឹមស្នាមកាត់ក្រោមកន្លាក់មែកបន្តិច ព្រោះនៅបរិវេណរបស់កមែក មានការផ្សំសារធាតុចិញ្ចឹមទុកច្រើន ធ្វើឱ្យឫសមានដំណុះលឿន ហើយច្រើនផ្អែកខាងក្រោមឱ្យឃ្លាតពីស្នាមលើ ដោយលៃយ៉ាងណាឱ្យសមស្របជាមួយមែក ។
- ប្រើចុងកាំបិត ចិតយកសំបក ក្នុងចន្លោះស្នាមលាក់លើក្រោម ដោយចាប់ពីលើមកក្រោមតាមបណ្តោយមែក ពេលយកសំបកចេញហើយ ត្រូវកោសរំអិលកោសិកាឱ្យស្អាត ភាគច្រើនការក្រៀវមែកដែលកោសសំបកចេញបានងាយ ក៏ចេញឫសបានលឿនដែរ តែមែកណាដែលកោសសំបកលំបាកដោយប្រើមុខកាំបិត ត្រូវឆូតសាច់រំអិលដែលជាសាច់មានលក្ខណៈរំអិលៗ ជាពិសេសយកសសៃសំបកចេញឱ្យអស់ដើម្បីការពារមិនឱ្យកោសិកា មកទាក់ទងគ្នា តបានវិញដែលនាំឱ្យ ឫសមិនដុះ គេសង្កេតបានដោយប្រើដៃចាប់មើល បើបាត់អស់រំអិលហើយ បញ្ជាក់ថាស្អាតហើយ ។
- យកថង់ដែលច្រកស្រកីដូងរួច មកវះចំកណ្តាលដោយវះចេញពីមាត់ថង់ ដែលចង ចៀររហូតដល់គូទថង់ យកចុងកាំបិត វែកស្រកីដូង ឱ្យឃ្លាតចេញជាពីរចំណែក រួចយកទៅហ៊ុំ បិទមុខក្រៀវ ការហ៊ុំមុខក្រៀវនោះ ត្រូវហួសស្នាមមុខក្រៀវ ពិសេសមុខខាងចុងមែកយ៉ាងតិច១ ដល់ ២ ធ្នាប់ដៃក្រោយមកយកខ្សែចងចំក្បាល កន្ទុយ និងកណ្តាល ឱ្យណែនកុំឱ្យវិលបានដើម្បីការពារសត្វល្អិតដូចជាកណ្តៀរ ឬ តោកពោក ឬ ស្រមោច វារចូលទៅធ្វើសំបុកនៅបាន។ចំណុចសំខាន់មួយទៀតមុខថង់ដែលវះ ត្រូវឱ្យស្ថិតនៅពីលើ ដើម្បីកុំឱ្យទឹកក្នុងផង់ ហូរចេញនិងឱ្យទឹកភ្លៀងហូរចូលខ្លះ ពេលមានភ្លៀង ។

**ការកាត់មែកសាកមកផ្សាំ:** នៅរយៈពេល ៣០ ដល់ ៤០ ថ្ងៃក្រោយមក មែកសាកនឹងមានឫសដុះចេញមក មុនពេលកាត់មែកនោះមកផ្សាំ គេត្រូវសង្កេតមើលឫសដែលដុះចេញមក មានចំនួនច្រើន ឫសភាគច្រើនមានពណ៌លឿងចាស់ និងពណ៌សចេញមកទៀត ទើបកាត់បានព្រោះឫសពណ៌ស ជាឫសអំបោះដែលស្រូបសារធាតុចិញ្ចឹម ការកាត់មែកសាក គួរកាត់នៅពេលល្ងាចព្រោះរយៈពេលនោះ ស្លឹកឈប់ស្រូបទឹក មែកមិនងាយស្រពោន គួរកាត់ដោយកន្ត្រៃមុតការកាត់ឱ្យជិតដុំស្រកីដូងដែលហ៊ុំមែកសាកពីខាងក្រោម។

ក្រោយពីការកាត់ហើយ ត្រូវសង្កេតមើលថាតើមែកនោះ មានស្លឹកតិច ឬ ច្រើន បើមានច្រើនត្រូវកាត់ស្លឹកចេញខ្លះ

ដើម្បីបន្ថយការស្រូបទឹក និងការពារខ្យល់ផាត់ នាំឱ្យរង្គើឫស មិនចាប់ដីព្រោះ ឫសនៅមានចំនួនតិចស្រូបទឹក ទៅចិញ្ចឹមមែកមិនគ្រប់គ្រាន់ បន្ទាប់មក គេយកថង់ទៅត្រាំទឹកឱ្យជោគស្រកីដូង ប្រមាណពី១ ដល់ ២ ម៉ោង រួចហើយទើបយកទៅផ្សាំ ក្នុងថង់ខ្មៅ ឬដាំតែម្ដងក៏បាន តែវិធីដែលល្អបំផុត គឺគេត្រូវយកទៅផ្សាំក្នុងថង់ប្លាស្ទីក ពណ៌ខ្មៅ ទុកក្នុងម្លប់ ឬ សៃបណ្ដុះ រហូតតាំងជំហ៊របានហើយ ទើបយកទៅដាំក្នុងចម្ការ។

**ការផ្សាំមែកសាក:** ក្រោយពីយកមែកសាកទៅត្រាំទឹកទុកក្នុងរយៈពេល ១ ដល់ ២ ម៉ោងហើយ ត្រូវបកយកថង់ប្លាស្ទីកដែលរុំនោះចេញគួរធ្វើដោយការប្រុងប្រយ័ត្នពីព្រោះវាអាចធ្វើឱ្យឫសដាច់បាន បន្ទាប់មកទើបយកមែកសាកដាក់ថង់ប្លាស្ទីកទំហំ ៥ x ១០ សង់ទីម៉ែត្រ ដោយប្រើវត្ថុផ្សាំ អាចជ្រាបទឹក ហើយរក្សាសំណើមបានល្អ ភាគច្រើនគេប្រើចំណែកផ្សាំ មានដីជាមួយផេះអង្កាម ក្នុងអត្រា ដី ២ដង ផេះអង្កាម ១ដង តាមសមាមាត្រ រួចយកមែកសាក ដែលត្រូវផ្សាំរួចហើយទៅទុកក្នុងម្លប់ មានពន្លឺល្មម ឬក្នុងរោងបណ្ដុះផ្សាំហើយសន្សឹមៗ បើកឱ្យត្រូវពន្លឺថ្ងៃច្រើនឡើងៗ រហូតដល់ត្រូវថ្ងៃ ការស្រោចទឹកជាប់លាប់ ក្រោយពីផ្សាំមែក ទុកប្រមាណពី១ខែ ដល់ ២ខែ ឬពេលឃើញថា ដើមថ្មី តាំងខ្លួនបានរឹងមាំល្អ ទើបបន្តយកទៅដាំក្នុងចម្ការ។



**ការបណ្ដុះគ្រាប់:** ការបណ្ដុះគ្រាប់គឺជាវិធីនៃការពង្រីកពូជដំបូងដែលបុព្វបុរសបានពង្រីកតៗគ្នាមកគឺជាវិធីដែលកសិករបាននាំគ្នាធ្វើជាយូរមកហើយ តែក្នុងពេលបច្ចុប្បន្ននេះគេមិននិយមពង្រីកពូជមៀន ដោយការបណ្ដុះគ្រាប់ដើម្បីឱ្យបានដើមពូជទៅដាំនោះ ទេតែគេមាន គោលបំណងដើម្បីធ្វើជាដើមត សម្រាប់ការសៀតមែក ហើយតមែក ដើម្បីបន្ថែមឫសរបស់ដើម ឱ្យមានឫសកែវ ចំណុចល្អរបស់ការពង្រីកពូជដោយការបណ្ដុះគ្រាប់ គឺងាយធ្វើ ចំណាយតិចអាចពង្រីកម្ដងៗបានច្រើន ហើយលឿន ដំណាំមានអាយុវែង ពីព្រោះមានឫសកែវចាក់ចុះជ្រៅទៅក្នុងដី មិនងាយដួលរលំ ពេលខ្លះអាចទទួលបាន ពូជថ្មីៗ និងមានគុណសម្បត្តិលើសដើមចំណែកចំណុចមិនល្អ ក្នុងការពង្រីកពូជតាមវិធីនេះ គឺផ្ដល់ផលយឺត បានដើម និងទម្រង់ដើមធំខ្ពស់ ធ្វើឱ្យមានការលំបាកក្នុងការមើលថែដើម និងប្រមូលផល ផ្លែ ផ្កា ដែលបានមកនោះមិន សូវមានគុណភាព គឺ ផ្លែតូច សាច់តិច សាច់ជ្រាយជាំទឹកជាដើម ។

គ្រាប់ពូជមៀន ដែលយកមកបណ្ដុះ ទោះជាពូជអ្វីក៏បាន អាចជាពូជក្នុងស្រុក ឬពូជដទៃទៀតក៏បាន ពីព្រោះប្រើត្រឹមតែគល់តប៉ុណ្ណោះ តែគួរជ្រើសរើសគ្រាប់ ដែលមកពីដើមដែលមានការលូតលាស់ល្អ ថ្លោសរឹងមាំ ហើយមិនមានរោគគ្មានសត្វល្អិតយាយី គួរប្រើគ្រាប់មៀនដែលចាស់ល្អ ពីព្រោះផ្ទុកសារធាតុចិញ្ចឹមច្រើនជាធម្មតាគ្រាប់មៀនមិនមានការផ្ញើខ្លួនទេ ដូច្នេះផ្លែចាស់ ពេលយកមកបកសាច់ចេញហើយ គួរប្រញាប់ធ្វើការបណ្ដុះជាបន្ទាន់ បើសិនជារក្សាទុកយូរ នឹងបាត់បង់សារធាតុចិញ្ចឹម នាំឱ្យដុះមិនល្អ។ ការសិក្សា ការទុកដាក់គ្រាប់ពូជបានឱ្យឃើញថា គ្រាប់ដែលប្រឡេះចេញពីផ្លែហើយ បើទុកក្នុងបន្ទប់ដែលមានសីតុណ្ហភាពទាបត្រឹម១០ថ្ងៃ គ្រាប់មៀន នោះដុះតិចបំផុត ឬស្ទើរតែមិនដុះសោះឡើយ វិធីសាស្រ្ត រក្សាទុកគ្រាប់មៀនបានយូរ គួររក្សាទុកទាំងផ្លែដោយត្រាំក្នុងទឹកថ្នាំការពាររោគ ក្រុមបេនណូមីល កំហាប់ ០.០៥ ក្នុងទឹក១លីត រយៈពេល៥នាទី ក៏អាចរក្សាទុកយូរ ដល់៣០ថ្ងៃ ដែលមានភាគរយដុះ ៨៥% ។

វិធីសាស្រ្តបណ្ដុះគ្រាប់មៀន អាចធ្វើការបណ្ដុះក្នុងថង់ប្លាស្ទីកតែម្ដង ឬបណ្ដុះក្នុងកេសរឈើក៏បាន ដោយប្រើផេះអង្កាមចាស់ៗ ឬ ដីលាយខ្សាច់ គ្រាប់គួរកប់ជម្រៅប្រមាណកន្លះស.មស្រោចទឹកឱ្យសើមជានិច្ច ក្រោយពីបណ្ដុះពីរសប្ដាហ៍គ្រាប់ក៏ចាប់ផ្ដើមដុះ រួចនាំយកទៅទុកក្នុងរោងបណ្ដុះ ផ្សាំ ឬកន្លែងម្លប់ ថែទាំបន្តទៀតប្រមាណ ៨ ដល់ ១២ខែ ទើបនាំយកទៅដាំដុះ តាមតម្រូវការ ដូចជាប្រើជាដើមមេ ឬដើមត

ក៏បាន ។

**ការតមែក :** ( Grafting ) ជាវិធីសាស្ត្រពង្រីកពូជមៀន ដែលផ្ដើមនិយមច្រើនឡើង តែត្រូវអាស្រ័យភាពចំណានល្មមគួរសម ពីព្រោះការដាំមៀនពេលបច្ចុប្បន្ននេះ កសិករអ្នកចម្ការនិយមដាំ ដោយមែកសាកធ្វើឱ្យកើតមានបញ្ហា ការដួលរលំដោយសារព្យុះ ទាំងនេះដោយសារប្រព័ន្ធឫសមៀន ដែលបានពីសាកមែក ជាប្រព័ន្ធគ្មាន ឫសកែវ ពិសេសគឺ មានប្រព័ន្ធឫសរយាងអំបោះ គេសង្កេតឃើញថាឫសរបស់មៀន មានចំនួនតិច ហើយស្ថិតក្នុង លំដាប់រាក់ៗព្រមជាមួយមៀន មានស្លឹកស្តុក ហើយធំក្នុងឆ្នាំដែលមានផ្លែច្រើន ពេលខ្យល់ខ្លាំង ឬព្យុះដួលរលំយ៉ាងច្រើនក្នុងមួយឆ្នាំៗ វិធីសាស្ត្រ ដោះស្រាយបញ្ហានេះបាន មានតែវិធីមួយគឺៈ ការដាំមៀនដោយមែកពូជ ដែលបានពីការពង្រីកពូជ ដោយវិធីតមែក ដែលមានប្រព័ន្ធឫសកែវ ក្រៅពីនេះ ការតមែក នៅមានប្រយោជន៍លើការសិក្សាស្ដីពីដើមត ដែលមានមែកតពូជល្អដូចជា អាចមានផ្ដល់ផលល្អ ទំហំ ទម្រង់ដើម និងគុណភាពរបស់ផ្លែមៀន ។ រដូវដែលសមស្របក្នុងការតមែកមៀន អាចធ្វើបានល្អគ្រប់រដូវកាល ។

សម្រាប់ដំណាក់កាលពង្រីកពូជមៀនដោយវិធីតមាន ដូចតទៅ ៖

- ត្រៀមឧបករណ៍ផ្សេងៗ ទុកជាស្រេចដូចជាកាំបិតភ្ជាប់មែក ស្តុត ឬ ខ្សែនិងថង់ប្លាស្ទីក
- ត្រៀមដើមត ដែលនឹងត្រូវតមែកបានមកពីការបណ្ដុះគ្រាប់ ដើម្បីត គួរមានអាយុយ៉ាងតិច ១ឆ្នាំ ឬមានអង្កត់ផ្ចិតរបស់ដើម ប្រមាណកន្លះទៅមួយសង់ទីម៉ែត្រ ឬទំហំប៉ុនបិច។
- ត្រៀមចុងពូជល្អ ពូជល្អគួរបានមកពីដើម ដែលមានការលូតលាស់ល្អ ចេញផ្កា ផ្លែលឿនផ្ដល់ផលញឹកជានិច្ច ធានាបានពីការរាតត្បាត ពីមេរោគ ចុងពូជល្អគួរមានប្រវែង ១០ ដល់១៥ សង់ទីម៉ែត្រ អង្កត់ផ្ចិត ប្រហាក់ប្រហែលគ្នា ជាមួយទំហំរបស់ដើមត បូតស្លឹកចេញឱ្យសល់ស្លឹកត្រឹម ២ ទៅ ៣ សន្លឹក រួមមានសន្លឹករាយ ២ ដល់ ៣គូរ ។
- កាត់ចុងដើមតឱ្យផុតពីដីក្នុងថង់ប្លាស្ទីក ប្រមាណ ១០-១៥ សង់ទីម៉ែត្រ ហើយប្រើកាំបិតមុតៗពុះកណ្ដាល ដើមតចុះត្រង់ទៅក្រោម ជម្រៅប្រមាណ ២-៣ សង់ទីម៉ែត្រ ហើយចិតគល់មែកពូជដែលល្អ ឱ្យមានរាងស្រួចចុង សំប៉ែត ដោយឱ្យស្នាមផែនទាំងសងខាងប្រវែងស្មើគ្នា ប្រមាណ២-៣ស.ម ហើយព្យាយាមចិតផែនមានរាងរៀបស្មើ ។
- បើកស្នាមពុះលើដើមតចេញ ហើយសៀតត្រួយចុងពូជល្អជាមួយដើមតឱ្យត្រង់គ្នាទាំងសងខាង ឬ ផ្នែកណា ដែលរឹង ហើយរុំដោយប្លាស្ទីកឱ្យណែន ។
- នាំយកទៅដាក់ក្នុងថង់ប្លាស្ទីក ទំហំធំឬប្រើថង់ប្លាស្ទីកគ្រប ហើយក្របួចមាត់ថង់រួចហើយចងឱ្យណែនដើម្បីការការពារ ការបាត់បង់ទឹក របស់មែកពូជល្អ ក្រោយមកគ្របដើមពូជដោយថង់ប្លាស្ទីក ហើយយកទៅរក្សាទុកក្នុងម្លប់ រោងផ្សាំ ។
- ក្រោយពីតមែកប្រមាណ៤០-៥០ថ្ងៃត្រួយមែកពូជក៏លូតឡើងទើបយកថង់ប្លាស្ទីកដែលគ្របចេញ ហើយយកទៅចិញ្ចឹមទុកក្នុងរោងបណ្ដុះផ្សាំ រហូតដល់ដើមលូតលាស់រឹងមាំហើយ ទើបយកទៅដាំក្នុងចម្ការ ឬលក់ដូរបានកសិករពិបាកបង្គាប់បញ្ជារ ឱ្យផ្លែខុសរដូវ មិនដូចមែកសាកទេ។



### ៥-៣. ការជ្រើសរើសដីដាំមៀនៈ

ផ្ទៃដីដាំហើយ និងស្ថានភាពបរិស្ថាន មានឥទ្ធិពលដល់ការរីកលូតលាស់របស់ដើម និងគុណភាពរបស់ផ្លែ ផ្កាមៀនយ៉ាងច្រើន បច្ចុប្បន្នថ្មីបើមៀនអាចដាំបានស្ទើរគ្រប់កន្លែងក៏ដោយ តែផ្ដល់ផលផ្សេងៗគ្នា ទាំងនេះក៏ជាកត្តាប្លែកគ្នា ទៅតាមសភាពផ្ទៃដី ហើយនឹងស្ថានភាពបរិស្ថាន និងទីកន្លែងនីមួយៗសម្រាប់ការធ្វើចម្ការមៀន ដើម្បីផលប្រយោជន៍ ផ្នែកអាជីវកម្ម គួរដាំលើផ្ទៃដី ដែលមានអាកាសធាតុសមស្រប បើផ្ទៃដីដាំ និងបរិស្ថានសមស្របអាចឱ្យដំណាំមៀនរីកលូតលាស់

បានល្អ ផ្ដល់ទិន្នផលខ្ពស់ ផលិតផលមានគុណភាពល្អ ។ដូច្នេះ មុនដាំមៀនត្រូវ ពិចារណាជ្រើសរើសដី និងសភាពបរិស្ថាន ដូចជា ៖

**ដីៈ** មៀនអាចលូតលាស់បានល្អសម្រាប់ដីស្ទើរគ្រប់ប្រភេទ តែដីដែលសមស្របជាមួយការដាំមៀន គឺដីដែលមានជីជាតិខ្ពស់ និងមធ្យមក្រៅពីដីដែលមានជាតិរ៉ែ អាចផ្ដល់សារធាតុចិញ្ចឹមដែលចាំបាច់ដល់ការលូតលាស់ ព្រមទាំងចេញផ្កា កាន់ផ្លែរបស់មៀន អាចដាំបានទាំងដីក្រហមលឿង ខ្មៅប្រផេះដែលជាដីកណ្ដោង ដីល្បាយខ្សាច់ ដីកណ្ដោងលាយស្អិត អាចជ្រាបទឹកបានល្អ ឬ ដីល្បាយឥដ្ឋ ដីល្បាប់មាត់ទន្លេ ជាដីដែលមានកម្រាស់ដីជ្រៅ កើតពីល្បាប់ ហូរពូនពីកករដី ដែលបានពីទឹកជំនន់របស់ទន្លេ ដីប្រភេទនេះស្ថិតនៅបរិវេណទន្លេខ្សែធំៗដូចជា ទន្លេមេគង្គ ទន្លេសេសាន ស្រែពក និង ព្រែកឆ្លូង ជាដើម ។

យើងសង្កេតឃើញថា បរិវេណដីដែលមានប្រភពទឹកដូចបានអធិប្បាយទាំងអស់នេះ អាចដាំមៀនបានផលល្អ ស្ទើរតែមិនប្រើជីរក៏បាន ក្រៅពីនេះ ដីដែលសមស្របជាមួយដំណាំមៀន ស្រទាប់ដីគួរមានជម្រៅជ្រៅ ហើយមាន កម្រិត PH សមស្រប ប្រមាណ ៥.០-៧.៥ ប្រការដែលសំខាន់ គឺដីជ្រាបទឹកបានល្អ បើមិនដូច្នេះទេ ផ្ទៃដីដែលដាំមៀននោះ ត្រូវមានកម្ពស់ខ្ពស់ល្មម ដើម្បីជ្រៀបទឹកបានល្អ ។

**ទឹកៈ** ទឹកជាធាតុចាំបាច់សម្រាប់ដំណាំមៀន ពីព្រោះទឹកជាបច្ច័យកំណត់ការលូតលាស់ និងភាពធំធាត់របស់ដើមមៀន ជាពិសេសក្នុងចន្លោះពេលដែលដើមនៅតូច ឬក្រោយពេលដាំថ្មីៗ បើសិនជាមៀនបានទទួលទឹកគ្រប់គ្រាន់ ទាំងទឹកភ្លៀង និងបឹង ស្ទឹង ទន្លេ ។ល។ធ្វើឱ្យដើមមៀន លូតលាស់ល្អជានិច្ច មិនបង្អាក់ការលូតលាស់ លូតលាស់ល្អ ហើយរឹងមាំ មិនមានការរំខានពីមេរោគ ធំលឿនជាងការដាំ ដោយអាស្រ័យលើទឹកភ្លៀង តែមួយមុខ បើសិនដើមមៀនខ្វះទឹកក្នុងចន្លោះពេល កំពុងលូតលាស់ មៀននឹងអន់ ក្រេះក្រិន ឬ អាចងាប់បាន។ មៀនជារុក្ខជាតិត្រូវការទឹក តែមិនជោគជាំពេកទេ ក្នុងតំបន់ដែលគ្មានប្រភពទឹក មៀនត្រូវការបរិមាណទឹកភ្លៀងសមស្រប គឺប្រមាណពី ១២០០ ដល់ ១៤០០ មីលីលីត្រ ឬក្នុងកម្រិត ពី១០០ ដល់ ១៥០ថ្ងៃក្នុង១ឆ្នាំ បើសិនជាផ្ទៃដីណាដែលមានចំនួនទឹកភ្លៀងតិចជាងនេះ ត្រូវមានការផ្ដល់ទឹកជំនួស តែទោះជាយ៉ាងណាក៏ដោយ ក្នុងចន្លោះពេលខ្លះ មៀនត្រូវការទឹកតិចបំផុត គឺចន្លោះមុនចេញផ្កា បើផ្ដល់ទឹកច្រើនក្នុងចន្លោះពេលនេះ ធ្វើឱ្យពន្លកផ្កា បរិមាណពន្លកត្រួយ លូតលាស់ក្លាយជាស្លឹកខ្ចី បើមៀនចេញផ្កា កាន់ផ្លែរួចហើយ ទើបត្រូវការទឹកច្រើន ជាពិសេសក្នុងចន្លោះក្រោយចេញផ្កា និងកាន់ក្ដិបក្នុងខែមករា ដល់ ខែមេសាពីព្រោះរយៈពេលដែល






កាន់ក្ដិបនេះ ចាំបាច់ត្រូវផ្ដល់ជីដល់ដីផង ដូច្នេះ ដីត្រូវមានសំណើមគ្រប់គ្រាន់ដើម្បី រលាយជីផ្ដល់ឱ្យ ឫសបានបឺតស្រូបចូលទៅដល់ដើមនឹងទៅដល់ស្លឹក ហើយឆ្លងកាត់ការធ្វើរស្មីសំយោគរួចបញ្ជូនសារធាតុចិញ្ចឹមទៅដល់ផ្លែខ្ចីបាន។ បន្ទាប់ពីនេះក៏អាស្រ័យលើទឹកភ្លៀង តាំងពីខែ ឧសភា ដល់ ខែកក្កដា ហើយនឹងខែសីហា ដែលជារយៈពេល ប្រមូលផល ។

**សីតុណ្ហភាព:** ចាត់ទុកជាបច្ច័យដែលមានសារៈសំខាន់ដល់ការលូតលាស់ ហើយនឹងចេញផ្ការបស់មៀន ជាទូទៅសីតុណ្ហភាពដែលសមស្រប សម្រាប់ការរីកលូតលាស់របស់ដំណាំមៀនស្ថិតក្នុងចន្លោះពី ២០ ទៅ ២៥ អង្សាសេ ក្នុងចន្លោះពេលមុនចេញផ្កា មៀនត្រូវការសីតុណ្ហភាពត្រជាក់ខ្លាំង ក្នុងចន្លោះពី១០ ទៅ ១៥ អង្សាសេ ដើម្បីជួយជំរុញឱ្យកើតពន្លកផ្កា ក្នុងរយៈពេល១ ទៅ ២ ខែ(វិច្ឆិកា-ធ្នូ) អាកាសធាតុកាន់តែត្រជាក់ មៀនចេញផ្កា និងកាន់ផ្លែបានកាន់តែច្រើនសង្កេតឃើញថា បើឆ្នាំណាអាកាសធាតុត្រជាក់យូរ ដោយមិនមានអាកាសធាតុក្ដៅជ្រៀតចូលមៀនអាចចេញផ្កា និងកាន់ផ្លែបានល្អ តែបើដាំមៀនដោយការប្រើសាធាតុ បញ្ឆាឱ្យចេញផ្កាក៏មិនចាំបាច់អាស្រ័យលើភាពត្រជាក់ក៏បាន។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចន្លោះមុនពេលចេញផ្កា យើងតែងកត់សម្គាល់ឃើញថាសីតុណ្ហភាពឡើងខ្ពស់ ក្នុងអំឡុងពេលអាកាសធាតុត្រជាក់ ហើយនឹងមានភ្លៀងធ្លាក់មកក្នុងរដូវនេះផងដែរ ធ្វើឱ្យមៀនជ្រុះស្លឹកខ្ចីយ៉ាងច្រើន បើសិនមិនមានការបំផ្លាញស្លឹកខ្ចីទាំងអស់នេះចោលទេ ស្លឹកទាំងនោះចាស់មិនបាន និងមិនចេញផ្កាក្នុងឆ្នាំនោះដែរ ធ្វើឱ្យមៀនអាក់ខានផ្លែ១ឆ្នាំ ។ ពេលមៀនកាន់ផ្លែហើយ ទោះបីសីតុណ្ហភាពឡើងខ្ពស់ ក៏មិនជាអ្វីដែរ តែមិនគួរឡើងខ្ពស់ហួសដល់៤០អង្សាសេដែរ ការឡើងកម្ដៅដល់កម្រិតនេះអាចធ្វើឱ្យផ្លែស្ងួតក្រៀម ហើយបែកបាន ។

**ពន្លឺ :** មៀនជាឈើហូបផ្លែដែលត្រូវការពន្លឺថ្ងៃគ្រប់ពេលវេលា ដើម្បីប្រើក្នុងការសំយោគសារធាតុចិញ្ចឹម។ ជាទូទៅ ប្រទេសកម្ពុជា និងប្រទេសជិតខាង គេប្រទះឃើញស្ទើរគ្រប់ភូមិភាគ ការសំយោគរបស់ពន្លឺដែល រុក្ខជាតិត្រូវប្រើជាប្រយោជន៍ ក្នុងការធ្វើរស្មីសំយោគ សម្រាប់ការរីកលូតលាស់ តែការដាំមៀនដែលសមស្រប គួរដាំក្នុងផ្ទៃដីដែលមានពន្លឺគ្រប់គ្រាន់ បើសិនជានៅក្នុងម្លប់ ឬស្អុកគ្មាន ពន្លឺ និងធ្វើឱ្យមៀនបែកទងផ្កាតិច ធ្វើឱ្យថយចុះនូវទិន្នផល។

## ៥.៤ ការត្រៀមដីដាំ:

ក្រោយពីការជ្រើសរើសផ្ទៃដីដាំហើយ ដំណាក់កាលបន្ត គឺការត្រៀមផ្ទៃដីសម្រាប់ដាំជាកត្តាសំខាន់បំផុត ផ្ទៃដីដែលកសិករជ្រើសរើសទុកសម្រាប់ធ្វើចម្ការមៀន អាចមានលក្ខណៈផ្សេងៗពីគ្នា កន្លែងខ្លះជាផ្ទៃដីរាប កន្លែងខ្លះអាចជាផ្ទៃដីខ្ពង់រាប ឬទួលភ្នំ ហើយកន្លែងខ្លះអាចជាដីស្ទើរស្រែតែជាទូទៅ សភាពផ្ទៃដីដែលប្រើ ក្នុងការដាំមៀន ចែកចេញជាពីរប្រភេទគឺ ផ្ទៃដីទំនាបហើយនិងផ្ទៃដីខ្ពង់រាប ដូចនេះវិធីត្រៀមផ្ទៃដី ទាំងពីរប្រភេទនេះមានការខុសប្លែកគ្នាដូចតទៅ ៖

**ការត្រៀមផ្ទៃដីក្នុងតំបន់ទំនាប:** ផ្ទៃដីទំនាប ភាគច្រើនជាផ្ទៃដីទំនាបមាត់ទន្លេ ឬដីដែលបានផ្លាស់ប្ដូរពីផ្ទៃដីស្រែ មកជាចម្ការមៀនវិញ លក្ខណៈផ្ទៃដីទាំងនេះនិងមានទឹកជំនន់ដក់ក្នុងចន្លោះពេលមានភ្លៀងធ្លាក់ សភាពដីជាដីស្អិតមានលំដាប់ទឹកក្រោមដីខ្ពស់ការត្រៀមផ្ទៃដី ដោយការជីកប្រឡាយ ហើយយកដីមកបន្ថែមឱ្យទៅជាកន្លែងខ្ពស់ ដើម្បីជាការបញ្ចៀញទឹកមិនឱ្យដក់ត្រូវដើម ពីព្រោះមៀនមិនត្រូវការដីជាំទឹកទេ ក្រៅពីនេះយើងអាចប្រើទឹកពីប្រឡាយ បញ្ចៀញទឹកមកស្រោចស្រពនៅរដូវរាំងស្ងួត ហើយកន្លែងដាំគួរមានចម្ងាយប្រមាណពី ៧-៨ ម៉ែត្រ ប្រឡាយទឹករវាងពីជួរមួយទៅជួរមួយមានប្រវែងពី ១-២ ម៉ែត្រ ជម្រៅពី១ ទៅ ១.៥ម៉ែត្រ ឬជីកប្រឡាយទឹកតាមសេចក្ដីត្រូវការ (សមស្រប) ដោយពិចារណា ពីភាពខ្ពស់ ទាបរបស់ផ្ទៃដី ចំណែកប្រវែងចម្ការដែលត្រូវដាំគឺទៅតាមទំហំផ្ទៃដី និងសេចក្ដីត្រូវការរបស់កសិករ ក្រោយពីជីករួចហើយ គួរទុកឱ្យដីស្រុត មួយរយៈទើបធ្វើការដាំ ។

**ការត្រៀមផ្ទៃដីក្នុងតំបន់ខ្ពង់រាប:** ជាលក្ខណៈផ្ទៃដីមិនមានទឹកជន់ដល់ដូចជា: ផ្ទៃដីចម្ការទើបរានថ្មី ឬផ្ទៃដីដាំដំណាំចម្ការពីមុន ការត្រៀមផ្ទៃដី ដោយការយកគល់ឈើចេញ ឬពង្រាបផ្ទៃដីឱ្យម៉ត់ ហើយភ្ជួររាស់ដី ឬសំអាតស្មៅឱ្យបានស្អាត។ ការត្រៀមផ្ទៃដីនៅក្នុងតំបន់ខ្ពង់រាប ដើម្បីធ្វើចម្ការមៀន ត្រូវពិចារណាដល់បច្ច័យការផ្ដល់ទឹកដល់ដើមមៀនផងដែរ គួររៀបចំដាក់ផែនការ ហើយចាត់ត្រៀមប្រភពទឹក ឱ្យរួចជាស្រេចសម្រាប់ពេលអនាគត ព្រមទាំងដាំដំណាំ ជារបាំងខ្យល់ផងដោយសារផ្ទៃដីខ្ពង់រាប ភាគច្រើនខ្យល់បក់ខ្លាំង ជាពិសេសផ្ទៃដីតំបន់ជើងភ្នំ បើមិនមានការការពារទុកជាមុន អាចធ្វើឱ្យដើមមៀនជួបប្រទះ នឹងការដួលរលំខូចខាត ក្រៅពីនេះនៅចន្លោះរដូវរាំងស្ងួត គួរធ្វើផ្លូវការពារភ្លើងទុកជុំវិញចម្ការ ដើម្បី

ការពារផលប៉ះពាល់ពីភ្លើងព្រៃផង។

### ៥-៥. គម្លាតចម្ងាយដើម្បីដាំ:

ចន្លោះចម្ងាយដាំ ជាបច្ច័យមួយ ដែលអាចកំណត់ទិន្នផលច្រើន ឬតិច ការដាំមៀននៅផ្ទៃដីទំនាប និងផ្ទៃដីខ្ពង់រាប គួរដាំឱ្យមានជួរ ទៅតាមក្បួនខ្នាតកំណត់ ទាំងនេះដើម្បីងាយស្រួលក្នុងការមើលថែទាំ និងអនុវត្តការងារផ្សេងៗនៅក្នុងចម្ការ គួរដាំឱ្យមានចម្ងាយជួរ និងដើមដែលសមស្រប បើដាំជិតពេកធ្វើឱ្យទម្រង់ម្លប់ជល់គ្នា និងធ្វើឱ្យពន្លឺថ្ងៃមិនមានលទ្ធភាពចាំងចូលដល់ដំណាំមៀន ជាហេតុធ្វើឱ្យមេរោគមានឱកាសបំផ្លាញផ្កា និងផ្លែបាន បើដាំឃ្លាតគ្នាពេកធ្វើឱ្យបានចំនួនដើមតិច ការផ្តល់ផ្លែ ផ្កាទាប និងដីនៅទំនេរតតប្រយោជន៍ច្រើន ការស្មានចម្ងាយដាំជាការកំណត់រណ្ដៅដាំ ឬកំណត់ចំនួនដើមត្រូវដាំការដាំមៀនក្នុងផ្ទៃដីទំនាប ឬបែបលើករងដាំចម្ងាយដាំអាចញឹកជាងការដាំលើផ្ទៃដីខ្ពង់រាប ។ ទោះយ៉ាងណាក៏ដោយ ក្នុងការកំណត់ចម្ងាយដាំមៀនតែមួយផ្នែកមិនអាចកំណត់កត្តាទិន្នផលបានដែរ បើសិនជាមិនមានការរួមចំណែកពីកត្តាមួយចំនួនដូចខាងក្រោម៖

**ជីជាតិដី:** ក្នុងការកំណត់ចម្ងាយរបស់ជួរ និងចម្ងាយរបស់ដើម ឬការកំណត់រយៈពេលដាំក៏អាស្រ័យទៅតាមលទ្ធភាពរបស់ដី មានន័យថាបើដីអន់ដាំញឹក ដីល្អដាំរង្វើល ជាធម្មតា បើដីមានជីជាតិស្តុកស្តម្ភ ដើមមៀនមានទំហំធំ ការរីករបស់ ឬសល្អជាងការដាំនៅលើដីដែលមិនសូវមានជីជាតិ ធ្វើឱ្យការធ្វើស្មើសំយោគសារធាតុចិញ្ចឹមមិនងាយស្រួល អាចប៉ះពាល់ទៅដល់បរិមាណនិងគុណភាពទិន្នផល ដែលទទួលបាន ក្រៅពីនេះបើជាផ្ទៃដីទំនាប លំដាប់ទឹកក្រោមដីខ្ពស់ការបញ្ចេញទឹកមិនសូវល្អ ការដុះក្នុងសភាពដូចនេះមានអាយុមិនវែង ។

**ទំហំម្លប់មែក:** ទម្រង់មែកត្រូវគិតដល់ពេលមៀនលូតលាស់ធំធាត់ពេញទី ហើយទម្រង់ម្លប់មែក និងមានទំហំប៉ុណ្ណា ទាំងនេះដើម្បីការពារទម្រង់ម្លប់មែកជល់គ្នា ពីព្រោះការចេញផ្កា កាន់ផ្លែរបស់មៀន មានការចេញផ្កា កាន់ផ្លែ នៅបរិវេណខាងចុងមែក ទើបត្រូវការពារការដណ្តើមពន្លឺគ្នា បើទម្រង់មែកដល់គ្នាធ្វើឱ្យបរិវេណនោះ មិនសូវចេញផ្កាហើយលូតលាស់ទៅតែផ្នែកកម្ពស់ធ្វើឱ្យដើមខ្ពស់លំបាកដល់ការបេះ ប្រមូលផលមៀន ។

**ពូជ:** ដោយសារពូជមៀននីមួយៗ មានការលូតលាស់ខុសប្លែកពីគ្នា បើសិនជាពូជណាមានទំហំទម្រង់ម្លប់មែកធំចម្ងាយនៃការគួរដាំរង្វើល ពូជដែលមានទម្រង់ដើមខ្ពស់ដូចជាពូជស៊ីជំពូជាដើម ។

**ការរៀបចម្ការប្រត្តិបត្តិ:** ក្នុងករណីដាំមៀនចម្ងាយជិតត្រូវមានការចាត់ចែងដីដូចជាការ កាត់តែងមែក ដើម្បីគ្រប់គ្រងទម្រង់ដើម ឬកាត់តែងតាមបរិវេណរបស់ដើមពេលទម្រង់ស្លឹកដល់គ្នាដើម្បីឱ្យមៀនចេញផ្កា កាន់ផ្លែបានច្រើន ចម្ងាយសមស្របរបស់មៀនជាធម្មតារវាងពី ៨ ដល់១២ និងពី១០ ដល់១២ ម៉ែត្រ តែបើត្រូវប្រើប្រយោជន៍ ពីផ្ទៃដីឱ្យបានច្រើន គួរដាំក្នុងចម្ងាយជិតដែលមានដូចជា ដាំ ៤ម x ៤ម ឬ ៥ម x ៥ម ឬ ៦ម x ៦ម មៀននឹងផ្តើមផ្តល់ផលក្នុងឆ្នាំទី៣ ទី៤ដូច្នេះការដាំចម្ងាយជិតនឹងផ្តល់ផលក្នុងមួយរ៉ៃ បានខ្ពស់ ក្នុងរយៈពេលដំបូង ហើយពេលទម្រង់ដើមជលគ្នាត្រូវកាត់ដើម មួយចន្លោះ និងបានចម្ងាយពី ៨ x ៨ម៉ែត្រ និង ១០ x ១០ម៉ែត្រ ឬ១២ x ១២ម៉ែត្រ តាមលំដាប់ ។

### ៥-៦. ការត្រៀមរណ្តៅដាំ:

ការត្រៀមរណ្តៅដាំគឺជាកិច្ចការជួយជំរុញដល់ការរីកលូតលាស់ របស់ដើមមៀន នៅក្នុងរយៈពេលដំបូង បើសិនការត្រៀមរណ្តៅដាំមិនបានត្រឹមត្រូវ ពេលយកដើមពូជមកដាំអាចធ្វើឱ្យដើមពូជងាប់ច្រើន ព្រោះរណ្តៅរក្សាទុកសំណើមមិនគ្រប់គ្រាន់ ដល់សេចក្តីត្រូវការរបស់មែកពូជ ទំហំរបស់រណ្តៅសម្រាប់ការដាំក្នុងផ្ទៃដីទំនាប បើសិនការកែប្រែលើដីចម្ការល្អ សមល្មម ទំហំរបស់រណ្តៅដាំក៏មិនចំបាច់ធំពេកទេ គឺបណ្តោយ ទទឹង និងជម្រៅប្រមាណ ៥០សង់ទីម៉ែត្រ តែបើការត្រៀមដីមិនសូវល្អ គួរជីករណ្តៅឱ្យមានទំហំធំជាងនេះ ដើម្បីបានកែប្រែដីក្នុងរណ្តៅឱ្យល្អឡើង ផ្នែកជម្រៅរបស់រណ្តៅដាំក្នុងផ្ទៃដីទំនាប ត្រូវមើលតាមលំដាប់ជម្រៅទឹកក្រោមដីផង មិនមានការចាំបាច់ណា ដែលត្រូវជីករណ្តៅដាំឱ្យជ្រៅជាង លំដាប់ទឹកក្រោមដីទេ ដោយសារលំដាប់ទឹកក្រោមដីដែលជាមូលដ្ឋានកំណត់ នៃការលូតលាស់របស់ឫស ពេលគឺឫសមិនអាចលូតលាស់ឆ្លងលំដាប់ទឹកក្រោមដីបានទេ ពេលឫសលូតលាស់មកដល់លំដាប់ទឹកក្រោមដី ឫសពង្រីកពង្រាយទៅផ្នែកខាង មិនជ្រៅតទៅទៀត ។ សម្រាប់លំដាប់ទឹកក្រោមដីអាចប្រមាណបានពីលំដាប់ទឹកខ្ពស់បំផុតក្នុងប្រឡាយ ទឹកក្នុងចម្ការ ឬសាកល្បងជីករណ្តៅឱ្យជ្រៅ ហើយទុកចោល ១ ដល់ ២ថ្ងៃ មិនមានទឹកជ្រាបចូលមកក្នុងរណ្តៅ លំដាប់ទឹកនោះហើយដែលជាលំដាប់ទឹកក្រោមដី ។ ចំណែកទំហំរបស់

រណ្តៅ សម្រាប់ការដាំក្នុងផ្ទៃដីខ្ពង់រាបវិញ ជាទូទៅមានទំហំបណ្តោយ ទទឹង ហើយជម្រៅប្រមាណពី ៣០ x ៣០ x ៣០ ស.ម ទាំងនេះ អាស្រ័យទៅតាមភាពសំបូរជីជាតិរបស់ដី បើដីល្អដីផុះធូ ដូចជាសភាពដីជាដីខ្សាច់ ឬ ដីថ្ម គួរជីករណ្តៅដាំមៀន ទំហំធំដើម្បីបានកែប្រែដីក្នុងរណ្តៅដាំឱ្យបានល្អឡើង។ ដីក្នុងរណ្តៅដែលជីកមកនោះ ត្រូវចែកជាពីរគំនរគឺ ដីស្រទាប់លើ ត្រូវចែកទុកមួយគំនរ ដីស្រទាប់ក្រោម ទុកមួយគំនរទៀត ហាលដីដែលជីកឡើងមកឱ្យស្ងួតប្រមាណ៥ថ្ងៃ ដើម្បីសម្លាប់មេរោគផ្សេងៗដែលអាស្រ័យនៅក្នុងដី ដីក្នុងរណ្តៅ គួរកែប្រែឱ្យនៅក្នុងសភាពផុះធូ ដើម្បីឱ្យដីជៀបទឹកបានល្អ ហើយសមស្របដល់ការស្រូបរបស់ ឫស្សរុក្ខជាតិ ដោយវាយដីដែលជីកឡើងមក ឱ្យមានទំហំតូច ហើយផ្សំដីជាន់លើជាមួយជីកំប៉ុស្តឬកាកសំណល់ រុក្ខជាតិផុយរលួយចាស់ៗ ជាជីធ្លាប់ ឬកម្ទេចកម្ទីស្លឹកឈើពុក ប្រមាណ១បង្គី ហើយលាយដីទាំងពីរគំនរជាមួយជីផូស្វ័រ ឬផេះឆ្អឹង ១០០ក្រាម ឬ ប្រមាណ ១-២ ក្តាប់ដៃច្របល់ដីជាមួយជីឱ្យចូលគ្នាល្អ ទើបលប់ដីទៅក្នុងរណ្តៅដូចដើម ដោយលប់ដីស្រទាប់លើទុកក្នុងបាតរណ្តៅ ហើយដីស្រទាប់ក្រោមលប់ទៅពីលើ (ក្រោយ) ដោយដាក់ដីក្នុងរណ្តៅឱ្យពូនឡើងខ្ពស់ ជាងលំដាប់ដីដើម ឱ្យមានលក្ខណៈជាទួលតូចៗ ដើម្បីជួយបញ្ចេញទឹក ចេញពីរណ្តៅដីផ្សំដែលដាក់ក្នុងរណ្តៅនោះ ជាដីដែលមានលក្ខណៈផុះធូ ឫសមៀនអាចលូតលាស់ទៅក្នុងដីបានយ៉ាងឆាប់រហ័ស ដើមមៀនអាចតាំងជំហរបានលឿន ហើយមានភាគរយរស់បានខ្ពស់ បើមានការមើលថែរក្សាបានល្អ ដូចជាការផ្តល់ទឹក ជីសមស្រប មៀននឹងរីកលូតលាស់បានល្អ និងផ្តល់ទិន្នផលខ្ពស់។

### ៥-៧. ការត្រៀមដើមពូជ:

ក្រោយពីត្រៀមដី និងរណ្តៅដាំរួចស្រេចហើយ ដំណាក់កាលបន្ទាប់ គឺការដាំមៀន មិនថាដាំដោយពូជមែកសាក មែកផ្សាប ការតមែក ឬដើមដែលបានពីការបណ្តុះក៏ដោយ ក៏ត្រូវធ្វើដោយប្រុងប្រយ័ត្ន កុំឱ្យមែកពូជគ្រិច ឬជាំ ហើយនឹងឫសដាច់ច្រើនពេក ពីព្រោះពេលដាំអាចធ្វើឱ្យដើមមិនលូតលាស់ ឬងាប់បាន ។

ការដាំមៀនក្នុងពេលបច្ចុប្បន្ននេះ មួយភាគធំនិយមប្រើដើមពូជដែលបានមកពីការសាកមែក ដោយសារដើមពូជដែលបានពីការសាកមែកនោះ ផ្តល់ផលលឿន ដើមមិនខ្ពស់ ទម្រង់ដើមជាទម្រង់ងាយស្រួលក្នុងការថែរក្សា និងប្រមូលផលដើមក៏មិនក្លាយពូជ តែចំណុចដែលមិនល្អពីការប្រើពូជមកពីការសាកមែក គឺអាយុខ្លីជាង ហើយមិនធន់ជាមួយមេរោគ។ ជាទូទៅដើមពូជដែលបានមកពីការសាកមែក គឺជាដើមពូជដែលបានសាកពីក្នុងចំការរបស់ខ្លួន ចំពោះកសិករដែលមិនមានលទ្ធភាពសាកមែកដោយខ្លួនឯងហើយត្រូវការពូជយកមកដាំ គួររកទិញដើមពូជពីចម្ការ ឬ កន្លែងលក់មែកពូជ ដែលអាចជឿទុកចិត្តបានមកដាំ ពីព្រោះការធ្វើចម្ការមៀនត្រូវតែដឹងច្បាស់ថា ដើមពូជដែលយកមកដាំ ជាពូជល្អ ត្រឹមត្រូវតាមសេចក្តីត្រូវការដែរឬទេ បើមិនដូច្នេះទ គេត្រូវប្រើពេលវេលាពិសោធន៍ច្រើនឆ្នាំ ទើបដឹងលទ្ធផល ។ បើបានពូជមៀនមិនល្អមកដាំត្រូវខាតទាំងពេលវេលា ប្រាក់ទុននិងកម្លាំងពលកម្ម។ ដើម្បីជៀសវាងពីប្រការនេះកសិករគួររកទិញដើមពូជ ពីកន្លែងក្រុមគាំទ្របច្ចេកទេសកសិកម្ម ជួយទំនុកបម្រុង ដោយមានការធានា មុខនឹងយកពូជមកដាំជាការល្អបំផុត។ ក្នុងការត្រៀមដើមពូជនេះ ក្រៅពីបរិមាណដើមពូជ ដែលត្រូវនាំយកមកដាំ ត្រូវមានការត្រៀម ដើមពូជ បម្រុងទុកសម្រាប់ដាំជួស ដើមពូជដែលងាប់ផងដោយត្រៀមដើមពូជទុកប្រមាណ៥% នៃចំនួនដើមពូជសរុប ឧទាហរណ៍បើដាំក្នុងចំនួន១០០ដើម ត្រូវត្រៀមដើមពូជ១០៥ដើម ពូជដែលនាំយកមកដាំជាពូជដែលផ្សាំទុកហើយនិង ត្រូវមានលក្ខណៈរឹងមាំល្អ មិនមានមេរោគនិងសត្វល្អិតបំផ្លាញ ឬមិនរីកលូតលាស់ មិនប្រេះស្រាំ ក្នុងរយៈពេលដឹកជញ្ជូន ហើយមែកពូជដែលកាត់ថ្មី គួរនាំយកទៅផ្សាំឱ្យរឹងមាំបរិបូរជាមុនសិន មុននឹងយកទៅដាំ ។



បន្តទៅលេខ ៥២

# បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

បន្តពីលេខ៥០ 

រៀបចំដោយៈ នាយកដ្ឋានអភិវឌ្ឍវារីវប្បកម្ម នៃរដ្ឋបាលជលផល

## ១៤- កត្តាសំខាន់ៗ ដែលត្រូវចៀសវាង

ការចិញ្ចឹមត្រី នឹងមានជំងឺ ងាប់ដោយសារបានអនុវត្តន៍នូវសកម្មភាពមិនល្អដូចខាងក្រោមៈ



ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតជិតស្រះ ចិញ្ចឹមត្រី



ប្រើបង្គន់នៅពីលើស្រះចិញ្ចឹមត្រី



ត្រាំឈើ ឬស្លឹកត្នោតក្នុងស្រះកំពុងចិញ្ចឹមត្រី



ដាក់ចកអណ្ដែតពេញផ្ទៃស្រះ



លាងធុងបាញ់ថ្នាំពុល ក្នុងស្រះកំពុងចិញ្ចឹមត្រី



បោកគក់ខោអាវក្នុងស្រះកំពុងចិញ្ចឹមត្រី

## ១៥- គន្លឹះសំខាន់ៗមួយចំនួនសម្រាប់ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ

- ការសំអាតស្រះមុនពេលដាក់កូនត្រីចិញ្ចឹម ជាកត្តាសំខាន់ណាស់ ធ្វើឱ្យការចិញ្ចឹមត្រីរបស់អ្នកទទួលបានជោគជ័យ
- បើមានត្រីផ្ទក់ ឬត្រីរស់ តែមួយនៅក្នុងស្រែ វានឹងស៊ីត្រីដែលអ្នកដាក់ចិញ្ចឹមអស់ ក្នុងរយៈពេលយ៉ាងខ្លី
- ការដាក់ជីជាប្រចាំ ដើម្បីឱ្យទឹកស្រះមានពណ៌បៃតង ជាកត្តាសំខាន់ណាស់ ធ្វើឱ្យត្រីរបស់អ្នកធំធាត់ល្អ
- ពន្លឺថ្ងៃជាកត្តាសំខាន់មួយ ធ្វើឱ្យចំណីធម្មជាតិ ឬប្លង់តុងកើតក្នុងស្រះបានល្អ ក្រោយពេលដាក់ជី
- ការចិញ្ចឹមត្រីក្នុងស្រះមានប្រឡាយឆ្លាប់ទៅស្រែ ជាវិធីមួយដ៏ល្អ ជួយឱ្យត្រីរបស់អ្នក ធំធាត់ឆាប់រហ័ស
- ហើយអ្នកអាចកាត់បន្ថយការចំណាយប្រាក់ទិញចំណីត្រីទៀតផង ។







# ជំពូកទី២
# បច្ចេកទេសចិញ្ចឹមត្រីក្នុងស្រែ

## ១- អត្ថប្រយោជន៍នៃការចិញ្ចឹមត្រីក្នុងស្រែ

### ចំពោះដំណាំស្រូវ

- កសិករចំណេញថវិកាមិនប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត សម្លាប់ស្មៅ និងជីគីមី ព្រោះការចិញ្ចឹមត្រីក្នុងស្រែ ត្រីស៊ីសត្វល្អិត និងស្មៅចង្រៃដែលបំផ្លាញដំណាំស្រូវ និងលាមកត្រីជាជីសម្រាប់ដំណាំស្រូវ។
- ត្រីឈ្មុសដីរកជន្លេនស៊ី ធ្វើឱ្យដីស្រែផុស និងដំណាំស្រូវលូតលាស់ល្អ។
- ទិន្នផលស្រូវកើនឡើងដោយមិនចាំបាច់ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត សម្លាប់ស្មៅ និងជីគីមីបង្កើនផលស្រូវ ក្នុងករណីៈ

១. រៀបចំដាំដំណាំស្រូវតាមគោលការណ៍បច្ចេកទេសបានល្អត្រឹមត្រូវ

២.ទំហំផ្ទៃជម្រកត្រីក្នុងស្រែមិនតិចជាង ១ភាគ ៤នៃទំហំផ្ទៃស្រែសរុប ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមក្នុង១ ម៉ែត្រការ៉េស្រែគឺ ១ក្បាលកូនត្រី និងអត្រារស់កូនត្រីនៅពេលប្រមូលផលមិនតិចជាង៨០%

### ចំពោះត្រី

មិនចាំបាច់មានស្រះកសិករក៏អាចចិញ្ចឹមត្រីបានហូបដែរ ដោយគ្រាន់តែជីកជម្រកត្រីក្នុងស្រែ

កាត់បន្ថយការផ្តល់ចំណីបន្ថែម ក្នុងករណីចិញ្ចឹមត្រីក្នុងស្រែមានបរិមាណតិចតួច (ទំហំផ្ទៃជម្រកត្រីក្នុងស្រែមិនច្រើនជាង១ ភាគ ៥នៃទំហំផ្ទៃស្រែសរុប និងដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមក្នុង២ ម៉ែត្រការេស្រែគឺ ១ ក្បាលកូនត្រី)។

ទិន្នផលត្រីកើនឡើង ក្នុងករណីផ្តល់ចំណីបន្ថែម និងជម្រកត្រីក្នុងស្រែមិនតិចជាង ១ ភាគ ៤ នៃទំហំផ្ទៃស្រែសរុប ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមក្នុង១ ម៉ែត្រការ៉េស្រែគឺ ១ក្បាលកូនត្រី។










# ២- ការជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រី

## គោលបំណង៖

ជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រី

- បានត្រឹមត្រូវ តាមបច្ចេកទេស ដើម្បីអនុវត្តន៍ទទួលបានជោគជ័យ
- និងបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង។

តើខ្ញុំត្រូវជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រីយ៉ាងដូចម្ដេច ?

យើងត្រូវជ្រើសរើសទីតាំងស្រែចិញ្ចឹមត្រីដូចខាងក្រោម ៖

- នៅជិតផ្ទះងាយស្រួលគ្រប់គ្រងមើលថែទាំ ការងារបច្ចេកទេស និងការលួចបាត់បង់ត្រី។



- ជាស្រែជម្រៅមិនលិចទឹកនៅរដូវវស្សា ឬលិចទឹកតិចតួចអាចលើកភ្លឺទប់បាន។
- ជាស្រែមានគុណភាពដីល្អ ឬដីមានជីវជាតិ ឬជាប្រភេទដី ដែលអាចកែលម្អបាន ដោយប្រើប្រាស់ជីធម្មជាតិ។
- ជាដីស្រែអាចរក្សាទឹកបានយូររយៈពេល ៦ ខែ ដើម្បីឱ្យដំណាំស្រូវនិងត្រីលូតលាស់បានល្អ។
- ស្ថិតនៅទីវាលស្រឡះ គ្មានដើមឈើធំៗព័ទ្ធជុំវិញ ដែលនាំឱ្យបាំងពន្លឺព្រះអាទិត្យ។
- នៅជិតប្រភពទឹក បើសិនមានកាន់តែប្រសើរ ងាយស្រួលក្នុងការផ្លាស់ប្ដូរទឹក ពេលទឹកក្នុងស្រែឡើងកម្ដៅខ្លាំងលើសពី ៤០ អង្សាសេ និងត្រូវការបញ្ចូលទឹកក្នុងស្រែបន្ថែម នៅពេលទឹកក្នុងស្រែស្រកចុះដើម្បីចៀសវាងដំណាំស្រូវ និងត្រីក្នុងស្រែងាប់ ។
- នៅឆ្ងាយពីតំបន់ដែលមានប្រើប្រាស់ថ្នាំពុលកសិកម្ម។





មិនត្រូវជ្រើសរើសស្រែចិញ្ចឹមត្រីនៅជិតតំបន់ប្រើប្រាស់ថ្នាំពុលកសិកម្ម

# ៣- លក្ខណៈស្រែចិញ្ចឹមត្រី

## គោលបំណង៖

### ដើម្បីយល់ច្បាស់ពី

- ទ្រង់ទ្រាយ ឬរូបរាង និងទំហំស្រែដែលអាចចិញ្ចឹមត្រីបាន
- លក្ខណៈបច្ចេកទេសនៃស្រែចិញ្ចឹមត្រី
- ការរៀបចំស្រែចិញ្ចឹមត្រី ឱ្យបានត្រឹមត្រូវ តាមបច្ចេកទេស ដើម្បីអនុវត្តន៍ទទួលបានជោគជ័យ



- ស្រែចិញ្ចឹមត្រីមានរូបរាងទ្រង់ទ្រាយបែបណាក៏អាចចិញ្ចឹមត្រីបានដែរ តែគួរមានរាងបួនជ្រុងងាយស្រួលគ្រប់គ្រង។
- ស្រែចិញ្ចឹមត្រីមានទំហំប៉ុនណាក៏អាចចិញ្ចឹមត្រីបានដែរ តែគួរមានទំហំពី ៥០០ ម៉ែត្រការ៉េឡើងទៅសមស្របដល់ការចិញ្ចឹមត្រីបានធំធាត់ល្អ។ ស្រែចិញ្ចឹមត្រីមានទំហំកាន់តែធំ ផលស្រូវនិងត្រីក៏ទទួលបានកាន់តែច្រើន ប៉ុន្តែទាមទារឱ្យមានការយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានល្អ ដូចក្នុងមេរៀនទី ១៣ ខាងក្រោមបានបញ្ជាក់។



- ស្រែចិញ្ចឹមត្រីត្រូវមានភ្លឺខ្ពស់និងមាំល្អ ដើម្បីការពារលិចទឹក និងត្រីរួចចេញពីស្រែ។
- នៅតាមភ្លឺស្រែត្រូវបង្កប់បំពង់ទឹក សម្រាប់បង្ហូរទឹកចេញពីស្រែនៅពេលមានភ្លៀងធ្លាក់ខ្លាំង និងសម្រាប់បង្ហូរទឹកពីក្រៅចូលស្រែវិញ នៅពេលទឹកក្នុងស្រែស្រកចុះ។
- ក្នុងស្រែចិញ្ចឹមត្រីត្រូវរៀបចំឱ្យមានជាប្រព័ន្ធប្រឡាយ ឬ ស្រះ ឬជីកស្រះតភ្ជាប់ទៅស្រែចិញ្ចឹមត្រី ដើម្បីជាជម្រកទឹកជ្រៅសម្រាប់ត្រីរស់នៅ នៅពេលទឹកក្នុងស្រែស្រកចុះ និងងាយស្រួលនៅពេលប្រមូលផលត្រី។



- ជម្រកត្រីក្នុងស្រែអាចរៀបចំជាប្រព័ន្ធប្រឡាយ ឬស្រះក្នុងស្រែ ឬក៏ជាស្រះនៅខាងក្រៅស្រែតែតភ្ជាប់ទៅស្រែដោយប្រឡាយ (សូមមើលរូបភាពបញ្ជាក់ខាងក្រោម)។
- ក្នុងករណីរៀបចំប្រព័ន្ធប្រឡាយចិញ្ចឹមត្រីក្នុងស្រែគួររៀបចំឱ្យមានទទឹង ឬទំហំមាត់ប្រឡាយហោចណាស់ ១ម៉ែត្រ និងជម្រៅកន្លះម៉ែត្រ។ បើទំហំមាត់ប្រឡាយ និងជម្រៅមានទំហំធំជាងនេះកាន់តែប្រសើរដើម្បីឲ្យត្រីលូតលាស់បានល្អ។ ជាទូទៅប្រព័ន្ធប្រឡាយក្នុងស្រែចិញ្ចឹមត្រីគួរមានទំហំផ្ទៃសរុបប្រមាណ ១ ភាគ ៥នៃផ្ទៃស្រែសរុប ឬ អាចមានទំហំធំជាងនេះក៏បាន អាស្រ័យយើងចង់បាន។
- ចូរចងចាំថា ទំហំផ្ទៃទឹកជាជម្រកត្រីកាន់តែធំ ទិន្នផលត្រីចិញ្ចឹមកាន់តែទទួលបានច្រើន ប៉ុន្តែចាំបាច់ត្រូវផ្តល់ចំណីបន្ថែមដល់ត្រី ព្រោះចំណីធម្មជាតិ ដែលមានក្នុងស្រែមិនគ្រប់គ្រាន់សម្រាប់ត្រីចិញ្ចឹមក្នុងស្រែ និងចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រងបន្ថែមទៀត។
- ក្នុងករណីកសិករចង់ទទួលបានទាំងផលស្រូវនិងផលត្រី ទំហំផ្ទៃទឹកជាជម្រកត្រីមិនគួរលើសពី ១ ភាគ ៤ នៃទំហំផ្ទៃដីស្រែសរុប។




ប្រព័ន្ធប្រឡាយចិញ្ចឹមត្រីក្នុងស្រែផ្សេងៗគ្នា

# ៤- របៀបជីកប្រព័ន្ធស្រែចិញ្ចឹមត្រី

## គោលបំណង៖

ដើម្បីយល់ច្បាស់ពី

- ភាពផ្សេងៗគ្នានៃប្រព័ន្ធជម្រកត្រីក្នុងស្រែ ដែលមានលក្ខណៈសមស្របសម្រាប់ចិញ្ចឹមត្រី
- របៀបជីកប្រព័ន្ធជម្រកត្រីក្នុងស្រែ
- របៀបរៀបចំប្រព័ន្ធស្រែចិញ្ចឹមត្រី តាមលក្ខណៈបច្ចេកទេសដើម្បីចិញ្ចឹមត្រីទទួលបានជោគជ័យ។

ប្រព័ន្ធស្រែចិញ្ចឹមត្រីអាចជីកបាន តាមរបៀបច្រើនយ៉ាងដូចខាងក្រោម ៖

- ជីកជាប្រព័ន្ធប្រឡាយជុំវិញក្នុងស្រែចិញ្ចឹមត្រី
- ឬជីកជាប្រឡាយស្របនឹងជ្រុងភ្លឺស្រែណាមួយក៏បានក្នុងករណីគ្មានថវិកាគ្រប់គ្រាន់សម្រាប់ជីកប្រព័ន្ធប្រឡាយជុំវិញក្នុងស្រែ។
- ឬ ជីកជាប្រព័ន្ធប្រឡាយខ្វែងកាត់ក្នុងស្រែក៏បាន
- ឬ ក៏ជីកជាកូនស្រះនៅក្នុងស្រែ ដែលមានកន្លែងទំនាបជាងគេក៏បាន ដើម្បីឱ្យទឹកក្នុងស្រែដក់ទឹកបានយូរជាប្រយោជន៍ដល់ការលូតលាស់របស់ត្រី។
- ការជីកប្រព័ន្ធប្រឡាយជុំវិញស្របនឹងភ្លឺស្រែ គួរទុកចំណីភ្លឺស្រែប្រមាណ ០.៥ ម៉ែត្រ ទើបជីកប្រព័ន្ធប្រឡាយនោះ ដើម្បីការពារការហូរបាក់ដី ពីភ្លឺស្រះចូលក្នុងប្រឡាយដែលនាំឱ្យទឹកប្រឡាយល្អក់ និងធ្វើឱ្យទឹកប្រឡាយរាក់ទៀតផង។





- ប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែ ត្រូវជីកឱ្យមានជើងទេរ ដើម្បីការពារកុំឱ្យដីធ្លាក់បាក់ចូលក្នុងប្រឡាយដែលនាំឱ្យទឹកស្រែល្អក់ និងប្រឡាយរាក់។
- អាចម៍ដីដែលជីកបានត្រូវយកមករៀបចំធ្វើជាទំនប់ភ្លឺស្រែកម្ពស់ ០.៥ម៉ែត្រ (ឬមានកម្ពស់ខ្ពស់ជាងនេះក៏បានអាស្រ័យនឹងកំពស់ទឹកជំនន់) ខ្នងលើប្រវែង ០.៨ម៉ែត្រ ទៅ ១ម៉ែត្រ រួចដាំស្មៅ ដើម្បីឱ្យទំនប់ភ្លឺស្រែរឹងមាំល្អ និងការពារទឹកជំនន់លិចស្រែចិញ្ចឹមត្រី។
- ប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែគួរជីកនៅជាប់ផ្លូវ ឬជាប់ភ្លឺស្រែដែលចេញចូល ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ឬក៏អាចជីកទៅតាមជម្រាលដីវាលស្រែជាក់ស្តែងក៏បាន។ ជាទូទៅ ប្រព័ន្ធប្រឡាយ ឬជម្រក

ត្រីក្នុងស្រែ គួរជីកនៅកន្លែងដែលមានជម្រាលទាបជាងគេ ដើម្បីឱ្យទឹកក្នុងស្រែដក់បានយូរនៅកន្លែងជម្រាលនោះ ម៉្យាងទៀត ដើម្បីបង្កលក្ខណៈងាយស្រួលនៅពេលប្រមូលផលត្រី។

- ការជីកប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែ គួរចាប់ផ្ដើមធ្វើនៅមុនពេលរដូវភ្លៀងធ្លាក់ និងក្រោយពេលភ្ជួររាស់ដាស់ដីស្រែរួចរាល់ហើយ ដើម្បីចៀសវាងការជីកប្រព័ន្ធប្រឡាយ ឬជម្រកត្រីក្នុងស្រែ មិនបានល្អ។
- ម៉្យាងទៀត យើងអាចចិញ្ចឹមត្រីក្នុងស្រះជាមួយវាលស្រែបាន ដោយតភ្ជាប់ស្រះនិងវាលស្រែដោយជីកជាប្រឡាយ។ ករណីនេះ ធ្វើឲ្យទិន្នផលត្រីចិញ្ចឹមក្នុងស្រះកើនឡើង ដោយសារត្រីចិញ្ចឹមក្នុងស្រះចេញទៅវាលស្រែស្វែងរកស៊ីចំណីបានច្រើនក្នុងវាលស្រែ ដូចជា សត្វល្អិត និងស្មៅចង្រៃរបស់ដំណាំស្រូវ និងត្រូវផ្ដល់ចំណីបន្ថែមដល់ត្រី។




គំរូរបៀបជីកប្រព័ន្ធប្រឡាយចិញ្ចឹមត្រីក្នុងស្រែ



## ៥- ការរៀបចំស្រែមុនពេលដាក់កូនត្រីចិញ្ចឹម

### គោលបំណង៖

ដើម្បីទទួលបាននូវ

- កូនត្រីមានអត្រារស់ច្រើន ក្រោយពេលដាក់កូនត្រីចិញ្ចឹម
- មិនប៉ះពាល់ដល់ដំណាំស្រូវ នៅមុនពេល ឬក្រោយពេលដាក់កូនត្រីចិញ្ចឹម
- កូនត្រីមានការលូតលាស់ល្អ
- ក្នុងស្រែគ្មានស្មៅ និងសត្វល្អិតបំផ្លាញដំណាំស្រូវ។

មុនពេលដាក់កូនត្រីចិញ្ចឹមក្នុងស្រែ ស្រែគួររៀបចំដូចខាងក្រោម៖

- វាលស្រែត្រូវភ្ជួររាស់ដាស់ដីឱ្យបានរៀបចំស្មើល្អ និងអាចប្រើប្រាស់ជីធម្មជាតិដាក់ក្នុងស្រែបាន តាមបច្ចេកទេសនៃការរៀបចំស្រែ ( គួរចៀសវាងការប្រើប្រាស់ជីគីមី ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងសម្លាប់ស្មៅចង្រៃ ព្រោះនាំឱ្យពុលដល់កូនត្រីក្រោយពេលដាក់ចិញ្ចឹមនិងខាតបង់ថវិកាថែមទៀតផង។
- លុបរន្ធក្ដាម ពស់ កង្កែបនៅតាមភ្លឺស្រែ។ នៅ



ក្នុងប្រព័ន្ធប្រឡាយ ឬស្រះ ដែលជាជម្រកត្រីក្នុងស្រែ អាចបាចកំបោរសក្នុងបរិមាណពី ៥ ទៅ ៨ គីឡូក្រាមក្នុងផ្ទៃដីជម្រកត្រីក្នុងស្រែ ១០០ ម៉ែត្រការ៉េ រួចបញ្ចូលទឹកកន្លះម៉ែត្រ និងទុករយៈពេលពី២ ទៅ៣ថ្ងៃ រួចដាក់ជីលាមកសត្វក្នុងបរិមាណដូចខាងក្រោម

- ជីលាមក គោ ក្របីសើម ៦០- ៨០ គ.ក្រ/ ១០០ ម៉ែត្រការ៉េនៃផ្ទៃជម្រកត្រីក្នុងស្រែ
- ឬជីលាមក ជ្រូកសើម ២០- ៣០ គ.ក្រ/ ១០០ ម៉ែត្រការ៉េនៃផ្ទៃជម្រកត្រីក្នុងស្រែ
- ឬជីលាមក មាន់ ទាសើម ១០- ២០ គ.ក្រ/ ១០០ ម៉ែត្រការ៉េនៃផ្ទៃជម្រកត្រីក្នុងស្រែ
- ឬជីរុក្ខជាតិបៃតងទន្រ្ទានខែត្រ ២០- ៣០ គ.ក្រ/ ១០០ម៉ែត្រការ៉េនៃផ្ទៃជម្រកត្រីក្នុងស្រែ

បន្ទាប់មកទុករយៈពេល ១សប្ដាហ៍ ដើម្បីឱ្យជីលាមកសត្វរលាយសព្វបានល្អក្នុងទឹកប្រឡាយ

- បន្ទាប់មក នៅលើផ្ទៃដីវាលស្រែ ក្រោយពេលរៀបចំភ្ជួររាស់និងដាក់ជីធម្មជាតិហើយ អាចចាប់ផ្ដើមស្ទូង ឬព្រោះគ្រាប់ស្រូវតាមបច្ចេកទេសនៃដំណាំស្រូវ។
- ចំពោះស្រែដែលស្ទូងតាមវិធីព្រោះគ្រាប់ស្រូវ ត្រូវព្រោះគ្រាប់ស្រូវឱ្យហើយក្នុងរយៈពេលពី ៤ទៅ ៥សប្ដាហ៍ ដើម្បីឱ្យសន្ទូងដុះចាប់ឫសបានល្អ មុនពេលដាក់កូនត្រីចិញ្ចឹម។
- ចំពោះស្រែដែលស្ទូងតាមវិធីដាំសំណាប ត្រូវស្ទូងឱ្យហើយក្នុងរយៈពេល ២ទៅ ៣សប្ដាហ៍ ដើម្បីឱ្យសន្ទូងដុះចាប់ឫសបានល្អ មុនពេលដាក់កូនត្រីចិញ្ចឹម។
- ក្នុងស្រែកសិករគួរស្ទូងស្រូវជាជួរ និងឱ្យមានគម្លាតពីគ្នាចម្ងាយពី២០ទៅ២៥ សង្ទីម៉ែត្រ ដើម្បីឱ្យត្រី ហែលចេញចូលក្នុងស្រែរកចំណីបានស្រួល។
- ចំពោះស្រែដាំស្រូវពង្រោះ កសិករគួរព្រោះគ្រាប់ស្រូវឱ្យពង្រាយ ឬឱ្យគន្លាតពីគ្នា និងគួរព្រោះគ្រាប់ស្រូវជា

ជួរ ដោយទុកចន្លោះក្នុងជួរនីមួយៗពី ២០ ទៅ ២៥ សង្ទីម៉ែត្រ ដើម្បីឲ្យត្រីហែលចេញចូលក្នុងស្រែរក ចំណីបានស្រួល។

- បើកសិករដែលមានលទ្ធភាពគួរព័ទ្ធសំណាញ់ជុំវិញស្រែនៅពីលើភ្លឺស្រែ នៅមុនពេលបញ្ចូលទឹកក្នុងស្រែ ដើម្បីការពារកុំឱ្យត្រីស្រែ ឬកង្កែបលោតចូលក្នុងស្រែស៊ីកូនត្រី និងការពារទឹកជំនន់លិចចូលក្នុងស្រែផង (សូមមើលរូបភាពខាងក្រោម)។
- ចំពោះការបញ្ចូលទឹកក្នុងស្រែ ត្រូវប្រើតម្រងចងស្បៃនៅខាងចុងទុយោផ្នែកប្រភពទឹកបូម ឬបង្ហូរចូលស្រែ ដើម្បីការពារកុំឱ្យត្រីស្រែចូលក្នុងស្រែ នៅក្រោយពេលស្រែបានរៀបចំល្អហើយ ឬនៅមុនពេលដាក់កូនត្រីចិញ្ចឹមបានរយៈពេល ២ ខែ។
- ត្រូវប្រាកដថា ប្រភពទឹកបញ្ចូលស្រែមានគុណភាពល្អ គ្មានជាតិពុល និងសារធាតុគីមីផ្សេងៗ ដែលនាំឱ្យកូនត្រីស្លាប់បាន។
- ក្រៅពីនេះត្រូវរៀបចំរណ្តៅជីលាមកសត្វឱ្យនៅជាប់នឹងភ្លឺស្រះ ដើម្បីងាយស្រួលបង្ហូរទឹកជីចូលក្នុងស្រែចិញ្ចឹមត្រី ក្រោយពេលដាក់កូនត្រីចិញ្ចឹមហើយ ។ គួរចៀសវាងការដាក់ជីលាមកសត្វផ្ទាល់ក្នុងស្រែចិញ្ចឹមត្រីនៅក្រោយពេលដាក់កូនត្រីចិញ្ចឹមហើយ ព្រោះវាបណ្តាលឱ្យកូនត្រីពុលងាប់យ៉ាងងាយ  រណ្តៅជីគួរជីកដីទំហំបណ្តោយប្រវែង ២ម៉ែត្រ ទទឹងប្រវែង ១ម៉ែត្រ ជម្រៅ ១ម៉ែត្រ ឬអាចជីកទំហំធំជាងនេះក៏បានអាស្រ័យនឹងទំហំស្រែដែលចិញ្ចឹមត្រី  សំអាតបាតរណ្តៅជី រួចក្រាលកម្រាលកៅស៊ូប្លាស្ទីក ដើម្បីការពារទឹកជីលាមកសត្វជ្រាបចូលក្នុងដី។ យើងអាចប្រើពាងទឹកធ្វើជារណ្តៅជី ត្រាំជីលាមកសត្វក៏បាន ឬប្រើកង់អណ្តូងរៀបធ្វើជារណ្តៅជីក៏បានអាស្រ័យទៅនឹងលទ្ធភាពកសិករ។



*ព័ទ្ធសំណាញ់ជុំវិញភ្លឺស្រែ នៅមុនពេលបញ្ចូលទឹកក្នុងស្រែ*



*ការរៀបចំរណ្តៅជីលាមកសត្វឲ្យនៅជាប់នឹងភ្លឺស្រែ នៅមុនពេលដាក់កូនត្រីចិញ្ចឹម*



បន្តនៅលេខ៥២

# បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ

បន្តពីលេខ៥០

រៀបចំដោយ: នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

**រោគសញ្ញា**

- ស្លាប់លឿន
- ហើមណាង់ ខ្ទង់ច្រមុះ បាតជើង និងសរសៃពួរ
- ភ្នែកមានខ្ទុះ
- ជង្គក់
- មានហូរសំបោរចេញពីរន្ធច្រមុះ និងមាត់

**ការពារ**

- ប៉ាស្ទ័ររ៉ែលឡា អាចរស់ក្នុងមជ្ឈដ្ឋានសើមបានយូរថ្ងៃ (សម្រាម ភក់ជ្រាំ កន្លែងក្រខ្វក់)
- វាអាចរស់នៅបានយូរខែក្នុងសាកសពដែលរលួយ និងសើម
- តែវាងាយងាប់នៅពេលត្រូវពន្លឺព្រះអាទិត្យកម្តៅសម្ងួត ។ ដូចនេះការសម្អាត និង សម្ងួតនៅមជ្ឈដ្ឋានជុំវិញ អាចការពារជំងឺនេះបាន ។

មជ្ឈដ្ឋានល្អ គឺជាវិធានការដ៏ល្អក្នុងការការពារជម្ងឺអាសន្នរោគ ។

នេះជាមជ្ឈដ្ឋានមិនល្អសម្រាប់មេរោគលូតលាស់



*ទិដ្ឋភាពមជ្ឈដ្ឋានមិនល្អសម្រាប់មេរោគលូតលាស់*

**ការព្យាបាល**

- ចាក់អុកស៊ីតេត្រាស៊ីគ្លីន (OTC) ៥០មក្រ/ក្បាល
- លាយតេត្រាស៊ីគ្លីនក្នុងចំណីឱ្យមាន់ស៊ីរយៈពេល ៣០ថ្ងៃ ព្រោះបាក់តេរីប៉ាស្ទ័ររ៉ែលឡាអាចរស់នៅក្នុងទឹក និងដីបានដល់ទៅ ៣សប្តាហ៍ ។
- ដើម្បីចៀសវាងកុំឱ្យមេរោគឆ្លងទៅក្នុងទឹក និងដី នៅពេលមានមាន់ស្លាប់ ចាំបាច់ត្រូវដុតសាកសពចោល ។

ចាក់អុកស៊ីតេត្រាស៊ីគ្លីន(OTC) តាមសាច់ដុំទ្រូង

### ៣.២ ជម្ងឺរលាកពោះវៀន

ជម្ងឺរលាកពោះវៀន តែងតែមានរោគសញ្ញាដូចគ្នា ដូចជា ៖

- រាគ



*ចាក់អុកស៊ីតេត្រាស៊ីគ្លីន (OTC) តាមសាច់ដុំទ្រូង*

- រោមនៅជុំវិញក្លូអាក់មានសភាពក្រខ្វក់
- ស្រេកទឹក / ខ្សោះទឹក
- សត្វស្គមលឿន

ការពិនិត្យលាមក និងការវះកាត់សាកសព អាចជាជំនួយក្នុងការធ្វើរោគវិនិច្ឆ័យ ។

ជម្ងឺរលាកពោះវៀន អាចបង្កឡើងដោយ ៖

- បរាសិត ដូចជាអាស្ការី (Ascaridia) កុកស៊ីដ្យា (Coccidia)
- បាក់តេរី ដូចជាជំងឺបង្កឡើងដោយអ៊ីកូលី (E. coli) សាល់ម៉ូណែលឡា (Salmonella)
- វីរុស ដូចជាជំងឺហ្គំបូរ៉ូ (Gumboro)
- កត្តាផ្សេងៗ
- ព្រូនមូល (Ascarisa) និងតេញ៉ា

**រោគសញ្ញា**

- លូតលាស់យឺត ពងតិច ហើយសត្វងាយទទួលជំងឺ ។

**ការព្យាបាល និងការការពារ**

- ប្រើតេត្រាមីសូល (Tetramisole) ១០០មក្រ ក្នុងមាន់ទម្ងន់ ២គក្រ
- ឬពីប៉េរ៉ាស៊ីន (Piperazine) ឬឡេវ៉ាមីសូល (Levamisole)



*ព្រូនក្នុងលាមក*

**កុកស៊ីដ្យូស៊ីស (Coccidosis)**

បង្កឡើងដោយប្រូតូសូអា ប្រភេទអេមេរ៉ា (Eimeria)។

**រោគសញ្ញា**

- កើតមានលើកូនមាន់
- ស្គមកំព្រឹង
- ស្រេកទឹក
- ស្លឹកស្រពន់
- រោមបាស់
- លាមកអាចមានឈាម ដោយសារមេរោគធ្វើឲ្យដាច់ពោះវៀន
- ក្នុងករណីធ្ងន់ធ្ងរលាមកមានពពុះ មានឈាម



*លាមកមានឈាម*

**ការព្យាបាល**

- ប្រើស៊ុលហ្វា ៣៣ (Sulfadimerazine) លាយក្នុងទឹកឱ្យផឹកចំនួន៣ថ្ងៃ ក្នុងកម្រិត១០ មល ក្នុងទឹក ១លីត្រ
- ឬស៊ុលហ្វាឌីមីឌីន (Sulfadimidine) អំប្រូលីយ៉ូម (Amprolium)

**ការការពារ**

- អនាម័យជាប្រចាំ
- កម្រាលត្រូវស្ងួតល្អ (ពិសេសស្នូកទឹក ស្នូកចំណី)



## កូលីបាក់ស៊ីឡូស៊ីស (Colibacillosis)

បង្កឡើងដោយអឺកូលី(E. Coli)។

**រោគសញ្ញា**

- អឺកូលីបំបែកខ្លួននៅក្នុងពោះវៀន តែរោគសញ្ញាដែលលេចចេញដំបូង គឺផ្លូវដង្ហើម ព្រោះបាក់តេរីអឺកូលីសាយភាយចូលទៅក្នុងថង់ខ្យល់
- មាន់ស្លឹកស្រពន់ រោមបាស់ ប្រឹងដកដង្ហើម ក្អកដកដង្ហើមឮសូរ
- រាគដោយសាររលាកពោះវៀន



*រោមបះ សញ្ញាផ្លូវដង្ហើម និងរាគ*

ត្រូវចាំថា អឺកូលីជាជម្ងឺឆ្លៀតឱកាស ដែលកើតឡើងក្រោយពីមានមីកូប្លាស្មា ។

**ស្លាកស្នាម**

- មានខ្ទុះខាប់នៅក្នុងថង់ខ្យល់ ស្រោមបេះដូង និង នៅលើផ្ទៃនៃបេះដូង ថ្លើម និងសួត

**ការព្យាបាល**



*ស្នាមរលាកសរសៃមានលើថ្លើម*

អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin) ជាឱសថដែលមានប្រសិទ្ធភាពប្រឆាំងនឹងបាក់តេរីទាំងពីរប្រភេទនេះ ។

## សាល់ម៉ូណែលឡូស៊ីស (Salmonellosis)

សាល់ម៉ូណែលឡាមានច្រើនប្រភេទ ដូចជា ហ្គាលីណារ៉ូម (Gallinarum) ពុលឡរ៉ូម (Pullorum) ... នៅពេលមានបញ្ហា ពោះវៀន គួរតែធ្វើរោគវិនិច្ឆ័យ ប្រៀបធៀបលើសាល់ម៉ូណែលឡា នេះ ។

**រោគសញ្ញា ( ប្រភេទ Pullorose )**

- កើតមានលើកូនមាន់អាយុតិចជាង ២សប្តាហ៍
- លាមករាគពណ៌សលឿង
- ក្លូអាក់ចំហរ ដោយសារលាមកស្អិតជាប់
- មាន់មិនស៊ីចំណី សំយ៉ុងក្បាលចុះក្រោម



*លាមកស្អិតជាប់នៅក្លូអាក់កូនមាន់*

**រោគសញ្ញា ( ប្រភេទ Typhose )**

- កើតមានលើមាន់ជំទង់
- មិនស៊ីចំណី សំកុក
- លាមករាគពីពណ៌លឿងទៅពណ៌ខៀវ មានឆ្អួតឈាម

**ការចម្លង**

- តាមរយៈស៊ុត ឬការប៉ះពាល់ផ្ទាល់ជាមួយសត្វដែលផ្ទុកជំងឺ

### ស្លាកស្នាម

- ពុលឡូរ៉ូស មានដុំពកពណ៌ប្រផេះនៅលើថ្លើម ផាល សួត បេះដូង កោះ និងពោះវៀន
- ទូហ្វស ថ្លើម និងផាលរីក (មានពណ៌លឿង) ផ្លូវអាហារគ្របដណ្ដប់ដោយហ្វីប្រ៊ីន (Fibrin)



*ដុំពកពណ៌ប្រផេះនៅថ្លើម*

### ការព្យាបាល

- ប្រើអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin)។ ករណីកើតមានលើមនុស្ស ច្រើនបណ្ដាលមកពីការបរិភោគសាច់មាន់ដែលមិនបានចំអិនឱ្យបានឆ្អិនល្អ ។

### ជំងឺហ្គំបូរ៉ូ (Gumboro)

ជំងឺនេះបង្កឡើងដោយវីរុស ។ ច្រើនកើតលើមាន់ដែលមានអាយុតិចជាង ១០សប្ដាហ៍ ។

### រោគសញ្ញា (ប្រភេទ Pullorose)

- មានសភាពអស់កម្លាំងខ្លាំង មិនអាចបញ្ជាខ្លួនឯងបាន
- រាគទឹកពណ៌ស ប្រឡាក់ជាប់នៅរោមក្លូអាក់ មាន់ចឹកក្លូអាក់ និងរលាកក្លូអាក់

### ស្លាកស្នាម

- ថង់ក្លូអាក់មានសភាពហើមពណ៌លឿង ហើយជួនកាលអាចមានឈាម

### ការព្យាបាល

- គ្មានថ្នាំព្យាបាលទេ តែសត្វខ្លះអាចជា
- ចាក់វ៉ាក់សាំង

### ៣.៣.ជំងឺសរសៃប្រសាទ

ជំងឺនេះអាចបង្កឡើងដោយ ៖

- បាក់តេរី : បូទុយលីស ( Botulism )
- វីរុស : ញូវកាស ( Newcastle ) និងម៉ារិក ( Marek )
- សារធាតុគីមី : ជាតិពុល (ថ្នាំសម្លាប់សត្វល្អិត)

### រោគសញ្ញាប្រព័ន្ធប្រសាទ រួមមាន ៖

- អស់កម្លាំង
- ខ្វិន / ពិការ
- ប្រកាច់តែវ៉ៃ

### បូទុយលីស ( Botulism )

វាបង្កឡើងដោយបាក់តេរីក្លូស្ទ្រីដ្យូម (Clostridi-um Botulimum)។ បាក់តេរីនេះរស់នៅក្នុងបំពង់អាហាររបស់មាន់ និងបក្សីព្រៃ ហើយបញ្ចេញទៅក្នុងសំបុកចំណី ទឹក ដែលមាននៅក្នុងទ្រុងមាន់ ។ បន្ទាប់ពីសត្វស្លាប់ បាក់តេរីបានបញ្ចេញជាតិពុល ។ ដង្កូវដែលមាន



*រាគសលាយទឹក*



*កូនដង្កូវលើសាកសពរលួយ*

នៅក្នុងសាកសពសត្វនេះ ពេញទៅដោយជាតិពុល ហើយនៅពេលដែលមាន់ស៊ីដង្កូវនេះ ធ្វើឱ្យវាកើតមានជំងឺ។

**រោគសញ្ញា**

- ទន់ជើង ធ្លាក់ស្លាប ទន់ក និងធ្លាក់ត្របកភ្នែក
- ភាពទន់នេះនឹងផ្ដើមពីជើងទៅស្លាប ក និង ត្របកភ្នែក ។

**ការការពារ**

- ប្រមូល និងកប់សាកសព ។

**ការព្យាបាល**

- មិនសូវមានប្រសិទ្ធភាពទេ
- អាចប្រើប៉ង់ស្ត្រិប ( Pen-Strep )



មាន់មានសភាពទន់

## ញូវកាស ( Newcastle )

ជំងឺញូវកាសបង្កឱ្យមានការស្លាប់ ឬបញ្ហាដង្ហើមស្រួចស្រាវ តែរោគសញ្ញាប្រព័ន្ធប្រសាទ អាចសង្កេតឃើញមានតែលើមាន់ដែលឈឺបាន២-៣ថ្ងៃប៉ុណ្ណោះ។

ជាធម្មតាមាន់ដែលមានអាយុពី ២-៣សប្ដាហ៍ បានបង្ហាញរោគសញ្ញាពិបាកដកដង្ហើម បន្ទាប់មកទៀត រាគ និង សញ្ញាប្រព័ន្ធប្រសាទ ។

**រោគសញ្ញា**

- ធ្លាក់ស្លាប និងរមួលក



រមួលក

## ជំងឺម៉ារ៉េក ( Marek )

ជំងឺម៉ារេកបង្កឡើងដោយវីរុស គឺជាប្រភេទមហារីករបស់មាន់ ។

**រោគសញ្ញា**

- ខ្វិនជើង
- ជើងលាតសន្ធឹងទៅទិសផ្សេងគ្នា ជើងមួយសណ្ដូកទៅមុខ ឯជើងមួយទៀត សណ្ដូកទៅក្រោយ)



ខ្វិនជើង

## ស្លាកស្នាម

- រីកសរសៃប្រសាទ ជាពិសេសសរសៃនៅផ្នែកខាងក្រោយជើង
- មានដុំពកនៅថ្លើម ផាល តម្រងនោម បេះដូង សួត សាច់ដុំ និងទងកោះ

**ការព្យាបាល**

- គ្មាន

**ការការពារ**

- ដោយចាក់វ៉ាក់សាំង





*សរសៃប្រសាទចង្កេះរីកធំ ជាហេតុធ្វើឱ្យខ្វិន*

### ៣.៤ ជំងឺលើស្បែក

**ជម្ងឺនេះអាចបង្កឡើងដោយ ៖**

- បរាសិត : ចៃ ស្រមើរ ...
- វីរុស : អុតមាន់
- ការចឹកគ្នា : ទ្រុងចង្អៀត
- កង្វះវីតាមីន និងអាស៊ីដអាមីណេ

**បរាសិតខាងក្រៅ**

- បរាសិតខាងក្រៅដែលច្រើនកើតនោះ គឺចៃ
- ចៃបង្កឱ្យដាច់រលាត់ស្បែក
- មាន់នៅមិនស្ងៀមមិនសូវស៊ី ឬដេកមិនស្រួល

កត្តាទាំងនេះធ្វើឱ្យការលូតលាស់យឺត ពងបានតិច និងងាយទទួលជំងឺ ។

**ការព្យាបាល**

ប្រើម៉ាឡាសុន ៥% ( Malathion 5% ) បាញ់ផ្ទាល់លើមាន់ ហើយរំលឹករៀងរាល់ ៣ខែម្ដង ។ ម្យ៉ាងទៀតសំបុកក៏ត្រូវសំអាតដែរ។



*បរាសិតនៅរោមជុំវិញគូទអាក់*

**ជំងឺអុត**

ជំងឺអុតបង្កឡើងដោយវីរុស ។

**រោគសញ្ញា**

- ស្លាកស្នាមដុំពកនៅត្រង់កន្លែងគ្មានរោម
- ទំហំរបស់ដុំពកនេះរីកធំយ៉ាងរហ័ស ហើយរួមបញ្ចូលគ្នាទៅជាទំហំធំពណ៌លឿង និងមានក្រម៉ក្រៀម
- ក្នុងទម្រង់ជាខាន់ស្លាក់ គេឃើញមានស្លាកស្នាមនៅក្នុងមាត់ បំពង់អាហារ និងបំពង់ខ្យល់ ដែលធ្វើឱ្យមានការពិបាកដកដង្ហើម ។



**ការចម្លង**

- កើតមានដោយសារការប៉ះផ្ទាល់ជាមួយស្បែកដែលដាច់
- ការខាំរបស់មូស និងសត្វល្អិតផ្សេងទៀត ក៏ជាការចម្លងជម្ងឺផងដែរ ។

**ការចាក់វ៉ាក់សាំង**

- គ្មានការព្យាបាលទេ តែជំងឺអុតមានការសាយ

ភាយយឺត ដូចនេះការចាក់វ៉ាក់សាំងអាចបញ្ឈប់ការសាយភាយបាន

- ការចាក់វ៉ាក់សាំងការពារ ដោយការជួសស្លាប
- ចាក់នៅពេលមាន់មានអាយុចាប់ពី ១០ថ្ងៃ
- ត្រូវប្រយ័ត្ន  វ៉ាក់សាំងអុតជាប្រភេទវ៉ាក់សាំងរស់ ហើយវាបង្កជាជំងឺក្នុងទម្រង់ស្រាល ដូចនេះត្រូវចាក់តែមាន់ណាដែលមានសុខភាពល្អ ។




ការចឹកគ្នា

ការចឹកគ្នា ចាប់ផ្តើមនៅពេលមាន់មិនទាន់ដុះរោមពេញ ឬនៅពេលមានអាយុពី ២-៣សប្តាហ៍ ។ សភាពបែបនេះបណ្តាលឱ្យមានការចឹកគ្នាដ៏សាហាវ ពិសេសប្រសិនបើមានរបួស ។ មាន់អាចចឹកគ្នារហូតដល់ស្លាប់។

**មូលហេតុ**

- កង្វះអំបិលសារធាតុរ៉ែ និងដោយសារបរាសិតខាងក្នុង
- ទីកន្លែងចង្អៀតពេក



**ការការពារ**

- កាត់ជំពុះ
- ផ្តល់ចំណីមានជាតិសរសៃខ្ពស់

កង្វះវីតាមីន

កង្វះវីតាមីនអា : ស្លាកស្នាមមាននៅលើភ្នែកត្របកភ្នែកស្អិតជាប់គ្នា (វីតាមីនអាជួយបង្កើតភ្នាសសើម) ។

**កង្វះវីតាមីនដេ :** ធ្វើឱ្យមាន់ដែលមានរោមពណ៌ក្រហម និងត្នោត ក្លាយទៅជាខ្មៅ

**កង្វះវីតាមីនបេកំផ្លិច :**  ឃើញមានក្រម៉ក្រៀមនៅជុំវិញភ្នែក និងចំពុះ ។  បាតជើងមានសភាពស្ងួតបែកក្រហែង និងក្រិនដោយមានឈាម ។



*កង្វះជីវជាតិចម្រុះ អាចឱ្យជំងឺងាយជ្រៀតចូល*

កង្វះអាស៊ីដអាមីណោ

**កង្វះលីស៊ីន :** ធ្វើឱ្យអស់ពណ៌នៅរោមស្លាប ។

**កង្វះមេត្យូនីន :** រោមដុះមិនស្មើគ្នា រោមវែងខុសធម្មតា រោមមិនក្រាបរាបស្មើ ។



## ៤. លក្ខណៈទូទៅរបស់វ៉ាក់សាំង

វ៉ាក់សាំងសម្រាប់បង្ការការពារជំងឺ មិនមែនជាថ្នាំសម្រាប់ព្យាបាលទេ

- សត្វដែលអាចចាក់វ៉ាក់សាំងបាន គឺពេលដែលវាមានសុខភាពល្អ
- វ៉ាក់សាំង១មុខ អាចការពារជំងឺបានតែ ១មុខប៉ុណ្ណោះ
- ថ្នាំការពារខុសគ្នា មានវិធីប្រើខុសគ្នា (ផ្លូវបញ្ចូលថ្នាំ)
- ថ្នាំការពារជំងឺដូចគ្នាតែផលិតដោយក្រុមហ៊ុនខុសគ្នាក៏អាចមានវិធី ប្រើប្រាស់ខុសគ្នាដែរ។ ដូច្នេះគប្បីត្រូវដឹងឱ្យបានច្បាស់ពីវិធីប្រើប្រាស់ និង កំរិតប្រើប្រាស់វ៉ាក់សាំងនីមួយៗ ។
- វ៉ាក់សាំងដែលនៅសល់ពីការប្រើប្រាស់ត្រូវដុតចោល
- អ្នកត្រូវកត់ត្រា ថ្ងៃ ខែ និង ចំនួនមាន់ចាក់វ៉ាក់សាំង
- ត្រូវចាក់ថ្នាំការពារដល់មាន់ទាំងអស់ និងចាក់បានទៀងទាត់ ទើបមានប្រសិទ្ធភាព។

តារាងកម្មវិធីចាក់ថ្នាំការពារជំងឺមាន់

| អាយុ | ឈ្មោះវ៉ាក់សាំងការពារជំងឺ | ផ្លូវបញ្ចូល | រំលឹកឡើងវិញក្រោយចាក់ |
|---|---|---|---|
| ១-៣ ថ្ងៃ | ជំងឺដង្ហោកាច់ (ញ៉ូកាស I 2) | បន្តក់ក្នុងភ្នែក/ច្រមុះ | ៦ ខែ |
| ៧-១០ ថ្ងៃ | ជំងឺអុតមាន់ | ជួសស្បែកផ្ទាំងស្លាបរង | ១ ឆ្នាំ |
| ២ ខែ | ជំងឺអាសន្នរោគ | ចាក់សាច់ដុំ | ៦ ខែ |

**បញ្ជាក់:**

ក្នុងករណីមាន់ទុកសម្រាប់ធ្វើមេ និងបា ត្រូវចាក់រំលឹកឡើងវិញ ៥-៦ខែ ម្តង (ជម្ងឺញ៉ូកាស ជម្ងឺអាសន្នរោគ និងជំងឺរលាកផ្លូវដង្ហើម)

## កម្មវិធីទម្លាក់ព្រូន

ទម្លាក់ព្រូនលើកទី១ នៅពេលមាន់អាយុ ១ ខែ និងរំលឹកឡើងវិញ រយៈពេល ២ ទៅ ៣ ខែក្រោយមក ។ គេអាចប្រើថ្នាំ មេបង់ដាសុល សម្រាប់ទំលាក់ព្រូនមាន់ ។ ក្នុងថ្នាំ មេបង់ដាសុល ១ គ្រាប់ សម្រាប់ដាក់ឱ្យមាន់ទម្ងន់រស់សរុប ៥ គីឡូក្រាម។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខាធិការដ្ឋាន ឯកឧត្ដម ជុច ភឿន**

លេខ ០០១/១៤

## គោរពជូន

**ឯកឧត្ដមបណ្ឌិត អ៊ុក រ៉ាប៊ុន**

**រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ឯកឧត្ដម ជាទីគោរពរាប់អាន!

ខ្ញុំមានសេចក្ដីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណជាអនេកចំពោះឯកឧត្ដម និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្ញើមកឲ្យខ្ញុំរៀងរាល់លេខនូវ **ទស្សនាវដ្ដី « កសិកម្ម »** ដែលជាសៀវភៅដ៏មានតម្លៃបង្ហាញអំពីភាពលូតលាស់ និងការវិវឌ្ឍនៃវិស័យកសិកម្ម ព្រមទាំងបានផ្ដល់នូវចំណេះដឹងនិងអត្ថប្រយោជន៍យ៉ាងច្រើនក្រៃលែងចំពោះកសិករខ្មែរនាពេលបច្ចុប្បន្ននេះ។

តបចំពោះសមានចិត្តប្រពៃថ្លៃថ្លា ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្ដម ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកបដោយពុទ្ធពរទាំងបួនប្រការគឺៈ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្ដម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០១៤

**រដ្ឋលេខាធិការ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

ជុច ភឿន

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ : ស្ថិតនៅតាមបណ្ដោយមហាវិថីព្រះនរោត្ដម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

(ដប់ប្រាំ)ថ្ងៃគិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីសហគមន៍កសិកម្មនិងត្រូវចម្លងជូនមន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត០១(មួយ)ច្បាប់ ។

**មាត្រា ២៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើការផ្សព្វផ្សាយនិងជំរុញឲ្យបង្កើតសហគមន៍កសិកម្មទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញប្រកាសស្ដីពីគោលការណ៍ណែនាំនីតិវិធីនៃការបង្កើតនិងការចុះបញ្ជីសហគមន៍កសិកម្ម ។

## ផ្នែកទី ២
## លក្ខន្តិកៈសហគមន៍កសិកម្ម

**មាត្រា ២៦.-**

លក្ខន្តិកៈសហគមន៍កសិកម្ម ត្រូវចែងលក្ខខណ្ឌដូចខាងក្រោម៖

- នាមករណ៍
- ស្លាកសញ្ញា ទីស្នាក់ការ និងអាសយដ្ឋាន
- ប្រភេទមុខរបរ
- ដើមទុនដែលបានមកពីភាគហ៊ុន តម្លៃភាគហ៊ុន និងលក្ខខណ្ឌនៃការបង់ភាគហ៊ុន
- លក្ខខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុ
- លក្ខខណ្ឌនៃហិរញ្ញប្បទាននិងឥណទាន
- របៀបរបបនៃការចុះបញ្ជីគណនេយ្យនិងការគ្រប់គ្រងឯកសារនានា
- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សមាជិកចំពោះបំណុលរបស់សហគមន៍កសិកម្ម ។ ការទទួលខុសត្រូវនេះមិនត្រូវមានកម្រិតលើសពី៤(បួន)ដងនៃចំនួនភាគហ៊ុនដែលសមាជិកម្នាក់ៗកាន់កាប់ឡើយ
- សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិក
- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- លក្ខខណ្ឌនៃការលាឈប់និងការបណ្ដេញចេញពីសមាជិកភាពសហគមន៍កសិកម្ម
- ការប្រព្រឹត្តទៅរបស់មហាសន្និបាតនិងមហាសន្និបាតតំណាង
- សមាសភាពក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការកោះប្រជុំក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- តួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការបញ្ចូលគ្នារបស់សហគមន៍កសិកម្ម

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១១/៣៧

- លក្ខខណ្ឌនៃការរំលាយសហគមន៍កសិកម្ម
- នីតិវិធីដោះស្រាយវិវាទនៅក្នុងសហគមន៍កសិកម្ម
- នីតិវិធីនៃការកែប្រែឬវិសោធនកម្មលក្ខន្តិកៈ
- នីតិវិធីផ្សេងទៀតដែលត្រូវសម្រេចដោយមហាសន្និបាតឬមហាសន្និបាតតំណាង។

**មាត្រា ២៧.-**

ក្នុងករណីដែលសហគមន៍កសិកម្មធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ខ្លួន សហគមន៍កសិកម្មនោះត្រូវដាក់លក្ខន្តិកៈថ្មីជូនមន្ទីរកសិកម្មរាជធានី ខេត្តសាមីជាថ្មីក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃសម្រេចរបស់មហាសន្និបាត ។ ក្នុងករណីដែលមានការប្តូរនាមករណ៍សហគមន៍កសិកម្មនោះ ត្រូវប្រគល់វិញ្ញាបនបត្រចុះបញ្ជីឲ្យមន្ទីរកសិកម្មរាជធានី ខេត្តសាមីវិញដើម្បីទទួលយកវិញ្ញាបនបត្រ ចុះបញ្ជីថ្មីដែលមាននាមករណ៍ថ្មី ។

**មាត្រា ២៨.-**

សហគមន៍កសិកម្ម ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុងដើម្បីគ្រប់គ្រងប្រតិបត្តិការមុខរបររបស់ខ្លួន ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីលក្ខន្តិកៈគំរូនិងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម ។

## ផ្នែកទី ៣
## សិទ្ធិនិងភារកិច្ចរបស់សមាជិកសហគមន៍កសិកម្ម

**មាត្រា ២៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានអាយុ១៨ (ដប់ប្រាំបី) ឆ្នាំឡើង មានសិទ្ធិដាក់ពាក្យសុំចូលជាសមាជិកសហគមន៍កសិកម្មបានដោយស្ម័គ្រចិត្ត ដោយត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

- មានមុខរបរចម្បងក្នុងក្របខ័ណ្ឌនៃប្រព័ន្ធផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម ឬសេវាកម្មដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម
- ទិញភាគហ៊ុន
- បង់ប្រាក់សមាជិកភាព
- គោរពបទប្បញ្ញត្តិនៃច្បាប់នេះ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់មហាសន្និបាតនៃសហគមន៍កសិកម្ម។

**មាត្រា ៣០.-**

សមាជិកសហគមន៍កសិកម្ម ត្រូវបង់ប្រាក់ភាគហ៊ុនដែលខ្លួនបានទិញស្របតាមលក្ខខណ្ឌដូចមានចែងក្នុងលក្ខន្តិកៈ ។ សមាជិកនីមួយៗត្រូវទទួលខុសត្រូវរៀងៗខ្លួនផងនិងរួមគ្នាផងចំពោះ

១២/៣៧

បំណុលរបស់សហគមន៍កសិកម្មក្នុងកម្រិតដូចមានចែងក្នុងលក្ខន្តិកៈ ដែលជាការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់ខ្លួនចំពោះសហគមន៍កសិកម្ម ។

**មាត្រា ៣១.-**

សមាជិកសហគមន៍កសិកម្មមានសិទ្ធិនិងកាតព្វកិច្ចដូចខាងក្រោម ៖

- ចូលរួមមហាសន្និបាតនិងបោះឆ្នោតដោយស្មើភាពគ្នាជាមួយសមាជិកដទៃទៀតដោយពុំគិតពីកម្រិតភាគហ៊ុនដែលកាន់កាប់នៅក្នុងសហគមន៍កសិកម្មឡើយ
- អនុវត្តតាមសេចក្ដីសម្រេចរបស់មហាសន្និបាត
- បោះឆ្នោតនិងឈរឈ្មោះក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្មដោយអនុលោមតាមបទប្បញ្ញត្តិ នៃច្បាប់នេះ
- ទទួលព័ត៌មាន អំពីស្ថានភាពហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម និងទីផ្សារកសិកម្មពីក្រុមប្រឹក្សាភិបាលឬគណៈកម្មាធិការត្រួតពិនិត្យ
- ស្នើសុំការកោះប្រជុំមហាសន្និបាតវិសាមញ្ញដើម្បីពិភាក្សាដោះស្រាយបញ្ហាចាំបាច់ណាមួយដោយអនុលោមតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនៃសហគមន៍កសិកម្ម ប្រសិនបើមានសមាជិកចំនួន១ភាគ៣ (មួយភាគបី) នៃសមាជិកសហគមន៍កសិកម្មទាំងអស់ឯកភាពគ្នាស្នើសុំ
- ធ្វើសំណើឲ្យដាក់ចូលក្នុងរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាដែលមានសារៈសំខាន់សម្រាប់សហគមន៍កសិកម្ម
- ទទួលភាគចំណេញរៀងៗខ្លួន
- ជួលឬប្រើប្រាស់សេវានិងមធ្យោបាយបរិក្ខាររបស់សហគមន៍កសិកម្មដូចសមាជិកដទៃទៀត
- ចូលរួមគ្រប់សកម្មភាពរបស់សហគមន៍កសិកម្ម
- ស្នើសុំលាឈប់ពីសមាជិកភាពនៃសហគមន៍កសិកម្មបាន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ដោយអនុលោមតាមការកំណត់ជាក់ស្ដែងក្នុងលក្ខន្តិកៈរបស់សហគមន៍កសិកម្មសាមី
- ទទួលបាននូវភាគហ៊ុនដែលបានបង់គ្រប់ចំនួនបូកនឹងការប្រាក់ស្របតាមការកំណត់ក្នុងលក្ខន្តិកៈ នៅពេលដែលសមាជិកសុំលាឈប់ឬត្រូវបណ្ដេញចេញ ។ ក្នុងករណីដែលសហគមន៍កសិកម្មមានការខាតបង់ សមាជិកដែលសុំលាឈប់ឬត្រូវបណ្ដេញចេញត្រូវទទួលបន្ទុកបង់ខាតតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់កាប់ ដោយអនុលោមតាមការកំណត់ក្នុងលក្ខន្តិកៈ ។

**មាត្រា ៣២.-**

សមាជិកសហគមន៍កសិកម្មណាម្នាក់ដែលខកខានក្នុងការបង់គ្រប់ចំនួននូវប្រាក់ភាគហ៊ុននិងប្រាក់សមាជិកភាពដែលតម្រូវដោយលក្ខន្តិកៈ សមាជិកនោះពុំអាចប្រើប្រាស់សិទ្ធិនិងទទួលផលប្រយោជន៍ពីសហគមន៍កសិកម្មឡើយ ។

១៣/៣៧

**មាត្រា ៣៣.-**

ក្នុងករណីមានសមាជិកសហគមន៍កសិកម្មណាម្នាក់ ធ្វើឲ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សហគមន៍កសិកម្មឬសមាជិកដទៃទៀតនៃសហគមន៍កសិកម្ម សមាជិករូបនោះអាចត្រូវបានព្យួរសមាជិកភាពឬត្រូវបានបណ្ដេញចេញពីសហគមន៍កសិកម្មក្រោយពីបានការពារខ្លួននៅចំពោះមុខក្រុមប្រឹក្សាភិបាល ។ ការបណ្ដេញចេញពីសហគមន៍កសិកម្ម ត្រូវសម្រេចដោយមហាសន្និបាត ។ ក្នុងករណីមានការប្រញាប់ ក្រុមប្រឹក្សាភិបាលអាចប្រកាសជាបណ្ដោះអាសន្ននូវការព្យួរសមាជិកភាពបាន តែត្រូវមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញជាបន្ទាន់ដើម្បីពិភាក្សានិងសម្រេចលើករណីរក្សាទុកសមាជិកភាពឬបណ្ដេញចេញសមាជិករូបនោះពីសហគមន៍កសិកម្ម ។

**មាត្រា ៣៤.-**

សមាជិកភាពសហគមន៍កសិកម្មត្រូវបានបញ្ចប់ក្នុងករណីណាមួយដូចខាងក្រោម ៖

- សហគមន៍កសិកម្មត្រូវបានក្ស័យធនឬត្រូវបានរំលាយ
- សមាជិកស្លាប់ឬបាត់ខ្លួនដោយអនុលោមតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្ម
- សមាជិកដែលផ្ទេរភាគហ៊ុនទាំងស្រុងទៅសមាជិកផ្សេងទៀត
- សមាជិកដែលត្រូវបណ្ដេញចេញពីសហគមន៍កសិកម្មដោយអនុលោមតាមសេចក្ដីសម្រេចរបស់មហាសន្និបាត
- ករណីផ្សេងទៀតដូចមានចែងក្នុងលក្ខន្តិកៈ ។

## ផ្នែកទី ៤
## សិទ្ធិ ភារកិច្ច និងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម
### អនុផ្នែកទី ១ ៖ សិទ្ធិនិងភារកិច្ចរបស់សហគមន៍កសិកម្ម

**មាត្រា ៣៥.-**

សហគមន៍កសិកម្មមានសិទ្ធិនិងភារកិច្ចដូចខាងក្រោម ៖

១- ធ្វើប្រតិបត្តិការលើមុខរបររបស់ខ្លួនក្នុងក្របខ័ណ្ឌផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្មឬសេវាកម្មពាក់ព័ន្ធផ្សេងទៀតដើម្បីផលចំណេញជូនសមាជិក។

២- ជាតំណាងឲ្យសមាជិកដើម្បីចុះកិច្ចសន្យានិងអនុវត្តកិច្ចសន្យាជាមួយផ្នែកឯកជនឬដៃគូអភិវឌ្ឍផ្សេងទៀត។

៣- ធានាសិទ្ធិរបស់សមាជិកក្នុងការចូលរួមបំពេញគោលដៅសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

៤- ផ្ដល់ជំនួយបច្ចេកទេស អប់រំបណ្ដុះបណ្ដាល លើកកម្ពស់សមត្ថភាពរបស់សមាជិកនិងផ្ដល់ព័ត៌មានទាំងឡាយដល់សមាជិក ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍កសិកម្ម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១៤/៣៧

៥- ស្នើសុំឬទទួលយកជំនួយបច្ចេកទេសឬជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាល និងប្រភពជំនួយស្របច្បាប់ផ្សេងទៀត។

៦- ធ្វើការគ្រប់គ្រងហិរញ្ញកិច្ច គណនេយ្យកិច្ច ការត្រួតពិនិត្យបញ្ជី ការរក្សានិងការបង្កើនដើមទុននិងធនធានដទៃទៀតរបស់សហគមន៍កសិកម្ម អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

៧- បង់ពន្ធនិងបំពេញកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀតដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់ជាធរមាន ។

៨- បំពេញកាតព្វកិច្ចផ្សេងទៀតដែលពាក់ព័ន្ធនឹងគោលដៅរបស់សហគមន៍កសិកម្ម ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចេញប្រកាសស្តីពីគោលការណ៍ណែនាំនៃកិច្ចសន្យាសម្រាប់ប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ។

**មាត្រា ៣៦.-**

សហគមន៍កសិកម្មត្រូវរក្សាទុកឯកសារឬបញ្ជីនៅទីស្នាក់ការរបស់ខ្លួននិងនៅកន្លែងផ្សេងទៀតតាមការកំណត់របស់ច្បាប់។ ឯកសារឬបញ្ជីដែលត្រូវរក្សាទុកមានដូចខាងក្រោម ៖

១- លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ។

២- បញ្ជីសមាជិកសហគមន៍កសិកម្មរួមមាន ៖

- ឈ្មោះនិងអាសយដ្ឋានទីស្នាក់ការរបស់សហគមន៍កសិកម្ម
- ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់សមាជិក
- កាលបរិច្ឆេទចូលជាសមាជិកភាព ។

៣- បញ្ជីភាគហ៊ុនរបស់សមាជិករួមមាន៖

- ឈ្មោះនិងអាសយដ្ឋានទីស្នាក់ការរបស់សហគមន៍កសិកម្ម
- ឈ្មោះសមាជិកដែលកាន់កាប់ភាគហ៊ុន តម្លៃភាគហ៊ុន ចំនួនភាគហ៊ុន និងភាគហ៊ុនដែលបានបង់ ។

៤- តារាងតុល្យការប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម ។

៥- របាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្មអំពីលទ្ធផលនៃប្រតិបត្តិការមុខរបររបស់ខ្លួន ។

៦- កំណត់ហេតុនៃកិច្ចប្រជុំនិងរបាយការណ៍គ្រប់ប្រភេទ ។

៧- ឯកសារផ្សេងៗទៀតរបស់សហគមន៍កសិកម្ម។

## អនុផ្នែកទី ២ ៖ មហាសន្និបាតនៃសហគមន៍កសិកម្ម

**មាត្រា ៣៧.-**

មហាសន្និបាតជាអង្គការខ្ពស់បំផុតរបស់សហគមន៍កសិកម្មដែលមានភារកិច្ចធ្វើការអនុម័តនិងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងដំណើរការបង្កើតនិងការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL

១៥/៣៧

ដែលរួមមាន មហាសន្និបាតកំណើតដំបូង មហាសន្និបាតប្រចាំឆ្នាំ មហាសន្និបាតតំណាង និងមហាសន្និបាតវិសាមញ្ញ ។

មហាសន្និបាតសហគមន៍កសិកម្មមានភារកិច្ចដូចខាងក្រោម ៖

- អនុម័តឬធ្វើវិសោធនកម្មលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង

- បោះឆ្នោតជ្រើសតាំងក្នុងចំណោមសមាជិកសហគមន៍កសិកម្មនូវប្រធាននិងសមាជិកដទៃទៀតរបស់ក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការត្រួតពិនិត្យតាមការបោះឆ្នោតជាសម្ងាត់

- បោះឆ្នោតដកតំណែងពីអ្នកដែលជាប់ឆ្នោតទាំងនោះវិញនិងកំណត់លាភការជូនអ្នកទាំងនោះ ប្រសិនបើមាន

- កំណត់ភារកិច្ចក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ

- ជ្រើសរើសសវនករឬអ្នកត្រួតពិនិត្យនិងអនុម័តយល់ព្រមលើរបាយការណ៍សវនកម្មរបស់សហគមន៍កសិកម្ម

- កំណត់កម្រិតអតិបរមានៃបំណុលដែលសហគមន៍កសិកម្មអាចខ្ចីបានសម្រាប់កម្មវត្ថុ របស់ខ្លួនដោយរក្សានូវស្វ័យភាពរបស់សហគមន៍កសិកម្ម

- អនុញ្ញាតការវិនិយោគ ការចុះកិច្ចសន្យា ការចងការ និងការកៀរគរមូលនិធិសហគមន៍កសិកម្ម

- កំណត់បែបបទ ចំនួនទឹកប្រាក់ និងអត្រាការប្រាក់ដែលអនុញ្ញាតឲ្យសមាជិកខ្ចី

- អនុម័តលើប្រាក់ចំណេញសុទ្ធនៃឆ្នាំនីមួយៗ ក្រោយពេលបានដកប្រាក់ពីប្រាក់ចំណេញសរុបនៃឆ្នាំដើម្បីដាក់បញ្ចូលទៅក្នុងមូលនិធិបម្រុង មូលនិធិបណ្ដុះបណ្ដាល និងក្នុងមូលនិធិផ្សេងទៀត ស្របតាមលក្ខន្តិកៈរបស់សហគមន៍កសិកម្មសាមី និងទូទាត់បំណុលរបស់សហគមន៍កសិកម្មនៃឆ្នាំកន្លងមក

- កំណត់ពីការបែងចែកប្រាក់ចំណេញសុទ្ធដល់សមាជិកសហគមន៍កសិកម្ម

- ធ្វើឲ្យមានលំនឹងឡើងវិញចំពោះការបែងចែកភាគហ៊ុនទៅឲ្យសមាជិកម្នាក់ៗ ក្នុងករណីចំនួនសមាជិកប្រែប្រួល

- ពិនិត្យនិងអនុម័តលើតារាងតុល្យការនិងរបាយការណ៍ស្ដីពីលទ្ធផលនៃប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម

- ពិភាក្សា អនុម័តលើរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការត្រួតពិនិត្យបន្ទាប់ពីបានត្រួតពិនិត្យរួច

- ផ្ដល់ការយល់ព្រមលើកំណត់ហេតុអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលឬគណៈកម្មាធិការត្រួតពិនិត្យ

- អនុម័តលើរបាយការណ៍ជម្រះបញ្ជីរបស់សហគមន៍កសិកម្ម

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១៦/៣៧

- អនុម័តយល់ព្រមលើផែនការសកម្មភាពនិងផែនការហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម សម្រាប់ការិយបរិច្ឆេទបន្ទាប់

- សម្រេចលើការសុំចូលជាសមាជិកថ្មី ការព្យួរនិងការបណ្តេញចេញសមាជិកនីមួយៗ

- សម្រេចលើការផ្លាស់ប្តូរនានា ដូចជាការបំបែក ការបញ្ចូលគ្នា ឬការរំលាយសហគមន៍កសិកម្ម

- ពិនិត្យអនុម័តឬសម្រេចលើការងារផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម ។

**មាត្រា ៣៨.-**

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្មមានភារកិច្ចធ្វើសេចក្តីសម្រេចលើឯកសារសំខាន់ៗនិងការតម្រូវ ដូចមានចែងនៅក្នុងមាត្រា១៧ និង១៨ នៃច្បាប់នេះ ដើម្បីស្នើសុំការចុះបញ្ជីនិងដាក់ឲ្យដំណើរការនៃការិយបរិច្ឆេទសហគមន៍កសិកម្ម ។

**មាត្រា ៣៩.-**

មហាសន្និបាតរបស់សហគមន៍កសិកម្មត្រូវរៀបចំឡើងមួយឆ្នាំម្តងនិងមានភារកិច្ចសំខាន់ៗមួយចំនួនដូចជាបូកសរុបលទ្ធផលប្រតិបត្តិការមុខរបរប្រចាំឆ្នាំ បង្ហាញពីតារាងតុល្យការ បែងចែកផលចំណេញ អនុម័តប្រតិបត្តិការមុខរបរសម្រាប់ឆ្នាំថ្មី អនុម័តលើការសុំលាឈប់របស់សមាជិកចាស់ អនុម័តការសុំចូលជាសមាជិកថ្មី ធ្វើវិសោធនកម្មលក្ខន្តិកៈ ពិនិត្យពិភាក្សានិងអនុម័តកិច្ចការផ្សេងទៀត ។

**មាត្រា ៤០.-**

ក្នុងករណីដែលសហគមន៍កសិកម្មមានសមាជិកលើសពី២០០(ពីររយ)នាក់ សហគមន៍កសិកម្មអាចជ្រើសរើសប្រតិភូតំណាងឲ្យចូលរួមមហាសន្និបាតដែលក្នុងករណីនេះហៅថាមហាសន្និបាតតំណាង ។

**មាត្រា ៤១.-**

មហាសន្និបាតវិសាមញ្ញរបស់សហគមន៍កសិកម្មមានភារកិច្ចសំខាន់សម្រាប់ដោះស្រាយបញ្ហាបន្ទាន់អ្វីមួយ ដែលអាចប្រព្រឹត្តទៅច្រើនដងក្នុងមួយឆ្នាំ អាស្រ័យតាមស្ថានភាពតម្រូវរបស់សហគមន៍កសិកម្មសាមី ។

មហាសន្និបាតវិសាមញ្ញអាចកោះប្រជុំបានដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ ។

**មាត្រា ៤២.-**

ការកោះជុំមហាសន្និបាត ត្រូវធ្វើដោយប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មដោយត្រូវបញ្ជាក់ពីទីកន្លែង កាលបរិច្ឆេទ និងរបៀបវារៈ ហើយត្រូវជូនដំណឹងដល់គ្រប់សមាជិកឲ្យបាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

១៧/៣៧

យ៉ាងតិច១០ (ដប់) ថ្ងៃមុន ។ សេចក្តីជូនដំណឹងត្រូវធ្វើតាមរបៀបផ្សព្វផ្សាយព័ត៌មានធម្មតាហើយត្រូវបិទប្រកាសនៅទីស្នាក់ការសហគមន៍កសិកម្មសាមី ។

មហាសន្និបាតអាចប្រជុំពិភាក្សា អនុម័ត និងសម្រេចបាន លុះត្រាតែមានកូរ៉ុម២ភាគ៣ (ពីរភាគបី) នៃចំនួនសមាជិកសហគមន៍កសិកម្មទាំងមូល ។ ក្នុងករណីដែលលក្ខខណ្ឌខាងលើពុំអាចបំពេញបាន ការកោះប្រជុំមហាសន្និបាតជាលើកទី២ លើរបៀបវារៈដដែលត្រូវធ្វើឡើងក្នុងរយៈពេល ១០ (ដប់) ថ្ងៃបន្ទាប់ពីថ្ងៃកំណត់នៃកិច្ចប្រជុំលើកទី១ ។ កិច្ចប្រជុំលើកទី២នេះ ពុំកំណត់ចំនួនកូរ៉ុមឡើយ ។

មហាសន្និបាតត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬដោយប្រធានអង្គប្រជុំដែលត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកវត្តមាន ។ មហាសន្និបាតត្រូវតែងតាំងលេខាធិការអង្គប្រជុំម្នាក់ដើម្បីធ្វើកំណត់ហេតុដោយបញ្ជាក់អំពីសេចក្តីសម្រេចរបស់មហាសន្និបាតនិងភ្ជាប់បញ្ជីវត្តមានសមាជិកចូលរួមផង ហើយលេខាធិការនិងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ ។

**មាត្រា ៤៣.–**

សមាជិកម្នាក់មានសំឡេងតែមួយគត់នៅក្នុងមហាសន្និបាត ហើយមិនអាចជំនួសដោយតំណាងឬសមាជិកគ្រួសារដែលគ្មានការទទួលខុសត្រូវលើសិទ្ធិសម្រេចរបស់ខ្លួនឡើយ ។

សេចក្តីសម្រេចដែលទាក់ទងនឹងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ការបំបែក ការបញ្ចូលសហគមន៍កសិកម្ម ឬការបណ្តេញចេញសមាជិកណាមួយ ត្រូវមានការយល់ព្រមតាមសំឡេង២ភាគ៣ (ពីរភាគបី) នៃសមាជិកវត្តមាន ។ សេចក្តីសម្រេចផ្សេងៗទៀតរបស់មហាសន្និបាតត្រូវយកសំឡេងភាគច្រើននៃសមាជិកវត្តមានទាំងអស់ ។

## អនុផ្នែកទី ៣ ៖ ក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម

**មាត្រា ៤៤.–**

ក្រុមប្រឹក្សាភិបាលជាអង្គការប្រតិបត្តិរបស់សហគមន៍កសិកម្ម ។ ប្រធាននិងសមាជិកទាំងអស់នៃក្រុមប្រឹក្សាភិបាលត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាត ។ សមាសភាពនៃក្រុមប្រឹក្សាភិបាលមានចំនួនសេសចាប់ពី៣ (បី) រូបឡើងទៅ រួមទាំងប្រធានផង ដោយផ្អែកលើចំនួននៃសមាជិកនិងប្រតិបត្តិការមុខរបរជាក់ស្តែងរបស់សហគមន៍កសិកម្មដែលត្រូវកំណត់នៅក្នុងលក្ខន្តិកៈ របស់សហគមន៍កសិកម្ម ។ ប្តីប្រពន្ធ ឪពុកម្តាយបង្កើត ឪពុកម្តាយក្មេក និងកូនបង្កើត ពុំអាចធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលជាមួយគ្នាបានឡើយ ។

សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាតសម្រាប់អាណត្តិ៥ (ប្រាំ) ឆ្នាំ ។

១៨/៣៧

# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ





កិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ អញ្ជើញជាអធិបតីភាពក្នុងពិធីសម្ពោធអគារវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ ក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋកូរ៉េ





ឯកឧត្តម បណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យស្ថានភាពគ្រោះរាំងស្ងួត និងជួយអន្តរាគមន៍បូមទឹកស្រោចស្រពជូនប្រជាកសិករនៅខេត្តតាកែវ





ការអញ្ជើញចូលរួមជាគណៈអធិបតីក្នុងទិវាស្រែបង្ហាញប្រារព្ធធ្វើនៅខេត្តកំពង់ធំ





ការពិនិត្យស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សា នៅខេត្តកណ្ដាល





សកម្មភាពពិនិត្យការងារទុកដាក់គ្រាប់ពូជបន្លែ នៅស្ថានីយ៍ពិសោធន៍ពូជបន្លែក្បាលកោះ ខេត្តកណ្ដាល





ការពិនិត្យសកម្មភាពការងារពិសោធន៍ពូជបន្លែ នៅស្ថានីយ៍ពិសោធន៍ពូជបន្លែក្បាលកោះ ខេត្តកណ្ដាល




ឯកឧត្តម **យុទ្ធ ភូថង់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំលើកទី០៤ របស់គណៈកម្មាធិការសម្របសម្រួលគម្រោងការប្រតិបត្តិបច្ចេកទេសស្តីពីលទ្ធផលនៃសកម្មភាពគម្រោងដែលបានអនុវត្តរយៈពេលកន្លងមក និងលទ្ធផល នៃការវាយតម្លៃចុងក្រោយរបស់គម្រោងបង្កើនផលិតភាពនិងផ្សព្វផ្សាយវារីវប្បកម្មទឹកសាបដំណាក់កាលទី២




ឯកឧត្តម **ទី សុគន្ធ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមក្នុងពិធីប្រគល់-ទទួលជំនួយសម្រាប់បម្រើឱ្យវិស័យព្រៃឈើរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់រាជរដ្ឋាភិបាលកម្ពុជា



ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលគម្រោងលើកទី០៤ និងវាយតម្លៃបញ្ចប់គម្រោង



លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមជាគណៈកម្មការប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការថ្មី នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម






ឯកឧត្តម **សាន វណ្ណទី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេសស្តីពីការរៀបចំផែនការការងារ១៨ ខែសម្រាប់ឆមាសទី២ឆ្នាំ២០១៤របស់គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមហាអនុតំបន់ទន្លេមេគង្គ នៅខេត្តព្រះសីហនុ






ឯកឧត្តម **គិត សេង** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពសិក្ខាសាលាស្តីពីការអនុវត្តកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្ននៃអនុវិស័យជលផល និងផលិតកម្មសត្វ និងនាំយកអំណោយសមាគមន៍មិត្តបុគ្គលិកកសិកម្មកម្ពុជាជូនគ្រួសារសពមន្ត្រីរាជការ នៅរាជធានីភ្នំពេញ



ឯកឧត្តម **អ៊ាង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមជាគណៈកម្មការប្រឡងជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការថ្មី នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម



ឯកឧត្តម **ម៉ាន សុត្រី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចូលរួមក្នុងពិធីប្រគល់-ទទួលជំនួយសម្រាប់បម្រើឱ្យវិស័យព្រៃឈើរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនដល់រាជរដ្ឋាភិបាលកម្ពុជា



# ទំនួញសំណាបដែលមានរបួស

ខ្លួនជាសំណាប ត្រូវមនុស្សធ្វើបាប ដកបោកវាយដំ
ដាច់ឫសបែកដើម ដង្ហើមឈឺគ្រាំ បាត់ភាពរឹងមាំ
ព្រោះខ្លួនពិការ ។

ស្ទូងសំណាបខ្ចី ភាពជាយុវវ័យ ថាមពលខ្លាំងក្លា
ពេលស្រូវដុះឡើង បែកគុម្ពអស្ចារ្យ ផ្តល់ភោគផលល្អា
បានដូចបំណង ។

*និពន្ធដោយ: លោក **ងិន ឆាយ***
*ប្រធាននាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម*

